ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី

## THE SITUATION OF IMPLEMENTATION AN ANNUAL OPERATIONAL PLAN BY MUNICIPAL OF EDUCATION YOUTH AND SPORT IN RATANAKIRI PROVINCE

ព្រិញ ចាន់ហួរ

PRINH CHANHUOR

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២១

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី

## THE SITUATION OF IMPLEMENTATION AN ANNUAL OPERATIONAL PLAN BY MUNICIPAL OF EDUCATION YOUTH AND SPORT IN RATANAKIRI PROVINCE

ព្រិញ ចាន់ហួរ

PRINH CHANHUOR

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២១

សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត ឈាង សទ្ធាត

សាស្ត្រាចារ្យដឹកនាំរង ៖ លោក ថៃ ហេង

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមធានាអះអាង និងបញ្ជាក់ជូនថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្តរតនគិរី** " សម្រាប់បំពេញលក្ខខណ្ឌ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃពិតប្រាកដរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់មាននរណាម្នាក់បានសិក្សាស្រាវជ្រាវ និងប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនេះ ឬនៅសាកលវិទ្យាល័យណាមួយ ឬវិទ្យាស្ថានថ្នាក់ស្មើ ឬខ្ពស់ជាងណាមួយឡើយ ។ ខ្ញុំបាទសូមបញ្ជាក់ជូនផងដែរថា ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារ ឬការចុះបញ្ជីឯកសារយោងណាមួយ ដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធនោះទេ ។

ខ្ញុំបាទសូមអះអាងថា និក្ខេបបទសិក្សាស្រាវជ្រាវខាងលើនេះ ពិតជាស្នាដៃរបស់ខ្ញុំបាទពិតប្រាកដមែន ។

ថ្ងៃ.................................ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី.............ខែវិច្ឆិកា ឆ្នាំ២០២១

**ហត្ថលេខាបេក្ខជន**

**ព្រិញ ចាន់ហួរ**

# លិខិតបញ្ជាក់

| | | |
|---|---|---|
| លោកបណ្ឌិត | **ឈាង សទ្ធាត** | ជាសាស្រ្តាចារ្យដឹកនាំ |
| លោក | **ថៃ ហេង** | ជាសាស្រ្តាចារ្យដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ព្រិញ ចាន់ឃួរ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវពី " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " ពិតប្រាកដមែន។

ថ្ងៃ....................................ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី.............ខែវិច្ឆិកា ឆ្នាំ២០២១

................................................ ................................................

**លោកបណ្ឌិត ៖ ឈាង សទ្ធាត**

ជាសាស្រ្តាចារ្យដឹកនាំ

**លោកសាស្ត្រាចារ្យ ៖ ថៃ ហេង**

ជាសាស្រ្តាចារ្យដឹកនាំរង

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណដល់ ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទ បានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ នាពេលកន្លងមក ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គណៈកម្មការគ្រប់គ្រងបណ្តុះបណ្តាលថ្នាក់វិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកបណ្ឌិត លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំដល់យើងខ្ញុំទាំងអស់គ្នា ដោយមិនគិតពីការនឿយហត់ ។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកបណ្ឌិត **ឈាង សច្ចាត** ជាសាស្ត្រាចារ្យដឹកនាំ និងលោកសាស្ត្រាចារ្យ **ថៃ ហេង** ជាសាស្ត្រាចារ្យដឹកនាំរង ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីពន្យល់ណែនាំដល់រូបខ្ញុំគ្រប់ជំហាន ទើបធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំជោគជ័យ និងបញ្ចប់ដោយរលូន

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរតនគិរី និងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ដែលបានអនុញ្ញាត និងចូលរួមសហការក្នុង អំឡុងពេលដំណើរការប្រមូលទិន្នន័យ ដែលធ្វើឲ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

សូមគោរពសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះលោកឪពុក **ព្រឹក ហើយ** និងអ្នកម្តាយ **តាក់ សារម្ងន** ដែលបានផ្តល់កំណើតព្រមទាំងលះបង់ពេលវេលា ជំនះឧបសគ្គ ចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ដ៏ប្រពៃរហូតកូនទទួលបាននូវអ្វីៗដូចក្នុងថ្ងៃនេះ និងសូមថ្លែងអំណរគុណដ៏ស្មុគ្រស្មោះអំពីដួងចិត្ត ចំពោះឧត្តមភរិយា **ធឿន សុធា** ដែលបានលះបង់ពេលវេលាដ៏មមាញឹក ការចំណាយសព្វបែបយ៉ាងក្នុងការសិក្សារបស់ខ្ញុំ ព្រមទាំងការផ្តល់កម្លាំងចិត្តជំរុញការតស៊ូរបស់ខ្ញុំរហូតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នាពេលនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សាដល់អ្នកទាំងអស់គ្នាសូម មានសុខភាពល្អបរិបូណ៌ ព្រមទាំងជួបនូវពុទ្ធពរ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឡើយ ។

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវលើប្រធានបទ " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " មានគោលបំណងសិក្សាស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ និងសិក្សាពីបញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាក្នុងខេត្តរតនគិរី ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះ គឺប្រើប្រាស់បរិមាណវិស័យ និងគុណវិស័យ ។ ការប្រមូលទិន្នន័យតាមបរិមាណវិស័យគឺប្រើប្រាស់កម្រងសំណួរជាមួយមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំខេត្ត មន្ត្រីការិយាល័យអប់រំស្រុក និងពីគណៈគ្រប់គ្រងសាលាមធ្យមសិក្សាទុតិយភូមិ សរុបចំនួន ៧៨ នាក់ ។ ទិន្នន័យបែបគុណវិស័យប្រមូលពីប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនៃនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍន៍សរុបចំនួន ៧ នាក់ ។ សូចនាករសម្រាប់ការវាស់ទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរ គឺទទួលបានពីការសំយោគទ្រឹស្តី និងឯកសារពាក់ព័ន្ធការធ្វើផែនការសាលារៀន និងផែនការយុទ្ធសាស្ត្ររបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ការប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យតាមបរិមាណវិស័យ គឺផ្តោតទៅលើការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន និងផ្ទះបញ្ជាំងជាមួយទិន្នន័យសម្ភាសន៍ដោយផ្តោតលើការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត រតនគិរីក្នុងកម្រិត " ល្អ " (មធ្យមភាពពិន្ទុ = ៣.៦៦) ។ ក្នុងន័យនេះប្រសិទ្ធភាពរបស់មន្ទីរ ក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ គឺផ្តោតសំខាន់លើ " ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន " និងបន្តលើកកម្ពស់ លើការចូលរួមរបស់មាតាបិតា និងសហគមន៍ក្នុងការជួយការសិក្សារបស់សិស្ស ។ បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី គឺមានបញ្ហាប្រឈមមួយចំនួនដោយក្នុងនោះ ទាមទារឱ្យផ្តោតលើការពង្រឹងយន្តការការងារ ទាក់ទងទៅនឹង " ពិនិត្យតាមដាននិងវាយតម្លៃផែនការ កម្មវិធី និងគម្រោង " ។

សរុបមក ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឱ្យមានប្រសិទ្ធភាព គឺត្រូវការការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដែលក្នុងនោះអង្គភាពខ្សែបណ្តោយគឺផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន គឺជាចំណុចស្នូលក្នុងការវាស់វែងលើការបន្សុី នៃក្របខណ្ឌជាយុទ្ធសាស្ត្ររបស់ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរ ។ ឆ្លើយតបទៅនឹងបញ្ហាប្រឈម ការកសាងធនធានមនុស្សដើម្បីបំពេញទៅតាមផែនការងារ និងការត្រៀមនូវយន្តការការងារ លើការពិនិត្យតាមដានគឺជាដំណោះស្រាយដ៏ល្អមួយ ក្នុងកិច្ចខិតខំលើការងារកំណែទម្រង់ការអប់រំរបស់ខេត្តរតនគិរីផងដែរ ។

**ពាក្យគន្លឹះ ៖** ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ/ មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។

# ABSTRACT

The purpose of these research was study on the current practices of annual operational plan and to defines the challenges of municipal of education youth and sport in Ratanakiri Province. The combination of research methodology was applied for both quantitative research method and qualitative research method. The elements used for describe on the current practices and challenges of AOP were used the tools of school's AOP in quantitative research design and questions for conducting interview protocol were used the elements of Municipal's AOP with key informants in order to find the supporting ideas and relevance perspectives on the situation of implementation as well.

The survey of quantitative data collection is 78 consist of high school management team, staff in local educational District and provincial. The data were analyzed by using descriptive statistics such as frequency, percentage, mean and standard deviation. The in-depth interview was conducted with 7 key informants, Directorate of Provincial municipal, staff in the Department of Planning under MoEYS and development partners to explore the current practices and challenges on AOP of educational Municipal of Ratanakiri Province.

The findings indicated the current practices of AOP by educational municipal in Ratanakiri province in the "good" level (Mean = 3.66). By this mean, the municipal need to build up on "school leadership" components and strengthening on the parents and community involvement in student's learning. Doing so, the effectiveness of AOP will sustain and maintain in the best approach manners. The municipal challenge on AOP implementation is "monitoring and evaluation" due to the lack of staff support for job implementation and other resources to judge the well mechanism for AOP in practices.

In conclusion, the current practices of AOP by educational municipal in Ratanakiri province need to involves from all stake holders and the main focus is schooling in order to measure the achievement of provincial and the alignment of educational planning as well. This finding could be useful to the policymakers at

ministry level, so that they can organize enough resources and well plan for implementation and response to the educational reform and educational quality assurance for Ratanakiri province northeast of Cambodia as well.

**KEY WORDS**: Annual Operational Plan (AOP), Municipal of Education Youth and Sport in Ratanakiri Province.

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៧២០៥ អយក. [illegible]

(ការសម្គាល់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នូន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
 "ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
 "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

# បញ្ជីរាយនាមអក្សរកាត់

| | | |
|---|---|---|
| PB | = | Planning Budget |
| AOP | = | Annual Operational Plan |
| ESP | = | Education Strategic Plan |
| SW | = | Sweden |
| SIG | = | School Improvement Grants |
| GEIP | = | General Education Improvement Project |
| SEIP | = | School Improvement Project |
| M&E | = | Monitoring and Evaluation |
| ICT | = | Information Communication Technology |
| POE | = | Provincial of Education |
| DOP | = | Department of Planning |
| មឋភ | = | មធ្យមសិក្សាបឋមភូមិ |
| មទភ | = | មធ្យមសិក្សាទុតិយភូមិ |

# បញ្ជីតារាង


| តារាង | | ចំណងជើង | ទំព័រ |
|---|---|---|---|
| តារាង ៤.១ | ៖ | ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ | ៣៦ |
| តារាង ៤.២ | ៖ | ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន | ៣៧ |
| តារាង ៤.៣ | ៖ | ចូលរួមសកម្មភាពលើការងារបង្រៀន និងរៀន | ៣៩ |
| តារាង ៤.៤ | ៖ | ការកសាងធនធានសមត្ថភាពគ្រូ និងសេវាជួយសិស្ស | ៤០ |
| តារាង ៤.៥ | ៖ | ការកសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន | ៤២ |
| តារាង ៤.៦ | ៖ | កៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ | ៤៣ |
| តារាង ៤.៧ | ៖ | មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស | ៤៤ |
| តារាង ៤.៨ | ៖ | សរុបស្ថានភាពនៃការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលា | ៥៥ |
| តារាង ៤.៩ | ៖ | ការកំណត់គោលនយោបាយអប់រំ | ៦៣ |
| តារាង ៤.១០ | ៖ | ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ | ៦៤ |
| តារាង ៤.១១ | ៖ | ការអនុវត្តផែនការ | ៦៥ |
| តារាង ៤.១១ | ៖ | ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | ៦៦ |

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន .....i
លិខិតបញ្ជាក់.....ii
សេចក្តីថ្លែងអំណរគុណ.....iii
មូលន័យសង្ខេប.....iv
Abstract.....vi
លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ.....vii
បញ្ជីពាក្យអក្សរកាត់.....x
ចំណងជើងតារាង.....xi


## ជំពូកទី១

## សេចក្តីផ្តើម


១.១ ផលិតផលបញ្ហានៃការស្រាវជ្រាវ.....១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ.....៣
១.៣ គោលបំណងនៃការស្រាវជ្រាវ .....៤
១.៤ សំណួរស្រាវជ្រាវ .....៤
១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ.....៥
១.៦ ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ .....៥
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៦

## ជំពូកទី២

## ការរំលឹកទ្រឹស្តី


២.១ ពន្យល់ពាក្យបច្ចេកទេស...............................................................................៩

២.១.១ ផែនការប្រតិបត្តិប្រចាំឆ្នាំ..........................................................................៩

២.១.២. បុគ្គលិកអប់រំ.........................................................................................៩

២.១.៣. សកម្មភាព............................................................................................៩

២.១.៤. ថវិកា...............................................................................................១០

២.១.៥. ក្របខណ្ឌពេលវេលា...........................................................................១០

២.១.៦. ច្បាប់ហិរញ្ញវត្ថុ.....................................................................................១០

២.២ ដំណើរការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ..............................................................១១

២.៣ ចំណុចខ្លាំង និងចំណុចខ្សោយនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ.......១៣

២.៤. តម្រូវការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុ...............១៦

២.៥. លទ្ធផលនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ.........................................១៩

២.៦. ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ....................................២០


## ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ


៣.១ គម្រោងវិភាគ ( Analysis Plan )....................................................................២៣

ក. វិធីសាស្ត្របរិមាណវិស័យ ( Quantitative Research Design )................................២៣

ខ. វិធីសាស្ត្រគុណវិស័យ ( Qualitative Research Design )......................................២៤

៣.១.១ ការសិក្សាស្រាវជ្រាវតាមបរិមាណវិស័យ........................................២៤
៣.១.១.១ ទំហំសំណាក និងការធ្វើសំណាក (Sample Size and Sampling Technique).........................................................................................................២៤
៣.១.១.២ ឧបករណ៍សម្រាប់ការស្រាវជ្រាវ (Research Instrument).២៧
៣.១.១.៣ កម្រិតចន្លុលបន្ទាញ...........................................................២៨
៣.១.១.៤ កម្រងសំណួរ.....................................................................២៩
៣.១.១.៥ ការប្រមូលទិន្នន័យតាមបរិមាណវិស័យ (Data Collection Procedure).........................................................................................................៣០
៣.១.១.៦ ការវិភាគទិន្នន័យតាមបរិមាណវិស័យ (Data Analysis)....៣០
៣.១.២ ការសិក្សាស្រាវជ្រាវតាមគុណវិស័យ...........................................៣១
៣.១.២.១ អ្នកចូលរួមសម្ភាសន៍ (Key informants).................................៣១
៣.១.២.២ នីតិវិធីនៃការសម្ភាសន៍ (Interview protocol)......................៣២
៣.១.២.៣ ការប្រមូលទិន្នន័យតាមគុណវិស័យ (Data Collection Procedure).........................................................................................................៣២
៣.១.២.៤ ការវិភាគទិន្នន័យតាមគុណវិស័យ (Data Analysis)........៣២
៣.២ ក្រមសីលធម៌នៃការស្រាវជ្រាវ...............................................................៣៣

## ជំពូកទី៤

## លទ្ធផលស្រាវជ្រាវ

៤.១ ទិន្នន័យព័ត៌មានទូទៅគណៈគ្រប់គ្រងសាលានៅមធ្យមសិក្សាមន្ត្រីការិយាល័យអប់ រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំយុវជននិងកីឡា ខេត្ត.......៣៤
៤.១.១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលាមធ្យមសិក្សា.....................៣៤

**៤.១.២ ព័ត៌មានទូទៅមន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅ ការិយាល័យអប់រំយុវជន និងកីឡាចំណុះមន្ទីរអប់រំ..........................៣៥**

**៤.២ ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន............៣៦**

**៤.២.១ ទិន្នន័យតាមបែបបរិមាណវិស័យពីគណៈគ្រប់គ្រងសាលាមន្ត្រីការិយាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡា.......៣៦**

**៤.២.២ ទិន្នន័យតាមគុណវិស័យ (ទិន្នន័យបានពីប្រធាន អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយក ដ្ឋានផែនការ និងដៃគូអភិវឌ្ឍ).........................................៤៦**

**៤. ៣ បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ..................................៦៣**

៤.៣.១ ទិន្នន័យតាមបែបបរិមាណវិស័យពីគណៈគ្រប់គ្រងសាលាមន្ត្រីនៅ ការិយាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំខេត្ត..........................................................**៦៣**

៤.៣.២ ទិន្នន័យតាមគុណវិស័យ ពីបញ្ហាប្រឈមនៅការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី (ទិន្នន័យបានពីប្រធាន-អនុប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍ)..................................................................**៦៧**

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

**៥.១ សេចក្តីសន្និដ្ឋាន...........................................................................................៧៧**

**៥.២ សំណូមពរ.....................................................................................................៧៩**

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហា

ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០-២០៥០ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ. ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ២០១៦-២០៣០ សំដៅប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ ២០៥០ និងដើម្បីចូលរួមចំណែកក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍសកល ។

សេចក្តីប្រកាស ស្តីពីការអប់រំដែលត្រូវបានអនុម័តនៅវេទិកាអប់រំពិភពលោកនៅអ៊ីនឈុនប្រទេសកូរ៉េខាងត្បូង នៅថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១៥ វាគឺជាការបន្តនៃចលនាអប់រំសម្រាប់ទាំងអស់គ្នា (EFA) និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍លើវិស័យអប់រំ ហើយគោលដៅជាច្រើនត្រូវបានផ្អែកលើការពិនិត្យឡើងវិញនៃវឌ្ឍនភាពចាប់តាំងពីវេទិកាអប់រំពិភពលោកឆ្នាំ ២០០០ នៅទីក្រុងដាកា **( Incheon Declaration. 2015 )** ។

ទន្ទឹមនឹងនេះ ក្រសួងអប់រំយុវជន និងកីឡា ប្រឹងកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ។ ដើម្បីសម្រេចចក្ខុវិស័យខាងលើក្រសួងអប់រំយុវជននិងកីឡា មានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌ និងការរីកចម្រើនទាំងក្នុងតំបន់ និងសកលលោក ។

វត្ថុបំណងចំពោះក្រសួងអប់រំយុវជន និងកីឡា គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ និងកាយសម្បទា ។

ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញារបស់ក្រសួងអប់រំយុវជន និងកីឡា គ្រប់បណ្តាក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធនានា ត្រូវផ្តល់ភាពងាយស្រួល និងសហការឱ្យបានប្រសើរដោយធ្វើយ៉ាងណាជួយ ជំរុញឱ្យស្ថាប័នអាទិភាពមួយនេះសម្រេចនូវលទ្ធផលផ្លែផ្កា ដោយមានការចូលរួមពីមន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យអប់រំយុវជន និងកីឡាស្រុក-ក្រុង និងជាពិសេសសាលារៀនគ្រប់កម្រិតថ្នាក់ចាប់ពីមតេយ្យសិក្សា រហូតដល់មហាវិទ្យាល័យដែលជាសេនាធិការផ្ទាល់ និងធ្វើការយ៉ាងសកម្មជាមួយ សិស្សានុសិស្សក្នុងការផ្តល់ការអប់រំ ។

ការរៀបចំផែនការបានច្បាស់លាស់ និងមានការចូលរួមបានពេញលេញ បង្ហាញឱ្យឃើញពីសញ្ញាវិជ្ជមាននៃការផ្តល់នូវសេវាអប់រំទៅដល់អ្នកទទួលសេវាបានល្អប្រសើរ ព្រោះថាផែនការជាផែនទីបង្ហាញផ្លូវសម្រាប់តម្រង់ដល់មន្ទីរអប់រំគ្រប់លំដាប់ថ្នាក់ ។ ទន្ទឹមនឹងនេះដែរ ក្រសួងបានធ្វើវិសហមជ្ឈការដល់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ នូវតួនាទីភារកិច្ច ស្វ័យភាពក្នុងការសម្រេចចាត់ចែងទៅលើផែនការ ឬសកម្មភាពទាំងឡាយណាដែលអង្គភាពសាមីបានគ្រោង និងដាក់ចេញ ដូចជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍសាលារៀន ឬផែនការប្រតិបត្តិសាលារៀនរយៈពេល ១ ឆ្នាំជាដើម ព្រោះថាវាបង្ហាញពីការចូលរួមការអនុវត្ត រវាងអ្នកផ្តល់សេវា និងអ្នកដែលត្រូវទទួលសេវា ជាជាងការដែលថ្នាក់ក្រោមជាតិអនុវត្តទៅតាមតែថ្នាក់ជាតិកំណត់ ឬគូសវាសឱ្យអនុវត្ត ដែលប្រការនេះវាអាចនឹងមិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន ។

ក្នុងន័យនេះ វិស័យអប់រំក្នុងខេត្តរតនគិរី ក៏កំពុងបោះជំហ៊ានទៅមុខយ៉ាងស្វាហាប់ ដោយបានប្រែក្លាយនូវកំរិតយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ឱ្យមានភាពល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការផ្តល់នូវការអប់រំប្រកបដោយសមភាព និងសមធម៌ ទៅដល់បងប្អូនជនជាតិដើមភាគតិចគ្រប់ជនជាតិ ។ ដូចដែលបានលើកបង្ហាញក្នុងរបាយការណ៍ សន្និបាតស្រាប់នូវស្នាដៃ ឬលទ្ធផលសម្រេចបានរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី តាមរយៈការអនុវត្តទៅតាមផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន ដែលមានភាគីពាក់ព័ន្ធនានាបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឱ្យផែនការទាំងនេះសម្រេច

បាននូវលទ្ធផលល្អប្រសើរ ព្រោះថាផែនការប្រតិបត្តិជាផែនការមួយដែលមានភាពច្បាស់លាស់ទៅលើចំណុចដៅ ចង្កោមសកម្មភាព ពេលវេលា ថវិកា អ្នកពាក់ព័ន្ធ ទីកន្លែង ហើយលទ្ធផលរំពឹងទុក ។

យ៉ាងណាក៏ដោយ ការអនុវត្តនូវផែនការប្រតិបត្តិរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី នៅមិនទាន់មានភាពរលូន និងល្អប្រសើរនៅឡើយទេ ដោយកង្វះនូវការចូលរួមពីអ្នកពាក់ព័ន្ធ ឬការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនូវតួនាទីភារកិច្ចនៅមានកម្រិត ជាពិសេស ដោយសារខេត្តរតនគិរីជាខេត្តដាច់ស្រយាល ខ្ពង់រាប មានជនជាតិដើមភាគតិចច្រើនរស់នៅលាយលំគ្នា និងគ្រប់ដណ្តប់ទៅទៅប្រពៃណី ជំនឿដូនតា និងដោយវិបត្តិសកល ( កូវីដ-១៩ ) ជាដើម ។ តើឬសគល់នៃ បញ្ហាខាងលើមានអ្វីបន្ថែមទៀតដែលយើងគួតប្បីស្វែងយល់ ព្រមទាំងរកដំណោះស្រាយ ?

## ១.២ ចំណោទបញ្ហា

ការធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំត្រូវមានសង្គតិភាពគ្នា ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំផែនការដោយមានការចូលរួមពីភាគីពាក់ព័ន្ធចាប់ពីថ្នាក់មន្ទីរ ក្រុង/ស្រុក និងសាលារៀនដែលជាអ្នកអនុវត្តដោយផ្ទាល់ជាមួយអ្នកទទួលសេវា ។ ជាក់ស្តែងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរីបានឆ្លុះ បញ្ចាំងពីសកម្មភាព តួនាទីភារកិច្ចរបស់បុគ្គលិកអប់រំនៅតាមការិយាល័យនីមួយៗអនុវត្តឱ្យសមស្រប តាមផែនការ តែទោះជាយ៉ាងណាចង្កោមសកម្មភាពជាអាទិភាពទាំងនោះដែលមន្ទីរបានដាក់ចេញ ពិត ជាមិនអាចសម្រេចបានទាំងស្រុងនោះទេ ដោយមានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង ជាហេតុនាំ ឱ្យលទ្ធផលសម្រេចបាននៅមានកម្រិត ។ ជាឧទាហរណ៍ៈ បញ្ហាប្រឈមនានានៅតាមការិយាល័យដែល ចំណុះបានរំលេចចេញនៅក្នុងរបាយការណ៍សន្និបាតដូចជាៈ ទីតាំងអនុវត្តកម្មវិធីនៅដាច់ស្រយាលពិបាក ធ្វើដំណើរ ការគ្រប់គ្រងសិស្សគ្រប់កម្មវិធីពុំទាន់មានស្ថិរភាព ( សិស្សបោះបង់ច្រើននៅរដូវវស្សា ) ខ្វះធនធានគ្រូជំនាញនៅតាមមជ្ឈមណ្ឌលសហគមន៍ ការជ្រើសរើសគ្រូពុំទាន់សមស្របតាមលក្ខខណ្ឌរបស់ក្រសួង ការពិនិត្យតាមដានពុំបានដិតដល់ ( ខ្វះថវិកា ) ការចូលរួមរបស់អាជ្ញាធរមិនទាន់បានទូលំទូលាយ ខ្វះការចូលរួមពង្រឹងការអប់រំក្រៅប្រព័ន្ធនៅមូលដ្ឋានពីមន្ទីរទទួលបន្ទុកថ្នាក់ស្រុក និង

បញ្ហា ប្រឈមនានាដែលបានលើកឡើងនៅក្នុងរបាយការណ៍សមិទ្ធកម្មមានៈ សកម្មភាពក្នុងអនុវិស័យមួយ ចំនួនត្រូវបានកាត់ចោលដោយខ្វះខាតថវិកា សកម្មភាពដែលត្រូវអនុវត្តមួយចំនួនត្រូវបានកាត់ចោលដោយជម្ងឺរាតត្បាត ការចុះជួយសាលាដែលធ្វើការបង្រៀនតាមអនឡាញមិនបានជិតដល់ និងទូលំទូលាយ ពិបាកក្នុងការធ្វើដំណើរនៅខែវស្សា កូនសិស្សគ្មានទូរសព្ទទំនើប គ្មានបណ្តាញអ៊ីនធើណែតជាដើម ។ ម្យ៉ាងវិញទៀតធនធានសម្ភារៈ ថវិកាគាំទ្រមិនទាន់មានលក្ខណៈគ្រប់គ្រន់ និងឆ្លើយតបទាន់ពេលវេលានៅឡើយដែលនាំឱ្យការអនុវត្តកម្មវិធីមិនទាន់បានពេញលេញ ពិសេសការចង្អុលបង្ហាញ ឬចំណាត់ការរបស់គណៈមន្ទីរនៅមានកម្រិត ដែលជាហេតុនាំឱ្យការអនុវត្តតាមការិយាល័យមួយចំនួននៅមានភាពរអាក់រអួល និងមានលទ្ធផលមិនទាន់ទទួលយកបាន ។ ការដែលបុគ្គលិកអប់រំតាមការិយាល័យមិនមានកិច្ចសហការ ព្រមទាំងការបំពេញការងារដោយមិនស្គាល់ពីតួនាទីរបស់ខ្លួនជាហេតុនាំឱ្យអង្គភាព ឬការអនុវត្តផែនការប្រតិបត្តិដែលបានដាក់ចេញមិនបានសម្រេចតាមផែនការកំណត់ ។ បញ្ហាទាំងអស់ខាងលើជាហេតុនាំឱ្យគុណភាពអប់រំ មិនឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០២៥ ឬឆ្នាំ ២០៣០ ឡើយ ។ ហេតុដូច្នេះហើយទើបអ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសយកប្រធានបទ " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " មកសិក្សាស្រាវជ្រាវដើម្បីស្វែងចំណុចល្អ និងចំណុចខ្វះខាតដែលជាបញ្ហាប្រឈម ដើម្បីធ្វើការកែលម្អជានាជំរុញឱ្យការអនុវត្តផែន ការប្រតិបត្តិប្រចាំឆ្នាំកាន់តែមានភាពល្អប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងក៏ដូចជាគោលនយោបាយអភិវឌ្ឍជាតិ ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

១. សិក្សាពីប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី

២. សិក្សាពីបញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាក្នុងខេត្តរតនគិរី

## ១.៤ សំណួរស្រាវជ្រាវ

១. តើស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីមានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ?

២.តើស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីជួបបញ្ហាប្រឈមយ៉ាងដូចម្តេចខ្លះ?

## ១.៥ សារៈសំខាន់នៃការសិក្សា

លទ្ធផលនៃការសិក្សាទៅលើប្រធានបទ " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " នេះ និងផ្តល់ជាមូលដ្ឋាន និងបំនិនយល់ដឹងដ៏ទូលំទូលាយដល់អ្នកគ្រប់គ្រងក្នុងការប្រមើលមើលជុំវិញលទ្ធផលគ្រប់គ្រងរបស់ខ្លួន ឈានទៅរកគំនិតផ្តួចផ្តើមធ្វើផែនការពង្រឹងប្រសិទ្ធភាពការងារឱ្យកាន់តែប្រសើរឡើង ។ ផែនការប្រតិបត្តិប្រចាំឆ្នាំជាឧបករណ៍គ្រប់គ្រងដ៏មានសារៈសំខាន់មួយរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ដែលមិនអាចខ្វះបាន ។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " នេះ គឺមានវិសាលភាពគ្រប់ដណ្តប់ទៅលើសកម្មភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ក្នុងឆ្នាំ ២០១៩-២០២០ តែប៉ុណ្ណោះ ដោយឈរលើលទ្ធភាព និងពេលវេលារបស់អ្នកស្រាវជ្រាវ ដែលកំណត់យកការិយាល័យចំណុះឱ្យមន្ទីរអប់រំយុវជន និងកីឡាខេត្តទាំង ៨ ដែលមានចំនួនសំណាកសរុប ២៤ នាក់ ការិយាល័យអប់រំយុវជន និងកីឡាស្រុកទាំង ៩ ស្រុក មានចំនួនសំណាកសរុប ២៧ នាក់ គណៈគ្រប់គ្រងសាលាមធ្យមសិក្សាទុតិយភូមិទាំង ១០ មានចំនួនសំណាកសរុប ៣០ នាក់ ប្រធាន/អនុប្រធានមន្ទីរចំនួន ៣ រូប មន្ត្រីនាយកដ្ឋានផែនការចំនួន ០៣ រូប ដៃគូរអភិវឌ្ឍចំនួន ០១ រូប ដែលស្ថិតក្រោមឱវាទនៃក្រសួងអប់រំយុវជន និងកីឡា ដែលមានចំនួនសំណាកសរុបចំនួន ៩០ នាក់ ។ ការសិក្សានេះ គឺវាស់តែទៅលើការអនុវត្តរបស់សាលារៀន និងទស្សនយល់ឃើញរបស់មន្ទីរ និងនាយកដ្ឋានពាក់ព័ន្ធទៅលើការងារផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីតែប៉ុណ្ណោះ ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា **៥** ជំពូកដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖

- **ជំពូកទី ១** : ជំពូកនេះ និងបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ពីចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ រួមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវផងដែរ ។

- **ជំពូកទី ២** : រំលឹកទ្រឹស្តី គោលការណ៍នានាដែលពាក់ព័ន្ធ លើកមកបង្ហាញពីស្ថានភាពទូទៅ ការបង្ហាញអត្ថន័យពាក់ព័ន្ធទៅនឹងការដឹកនាំ ការគ្រប់គ្រងលើការងាររដ្ឋបាលដែលមានប្រសិទ្ធភាព ។

- **ជំពូកទី ៣** : បង្ហាញពីវិធីសាស្ត្រនានាក្នុងការស្រាវជ្រាវ ព្រមទាំងការវិភាគនូវទិន្នន័យ ការវិភាគទ្រឹស្តីដោយឆ្លុះបញ្ចាំងទៅនឹងការអនុវត្តន៍ជាក់ស្តែង ។

- **ជំពូកទី ៤** : ការបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ និងការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយរបស់នាយកសាលាទៅលើការដឹកនាំគ្រប់គ្រងអង្គភាព ។

- **ជំពូកទី ៥** : សេចក្តីសន្និដ្ឋាន និងសំណូមពរ និងការផ្តល់អនុសាសន៍ដោយសង្ខេបទៅលើចំណុចដែលបានវិភាគ និងការផ្តល់អនុសាសន៍ទៅលើចំណុចខ្លះៗដើម្បីកែលម្អ ។

# ជំពូកទី ២

# ការរំលឹកទ្រឹស្តី

## ២.១ ពន្យល់ពាក្យបច្ចេកទេស

ការស្រាវជ្រាវនេះ មានពាក្យបច្ចេកទេសមួយចំនួនដែលទាមទារឱ្យយើងស្វែងយល់ជាមុន ដើម្បីជាភាពងាយស្រួលដល់ការយល់ និងការអានដែលពាក្យទាំងនេះមានដូចខាងក្រោម៖

### ២.១.១ ផែនការប្រតិបត្តិប្រចាំឆ្នាំ

- **ផែនការប្រតិបត្តិប្រចាំឆ្នាំ** ជាបណ្តុំសកម្មភាព ដែលបានគ្រោងសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ ដោយជានាថាសកម្មភាពនីមួយៗស្របតាមចក្ខុវិស័យ គោលដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ។ ផែនការប្រតិបត្តិប្រចាំឆ្នាំជាត្រីវិស័យកំណត់ផ្លូវ ថាតើអង្គភាពមួយត្រូវដើរទៅទិសខាងណា ដើរទៅយ៉ាងដូចម្តេចដើម្បីឱ្យទៅដល់ទិសដៅ ។ ជាចុងក្រោយ ផែនការប្រតិបត្តិប្រចាំឆ្នាំជាគម្រោងលម្អិតដែលរៀបរាប់ពីសកម្មភាពនានាពីវិធីសាស្ត្រដែលក្រុម ឬផ្នែកណាមួយត្រូវអនុវត្ត ឬចូលរួមទាំងកម្លាំងកាយចិត្តដើម្បីសម្រេចតាមវត្ថុបំណងរួមរបស់អង្គភាពដែលបានដាក់ចេញ (Syndicate Room. 2020)។

- **ផែនការប្រតិបត្តិប្រចាំឆ្នាំ** ជាផែនការលំអិតថវិកាទាំងរដ្ឋ និងដៃគូទៅលើសកម្មភាពនានាដែលបានកំណត់ ដើម្បីយកមកប្រើប្រាស់ក្នុងដំណើរការសាលារៀនរយៈពេលមួយឆ្នាំសិក្សា ។

### ២.១.២. បុគ្គលិកអប់រំ

**បុគ្គលិកអប់រំ** គឺជាមន្ត្រីអប់រំដែលជាមន្ត្រីរដ្ឋបាល មន្ត្រីគ្រប់គ្រងរដ្ឋបាល លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យតាមគ្រឹះស្ថានឧត្តមសិក្សា ។ បុគ្គលិកអប់រំ គឺជាមន្ត្រីរាជការស៊ីវិលដែលបម្រើការក្នុងវិស័យអប់រំ ដោយទទួលការបណ្តុះបណ្តាលវគ្គគរុកោសល្យត្រឹមត្រូវពីក្រសួងអប់រំយុវជន និងកីឡាហើយបុគ្គលិកអប់រំ អាចជាបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន (**ក្រសួងអប់រំ យុវជន និងកីឡា២០០៧**)។

### ២.១.៣. សកម្មភាព

**សកម្មភាព** គឺជាការអនុវត្តការងារមួយ ដែលអង្គភាពឬបុគ្គលណាមួយទទួលខុសត្រូវ ។ សកម្មភាពមានទំហំធំ ឬតូចទៅតាមដែនកំណត់ដែលមានក្របខណ្ឌពេលវេលា និងថវិកាគាំទ្រ ។ សកម្មភាព

អាចជាការងារដែលត្រូវធ្វើប្រចាំថ្ងៃ ឬការងារដែលត្រូវធ្វើបន្តរហូតដល់ថ្ងៃអនាគត់ទើបចប់ ។ សកម្មភាព គឺជាស្ថានភាពដែលមានរឿងរ៉ាវជាច្រើនកើតឡើង ឬមនុស្សមានដំណើរការវិលជុំជាប្រចាំ ( Cambridge Dictionary. 2020 ) ។

### ២.១.៤. ថវិកា

**ថវិកា** គឺជាកញ្ចប់ប្រាក់សម្រាប់យកទៅប្រើប្រាស់អនុវត្តសកម្មភាពទៅតាមចំណុចដៅ ទៅតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍសាលារៀន ទៅតាមផែនការប្រតិបត្តិប្រចាំឆ្នាំ ។ ថវិកាដែលប្រើប្រាស់ត្រូវបានកំណត់ជាប្រាក់រៀលខ្មែរ ដើម្បីចាយ និងទូទាត់វិញ ។ ថវិកានៃសកម្មភាពនីមួយៗគិតជាលានរៀល ។ ថវិកា គឺជាលំហូរសាច់ប្រាក់ ការប៉ាន់ប្រមាណតម្លៃនៃចំណូល និងចំណាយក្នុងពេលអនាគត ហើយថវិកាអាចត្រូវបានប្រើប្រាស់សម្រាប់ទ្រទ្រង់ជីវិតសត្វ និងមនុស្សតាមរយៈការចាយវាយ និងការដោះដូរទៅនឹងអ្វីមួយទៀត ( Investopedia. 2020 ) ។

### ២.១.៥. ក្របខណ្ឌពេលវេលា

**ក្របខណ្ឌពេលវេលា** គឺជារយៈពេលគិតជាខែ ឬថ្ងៃនៃសកម្មភាពមួយដែលត្រូវអនុវត្តដើម្បីសម្រេចលទ្ធផល ។ ក្របខណ្ឌពេលវេលាមានការប្រែប្រួលទៅតាមតម្រូវការអនុវត្តសកម្មភាពជាក់ស្តែង ។ ឧទាហរណ៍ៈ សកម្មភាពខ្លះត្រូវបានអនុវត្តមុនកាលកំណត់ ហើយសកម្មភាពខ្លះទៀតត្រូវបានពន្យាពេលអនុវត្តដោយសារមូលហេតុអ្វីមួយដែលកើតឡើង ។ ក្របខណ្ឌពេលវេលា គឺជាកំឡុងពេលវេលា ដែលត្រូវបានកំណត់ក្នុងគោលបំណងសម្រេច សកម្មភាព ឬគម្រោងណាមួយក្នុងពេលវេលាកំណត់ច្បាស់លាស់ ( Marriam-Webster. 2020 ) ។

### ២.១.៦. ច្បាប់ហិរញ្ញវត្ថុ

**ច្បាប់ហិរញ្ញវត្ថុ** គឺជាគោលការណ៍នៃការចំណាយ និងចំណូលនៃអង្គភាពមួយ ដែលត្រូវបានកំណត់ដោយច្បាប់ ។ ច្បាប់ហិរញ្ញវត្ថុ ជាការកំណត់ ឬក្រឹតវាស់វែងពីទំហំសកម្មភាពការងារដែលត្រូវប្រើប្រាស់ថវិកា ដើម្បីធានាថាសកម្មភាពដែលត្រូវអនុវត្តស្របតាមគោលការណ៍ចំណាយ និងចំណុចដៅដែលមានចែងក្នុងគោលនយោបាយនោះ ។ គោលនយោបាយចំណាយ តែងមានភាពខុសគ្នាពីអង្គភាពមួយ

ទៅអង្គភាពមួយ អាស្រ័យលើច្បាប់ និងការបកស្រាយទៅតាមគណនេយ្យ និងអនុគណនេយ្យ ។ ឧទាហរណ៍ៈ គណនេយ្យជួសជុលមាន អនុគណនេយ្យជួសជុលប្រាសាទ និងអគារផ្សេងៗ អនុគណនី ជួសជុលសម្ភារបរិក្ខាការិយាល័យ ។ល។

**ផែនការប្រតិបត្តិប្រចាំឆ្នាំ** គឺជាផែនការគ្រោងសកម្មភាព និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ ដោយឆ្លុះបញ្ចាំងពីលទ្ធផលរំពឹងទុក និងសូចនាករសម្រាប់វាស់វែងពីកម្រិតអនុវត្ត ។ ក្នុងសម័យកាលនេះ ផែនការប្រតិបត្តិប្រចាំឆ្នាំ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ពីសកម្មភាពដែលនឹងត្រូវអនុវត្តនៅ ឆ្នាំបន្ទាប់ និងថវិកាគាំទ្រស្របតាមសកម្មភាពនីមួយៗ ដើម្បីធានាថាអាចសម្រេចបានទៅតាមលទ្ធផល ដែលបានគ្រោងទុក និងសូចនាករដៅបានជោគជ័យ ( **ក្រសួងអប់រំយុវជន និងកីឡា ២០១៩** ) ។ លើស ពីនេះទៅទៀត សកម្មភាពក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ចាំបាច់ត្រូវបន្សីជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ជាតិ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ នីតិកាលទី៦ នៃរាជរដ្ឋាភិបាល កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រថវិកា ២០១៩-២០២១ ដើម្បីធានាថាសកម្មភាព និងថវិកាដែលបានគ្រោង ស្របតាមផែនការ និងការវិវត្តនៃសេដ្ឋកិច្ច ជាតិនាពេលបច្ចុប្បន្ន ។ បើទោះបីជាយ៉ាងណាក៏ដោយ ការគ្រោងសកម្មភាព និងថវិកា និងការអនុវត្តជាក់ ស្តែងតែងតែនៅមានការខ្វះចន្លោះ ដែលទាមទារឱ្យមានការប្រៀបធៀបលទ្ធផលនៃការសិក្សាកន្លងមក និងទ្រឹស្តីមួយចំនួនដែលឆ្លុះបញ្ចាំងពីភាពជោគជ័យ ។

## ២.២ ដំណើរការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ជាចំណុចអាទិភាពមួយរបស់ក្រសួង ដើម្បីបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រង និងផ្តល់សេវាដល់អ្នកប្រើប្រាស់សេវាប្រកបដោយគុណភាព ( **ក្រសួងអប់រំយុវជន និង កីឡា ២០១៩** ) ។ ដើម្បីឱ្យការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំប្រកបដោយភាពរលូន និងមានតម្លាភាព លុះត្រាតែប្រធានអង្គភាពបែងចែកកញ្ចប់ថវិកាដោយឡែកៗសម្រាប់ការិយាល័យជំនាញនីមួយៗ ក្នុងការ អនុវត្តសកម្មភាពជំនាញរបស់ពួកគេស្របទៅតាមតួនាទីភារកិច្ច និងប្រតិទិនការងារដែលបានកំណត់ ។ ប៉ុន្តែការអនុវត្តសកម្មភាពទាំងនោះ នឹងមិនដែលសមស្របតាមក្របខណ្ឌតួនាទីភារកិច្ច និងពេលវេលា

ដែលបានគ្រោងទុកនោះទេ ពីព្រោះថវិកាដែលត្រូវអនុវត្តធ្លាក់មកមិនទាន់ពេលវេលានៃសកម្មភាពដែលបានគ្រោង ដូច្នេះហើយ ភាពយឺតយ៉ាវនៃការអនុវត្តសកម្មភាពតែងតែមាន ។ ជាមួយគ្នានេះ ប្រធានអង្គភាពត្រូវតែចេះបត់បែននូវក្របខណ្ឌពេលវេលាក្នុងការអនុវត្ត ដើម្បីធានាថាសកម្មភាពដែលបានគ្រោង និងត្រូវបានអនុវត្តដោយប្រសិទ្ធភាព និងភាពទទួលយកបានពីភាគីពាក់ព័ន្ធ ។

អង្គភាពដែលមានការរីកចម្រើន គឺមិនអាស្រ័យតែទៅលើកញ្ចប់ថវិការដ្ឋតែមួយមុខនោះទេ គប្បីចេះកៀរថវិកាពីភាគីពាក់ព័ន្ធពីសប្បុរសជននានា ពីដៃគូរអភិវឌ្ឍ រកធនធានបន្ថែមដើម្បីបំពេញកង្វះខាតផ្នែកធនធាន ( **ក្រសួងអប់រំយុវជន និងកីឡា ២០១៦** ) ។ ឧទាហរណ៍ៈ ថវិកាដៃគូ ( Sweden ) ឬហៅថាស៊ុយអ៊ែត ថវិកា School Block Grant របស់អង្គការ Unicef ដែលជួយគាំទ្រដល់ដំណើរការបង្រៀន-រៀនពីចម្ងាយតាមរយៈប្រព័ន្ធអនឡាញ ។

កាន់តែជាក់លាក់ជាងនេះ ផែនការប្រតិបត្តិប្រចាំឆ្នាំគួរមានសមាសធាតុផ្សេងទៀតចូលរួមដូចជាៈ សូចនាករផលសម្រេច និងចំណុចដៅក្នុង ESP ចំណុចដៅប្រចាំឆ្នាំ កម្មវិធីដែលមានចែងក្នុង ESP និងសកម្មភាពគោល ។ ឧទាហរណ៍ៈ សូចនាករភាគរយកុមារតូចក្នុង ESP អាយុ ៤ ឆ្នាំកើនពី៤៩.៦៥% នៅឆ្នាំ២០១៩ កើនរហូតដល់ ៥៦% នៅឆ្នាំ ២០២៣ ។ កាត់បន្ថយអត្រាបោះបង់ការសិក្សាពី ១១% ក្នុងឆ្នាំ ២០១៩ មកត្រឹម ៥% ក្នុងឆ្នាំ ២០២៣ ។ កាត់បន្ថយអត្រាត្រួតថ្នាក់ពី ៤% ក្នុងឆ្នាំ ២០១៩ មកត្រឹម ២% ក្នុងឆ្នាំ ២០២៣ ។ បង្កើនអត្រាបញ្ចប់ការសិក្សាពី ៧៩% នៅឆ្នាំ ២០១៩ ឱ្យបានដល់ ៨៥% ក្នុងឆ្នាំ ២០២៣ ។ បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមភូមិទៅមធ្យមសិក្សាឱ្យបាន ៩៥% ក្នុងឆ្នាំ ២០២៣ ( **របាយការណ៍សមិទ្ធកម្មឆ្នាំ ២០២០ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** ) ។

ប្រធានអង្គភាពដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្រេច និងដឹកនាំអនុវត្តផែនការសកម្មភាពនានា ហើយការអនុវត្តនោះត្រូវធានាថាបានអនុវត្តទៅលើសកម្មភាពជាអាទិភាព ដើម្បីបំពេញតម្រូវការចាំបាច់ជាក់ស្តែង ដោយធានាឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធគិតចាប់ពីប្រធានអង្គភាពរហូតដល់អ្នកទទួលសេវា ។ ពេលខ្លះទាមទារឱ្យមានការចូលរួមពីអាជ្ញាធរដែនដី ឬអង្គភាពថ្នាក់កណ្តាលដើម្បីដឹងឮ និង

សម្រេច ។ ជារួម ភាគីពាក់ព័ន្ធដើរតួនាទីសំខាន់ណាស់ក្នុងការអនុវត្តសកម្មភាពនីមួយៗពិសេសប្រធានអង្គភាពដែលជាបុគ្គលមានសិស្សក្នុងការសម្រេច ។

លំហូរនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលរលូនទៅបានលុះត្រាតែអនុលោមទៅតាមគោលការណ៍ច្បាប់ និងប្រកបដោយតម្លាភាព ។ ក្នុងន័យនេះមានន័យថា មន្ត្រីដែលទទួលបន្ទុកចាំបាច់ត្រូវធ្វើការសិក្សាឈ្វេងយល់ឱ្យបានគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅទៅលើបទដ្ឋានច្បាប់ សេចក្តីណែនាំព្រមទាំងធ្វើការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្តផែនការ និងអ្នកដែលទទួលផលពីផែនការនោះ ។ លើសពីនេះទៅទៀត ត្រូវមានការបិទផ្សាយពីព័ត៌មានអំពីថវិកា លំហូរថវិកា ខ្ទង់ថវិកាចំណូល-ចំណាយ ហើយប្រការទាំងនេះគឺចាំបាច់ត្រូវប្រធានអង្គភាពផ្តល់ជាគម្រូមុនគេ ។

ផែនការប្រតិបត្តិប្រចាំឆ្នាំ នៅតាមសាលាដែលមានការយឺតយ៉ាវគឺអាស្រ័យដោយស្ថានភាព ឬបញ្ហាប្រឈមជាក់ស្តែងដែលកើតមានឡើងនៃអង្គភាពនោះ ។ ឧទាហរណ៍ៈ អ្នកធ្វើផែនការ និងអ្នកអនុវត្តផែនការធ្វើការមិនស៊ីចង្វាក់គ្នា មានន័យថាអ្នកគ្រោងថវិកាផ្សេង អ្នកអនុវត្តផ្សេងដែលនាំឱ្យលទ្ធផលនៃសកម្មភាពនោះ មិនឆ្លើយតបទៅនឹងផែនការដែលបានដាក់ចេញ ឬមិនបម្រើផលប្រយោជន៍ដល់អ្នកទទួលសេវា ។

## ២.៣ ចំណុចខ្លាំង និងចំណុចខ្សោយនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់អង្គភាពនីមួយៗតែងតែមានចំណុចខ្លាំងដែលហៅថាគុណសម្បត្តិ និងចំណុចខ្សោយដែលហៅថាគុណវិបត្តិ ដែលទាំងនេះបានឆ្លុះបញ្ចាំងពីកម្រិតនៃការអនុវត្តកន្លងមករបស់អង្គភាពនោះ ។ ចំណុចខ្សោយនៃអង្គភាពមួយ គឺទៅលើបញ្ហាថវិកា ការចាយវាយមិនអស់មិនចំគោលដៅ មិនមានតម្លាភាព ឬខុសពីផែនការដែលបានគ្រោង ដែលនាំឱ្យមានភាពមិនពេញចិត្តចំពោះបុគ្គលិកដែលពាក់ព័ន្ធមួយចំនួន រីឯចំណុចខ្លាំងវិញគឺមានន័យថាអង្គភាពបានចាយវាយថវិកាចំគោលដៅ ឬទៅតាមផែនការដែលបានគ្រោង ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដោយមានតម្លាភាពគណនេយ្យភាព ។ តែទោះជាយ៉ាងណាក៏ដោយក៏ខ្ទង់ថវិកា និងសកម្មភាពដែលបានដាក់ចេញតែងមាន

ភាពលំអៀង ឬមានការយឺតយ៉ាវដោយបញ្ហាផ្សេងៗដូចជាការប្រែប្រួលនៃស្ថានភាពសង្គម ការធ្លាក់ថវិកាមានការយឺតយ៉ាវ ប៉ុន្តែភាពលំអៀងទាំងនោះត្រូវមានសង្គតិភាព និងមានតម្លាភាពចំពោះមន្ត្រីពាក់ព័ន្ធ ។

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំដែលមានការយឺតយ៉ាវអាចដោយសារប្រធានស័ក ។ ការណ៍នេះបង្ហាញពីចំណុចខ្សោយមួយដែលធ្វើឱ្យការអនុវត្តសកម្មភាពនីមួយៗមិនបានគ្រប់ជ្រុងជ្រោយ និងចប់តាមផែនការកំណត់ ។ ទោះជាយ៉ាងនេះក្តី សកម្មភាពទាំងនោះត្រូវតែស្របតាមវត្ថុបំណងនៃគោលនយោបាយ និងសម្រេចតាមគោលដៅកំណែទម្រង់វិស័យអប់រំ របស់ក្រសួងអប់រំយុវជន និងកីឡា ( **ក្រសួងអប់រំយុវជន និងកីឡា ២០១៩** ) ។ ការត្រួតពិនិត្យគោលនយោបាយដែលកំពុងអនុវត្ត និងកំណែទម្រង់វិស័យអប់រំ ជាគន្លឹះក្នុងការអនុវត្តផែនការប្រតិបត្តិ ដោយជៀសវាងការអនុវត្តប្រាស់ចាកពី គោលនយោបាយ ពិសេសផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ នៃរាជរដ្ឋាភិបាលនីតិកាល ទី៦ ។

ការរៀបចំផែនការប្រតិបត្តិដែលមានទម្រង់ និងធាតុសំខាន់ៗច្បាស់លាស់ ជាចំណុចខ្លាំងមួយអាចកំណត់សកម្មភាព ដែលត្រូវអនុវត្តបានច្បាស់ ។ ឧទាហរណ៍ៈ សមាសភាពនៃផែនការប្រតិបត្តិមានកម្មវិធី អនុកម្មវិធី សកម្មភាព សូចនាករ ចំណុចដៅប្រចាំឆ្នាំ និងប្រភពធនធានប្រើប្រាស់សម្រាប់អនុវត្តសកម្មភាព ។ បើតាមគោលការណ៍ ជំហ៊ាននៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំមានៈ ការពិនិត្យឡើងវិញនូវការចំណាយថវិការ និងលទ្ធផលបំពេញការងារតាមអនុវិស័យនាឆ្នាំសិក្សាកន្លងមក ការពិនិត្យលើគោលនយោបាយដែលក្រសួងបានដាក់ចេញ និងកំណែទម្រង់វិស័យអប់រំ ការកំណត់វត្ថុបំណងចំណុចដៅ សកម្មភាព និងផែនការចំណាយថវិកា ។ ជាងនេះទៅទៀត ចំណុចខ្លាំងដែលគួរពិចារណាកន្លងមកគឺអង្គភាពសាមីធ្វើការវិភាគចំណាយសាធារណៈសម្រាប់វិស័យអប់រំតាមកម្រិត និងប្រភេទអប់រំ ចង្កោមសកម្មភាព ការវិភាគចំណាយសម្រាប់វិស័យអប់រំផ្អែកលើប្រភពហិរញ្ញវត្ថុផ្សេងៗ និងកំណត់បានពីភាពពេញចិត្ត សមធម៌ និងសនិទានកម្មនៃការប្រើប្រាស់ធនធានមានកម្រិត និងប្រភេទផ្សេងៗក្នុងវិស័យអប់រំ ។ ហើយការវិភាគចំណាយ គួរតែគ្រប់ដណ្តប់លើស្ថានភាពនៃវិស័យអប់រំផ្អែកលើបណ្តុះសូចនាករស្នូល សូចនាករប្រចាំឆ្នាំ និងសូចនាករផលសម្រេច ។ សូចនាករសំខាន់ៗ ដែលប្រើប្រាស់សម្រាប់វាស់វែង

មានភាគរយនៃថវិកាវិស័យអប់រំ ធៀបនឹងថវិកាចំណាយសាធារណៈ ភាគរយនៃចំណាយសាធារណៈលើវិស័យសាធារណៈ និងការចំណាយសាធារណៈលើសិស្សម្នាក់ៗ ។

ចំណុចខ្លាំងនៃផែនការប្រតិបត្តិប្រចាំឆ្នាំ លុះត្រាតែផែនការនោះអនុលោមទៅតាមការណែនាំរបស់ការិយាល័យពាក់ព័ន្ធពិសេសគឺការិយាល័យផែនការ និងគ្រប់គ្រងជំនួយ នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តដែលមានវត្ថុបំណងច្បាស់លាស់ចំនួន ៦ ជាពិសេសផ្អែកលើសមាសភាពទាំង ៩ របស់សាលាកុមារមេត្រីរួមមាន ៖ (១).វត្ថុបំណងគោលនយោបាយសាលារៀន (២).ការបង្រៀន និងរៀន (៣).មាតាបិតា និងសហគមន៍ជួយការសិក្សារៀនសូត្ររបស់សិស្ស (៤). សិស្ស និងសេវាជួយសិស្ស (៥).ការដឹកនាំនិងគ្រប់គ្រង (៦).ធនធានមនុស្ស (៧).សម្ភារបង្រៀន និងរៀន (៨).កសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន (៩).កៀរគរហិរញ្ញប្បទាន និងគ្រប់គ្រងហិរញ្ញវត្ថុ (គោលការណ៍សា លាកុមារមេត្រី)

រាល់ផែនការមិនមែនមានន័យថាត្រូវអនុវត្តឱ្យបាន ១០០% នោះទេ តែគ្រប់អង្គភាពចាំបាច់ត្រូវមានផែនការ ។ តម្លាភាពនៃការប្រើប្រាស់ថវិកាកម្មវិធី ជាបញ្ហាប្រឈមដែលគណៈគ្រប់គ្រងអង្គភាពភាគច្រើនធ្លាប់បានអនុវត្តដើម្បីបម្រើដល់ផលប្រយោជន៍ក្រុមរបស់ខ្លួន ។ ចំណែកការធ្វើសវនកម្ម និងការត្រួតពិនិត្យការចាយវាយថវិកា នៅតែមានបញ្ហាដោយការឃុមឃិតពីអ្នកពាក់ព័ន្ធមួយចំនួនដូចជាគណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកផែនការ ឬអ្នកទទួលបន្ទុកហិរញ្ញវត្ថុ ឬអាចជាមួយអ្នកមកចុះធ្វើសវនកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមិនទាន់មានការសិក្សាស្រាវជ្រាវណាមួយដែលបានសិក្សាលម្អិតអំពីប្រធានបទខាងលើនោះទេនៅក្នុងប្រទេសកម្ពុជាយើង ពិសេសក្នុងខេត្តរតនគិរីតែម្តង ។

ភាពចៃដន្យអាចនឹងកើតឡើងជាយថាហេតុក្នុងករណីចាំបាច់ណាមួយ ដែលអាចធ្វើឱ្យរាំងស្ទះដល់ដំណើរការអនុវត្តសកម្មភាពប្រតិបត្តិ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ប្រធានអង្គភាពត្រូវបង្កើតផែនការជាយថាហេតុ ( Contingency Plan ) ដែលផែនការនេះអាចធានាដំណើរការនិរន្តរភាពអង្គភាពបានក្នុងករណីប្រធានស័កកើតឡើង ។ ឧទាហរណ៍ៈ បើមន្ត្រីជំនាញលើផ្នែកណាម្នាក់អវត្តមាន ឬខកខាន់មិនបានបំពេញការងារដែលបានគ្រោងទុក នោះផែនការជាយថាហេតុត្រូវកំណត់ឱ្យអ្នកដទៃធ្វើជំនួស

ដើម្បីជានាថាសកម្មភាពដែលបានគ្រោងនៅតែដំណើរការ ។ ដូចនេះ ផែនការជាយថាហេតុអាចដោះស្រាយប្រធានសក័ចាំបាច់ណាមួយបានទាន់ពេលវេលា និងផែនការ ។

រីឯចំណុចខ្សោយនៃផែនការប្រតិបត្តិ គឺជាភាពរឹងស្លូកនៃរបៀបដឹកនាំរបស់ប្រធានអង្គភាពដែលមិនចេះបត់បែនទៅលើផែនការសកម្មភាពនោះ ដែលនាំឱ្យមានការរាំងស្ទះដល់ការអនុវត្ត ។ ប្រធានអង្គភាពគួរគប្បីចេះបត់បែន ពិនិត្យទៅលើអាទិភាព ស្ថានភាព និងការលះទេសៈដោយក្នុងករណីចាំបាច់ណាមួយប្រធានអង្គភាពត្រូវនិយ័តខ្ទង់ថវិកាណាមួយដែលមិនចាំបាច់ ទៅបំពេញបន្ថែមលើផ្នែកណាដែលចាំបាច់ ។ ឧទាហរណ៍ៈ ក្នុងឆ្នាំ២០២០ កន្លងទៅនេះការអនុវត្តផែនការប្រតិបត្តិរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីបានជួបនឹងបញ្ហាប្រឈមមួយចំនួនដូចជាៈ សកម្មភាពតាមអនុវិស័យមួយចំនួន ត្រូវបានកាត់ចោលដោយសារកង្វះខាតថវិកា សកម្មភាពដែលបានគ្រោងសម្រាប់អនុវត្តតាមត្រីមាសនីមួយៗ ត្រូវបានខកខានដោយជម្ងឺរាតត្បាត ការចុះជួយសាលាអំពីការសិក្សាពីចម្ងាយមានបានទូលំទូលាយដោយកង្វះខាតថវិកា នៅការិយាល័យបឋម កុមារតូច និងការិយាល័យមធ្យម ( **របាយការណ៍សមិទ្ធកម្មឆ្នាំ ២០២០ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី**) ។

ទន្ទឹមនឹងនេះ ត្រូវបង្ហាញពីតារាងតម្លាភាពថវិកា ប្រជុំផ្សព្វផ្សាយជាសាធារណៈដល់ភាគីពាក់ ព័ន្ធមានប្រធានគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិក្សានុសិស្ស សហគមន៍ អាជ្ញាធរ ដៃគូ ជំនួយ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត អំពីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ។ មកទល់ពេលនេះ នៅមិនទាន់មានការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រណាមួយ ត្រូវបានយកមកបង្ហាញនៅឡើយទេពាក់ព័ន្ធនឹងបញ្ហាខាងលើនៅក្នុងខេត្តរតនគិរី ។

## ២.៤. តម្រូវការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុ

អ្នកអាចធ្វើជាគណៈគ្រប់គ្រងដ៏ឆ្នើម ដោយគ្មានបំពេញកិច្ចការជាអ្នកដឹកនាំដ៏ល្អ ក៏ប៉ុន្តែអ្នកមិនអាចធ្វើជាអ្នកដឹកនាំដ៏ឆ្នើម ដោយគ្មានបំពេញកិច្ចការជាគណៈគ្រប់គ្រងដ៏ល្អបានទេ " ‚ **“ You can be an excellent manager without becoming a good leader; but you cannot be an excellent leader without becoming a good manager” (Elwood N. Chapman & Sharon Lun O’Neil: 2000. p.6)**

ពិតណាស់ការងារនេះជាការទទួលខុសត្រូវរបស់មន្ត្រីផែនការ ដែលទាមទារឱ្យពួកគេមានជំនាញ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង និងរៀបចំសកម្មភាពដោយឆ្លុះបញ្ចាំងពីលទ្ធផលនៃការអនុវត្តជាក់ស្តែង ធៀបនឹងឆ្នាំកន្លងទៅ ។ ជំនាញរបស់មន្ត្រីផែនការគួរតែត្រូវបានឆ្លងកាត់វគ្គបណ្តុះបណ្តាលនូវអ្វីដែលថ្មីៗជាប្រចាំ ដើម្បីឱ្យការអនុវត្តមានសង្គតិភាព និងភាពស៊ីចង្វាក់គ្នា ។ ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញលើការងារផែនការ និងហិរញ្ញវត្ថុនៅគ្រប់ឋានានុក្រមគ្រប់គ្រង អាចបង្កើនភាពឆ្លើយតប និងគ្រប់គ្រងប្រកបដោយចីរភាព ពិសេសគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៩** ) ។ ទម្រង់ ឬបែបបទនៃការស្នើនូវថវិកា ឬប្រព័ន្ធហិរញ្ញវត្ថុ ពីមួយឆ្នាំទៅមួយឆ្នាំតែងមានការប្រែប្រួល ដែលទាមទារឱ្យអ្នកទទួលបន្ទុកមានភាពឆ្លាតវៃ និងមានគំនិតច្នៃប្រឌិតខ្ពស់ផងដែរ ។ ហេតុនេះ ការបណ្តុះបណ្តាលគួរជ្រើសរើសយកប្រធានបទពាក់ព័ន្ធការរៀបចំ ឬគ្រោងថវិកា ការរៀបចំផែនការដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាព ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៦** ) ។

លក្ខណៈសម្បត្តិសមរម្យ ចាំបាច់ត្រូវតែមានចំពោះមន្ត្រីដែលទទួលបន្ទុកកិច្ចការធ្វើផែនការ និងកិច្ចការហិរញ្ញវត្ថុ ដើម្បីឱ្យការអនុវត្តតួនាទីភារកិច្ចមានប្រសិទ្ធភាព ពិសេសកម្រិតសញ្ញាបត្របរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់លើជំនាញឯកទេសឱ្យស្របតាមគោលការណ៍ពន្លឿនរបស់ក្រសួង ។ ជាមួយគ្នានេះដែលមន្ត្រីជំនាញទាំងនោះគួរគប្បីមានជំនាញគាំទ្រដទៃទៀតដូចជាភាសាអង់គ្លេស បច្ចេកវិទ្យា និងទំនាក់ទំនងជាដើម ដែលរបកគំហើញទាំងនេះមិនទាន់ត្រូវបានស្រាវជ្រាវរកឃើញទេនៅក្នុងខេត្ត រតនគិរី ។

អ្នកដែលដើរតួនាទីជាឆ្អឹងខ្នងរបស់អង្គភាព ជាមន្ត្រីដែលទទួលបន្ទុកធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលគាត់ជាមន្ត្រីស្នូលដែលមិនអាចខ្វះបាន ព្រោះគាត់ជាអ្នកគ្រប់គ្រងថវិកា និងសកម្មភាពនានារបស់អង្គភាព ដោយហេតុគាត់ជាអ្នកដែលដឹងរាល់សកម្មភាពទាំងឡាយរបស់អង្គភាពទើបអាចគ្រោងថវិកាសម្រាប់ដំណើរការសកម្មភាពនានាបាន ។ មន្ត្រីផែនការគប្បីជាបុគ្គលដែលមានទំនាក់ទំនងល្អ រាក់ទាក់ជាមួយគ្រប់ផ្នែកពាក់ព័ន្ធ ការិយាល័យចំណុះក្នុងមន្ទីរអប់រំ ។ ហេតុនេះ ដើម្បីលើកទឹកចិត្តពួកគាត់ គណៈគ្រប់គ្រងគួរគប្បីរៀបចំឱ្យមានការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាពរបស់ពួកគាត់នៅគ្រប់កម្រិត និងឋានានុក្រមគ្រប់គ្រង ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៩** ) ។

ថវិកាផ្ទេរទេយ្យបុរេប្រទាន តាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានតាមដានដោយក្រសួងអប់រំយុវជន និងកីឡា ដែលសម្រាប់គ្រោងថវិកាដោយផ្សារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ជាមួយផែនការយុទ្ធសាស្ត្រថវិកា និងកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលប្រការនេះទាមទារឱ្យមានការបណ្តុះបណ្តាលជំនាញដល់មន្ត្រីទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងផែនការពីរបៀប និងនីតិវិធីអនុវត្ត ( **ក្រសួងអប់រំ យុវជន និងកីឡា ២០២០** ) ។ ទាំងនេះជាដំណាក់កាលថ្មីៗដែលក្រសួងបានដាក់ចេញក្នុងន័យធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលហិរញ្ញវត្ថុសាធារណៈ ដល់អ្នកពាក់ព័ន្ធដើម្បីយកទៅអនុវត្ត ។ ហេតុនេះ ការពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីដែលទទួលបន្ទុកហិរញ្ញវត្ថុស្តីពីការតម្រង់ទិស ចង្អោមសកម្មភាពអាទិភាពឱ្យស្របតាមគោលបំណង និងគោលនយោបាយរបស់ក្រសួង ត្រូវបានធ្វើឡើងជាប្រចាំ ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៩** ) ។

ទន្ទឹមនឹងនេះដែរ ការគិតគូរទៅលើការអភិវឌ្ឍធនធានមនុស្ស ជាផ្នែកមួយយ៉ាងសំខាន់ដើម្បីអាចធានាបានថាមន្ត្រីគ្រប់ផ្នែកមានសមត្ថភាពគ្រប់គ្រាន់ដើម្បីយកទៅអនុវត្តនូវតួនាទីភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដែលមុខវិជ្ជាទាំងនោះរួមមាន៖ ការធ្វើផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ ផែនការគ្រោងថវិកា ការគ្រោងសកម្មភាពប្រចាំឆ្នាំ បទដ្ឋានគតិយុត្តិពាក់ព័ន្ធច្បាប់ហិរញ្ញវត្ថុ និងកិច្ចការរដ្ឋបាលជាដើម ។

បញ្ហាប្រឈមដែលរាំងស្ទះដល់ការងារនៅក្នុងអង្គភាពនីមួយៗមានច្រើនរឿង ច្រើនទម្រង់ ។ ប៉ុន្តែដើម្បីអាចដឹងបានថាបញ្ហាទាំងអស់នោះបណ្តាលមកពីបញ្ហាអ្វី គឺវិធីការវាយតម្លៃពីតម្រូវការ ដែលគេហៅថា ( Needs Assessment ) គួរត្រូវបានយកមកប្រើប្រាស់ ។ ក្នុងន័យនេះបានន័យថា ប្រសិនបើលទ្ធផលនៃការវាយតម្លៃពីតម្រូវការចង្អុលបង្ហាញថាបញ្ហាទាំងនោះបណ្តាលមកពីកត្តាមនុស្ស នោះការរៀបចំផែនការក្នុងការបណ្តុះបណ្តាលគួរត្រូវបានរៀបចំ ដើម្បីស្វែងរកដំណោះស្រាយ និងបំពេញចន្លោះខ្វះខាតទាំងនោះ ។ ក្រោយពីកំណត់ថាការបណ្តុះបណ្តាលជាដំណោះស្រាយហើយ ការវិភាគពីតម្រូវការ( Needs Analysis ) មួយគួរធ្វើឡើងដើម្បីរកឬសគល់នៃបញ្ហាឱ្យកាន់តែជាក់លាក់ ។ លទ្ធផលនៃការវិភាគពីតម្រូវការមាន ៣ ផ្នែកគឺ៖ (១). បុគ្គលិករូបនោះខ្វះចំណេះដឹង គឺមានន័យថា បុគ្គលិករូបនោះមិនដឹងថាតើត្រូវធ្វើអ្វី ដើម្បីបំពេញការងារឱ្យបានប្រសើរទៅតាមស្តង់ដាកំណត់ (២). បុគ្គលិករូបនោះមិន

មានជំនាញជាក់លាក់ដើម្បីបំពេញការងារ មានន័យថាគាត់មិនដឹងពីរបៀបបំពេញការងារឱ្យមានលក្ខណៈប្រសើរតាមស្តង់ដាកំណត់ និង (៣). បុគ្គលិករូបនោះខ្វះបម្រុងប្រយ័ត្ន និងសម្បទាខាងផ្លូវចិត្ត មានន័យថាគាត់មិនដឹងពីរបៀបបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ក្នុងន័យនោះ មិននឹងសម្រេចជ្រើសការបណ្តុះបណ្តាលណាមួយដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម នៃការបំពេញការងារតាមគោលការណ៍ជាប្រព័ន្ធគួរត្រូវបានពិចារណាក្នុងការអនុវត្ត ដើម្បីស្វែងរកឬសគល់នៃបញ្ហា ដែលគោលការណ៍នេះមិនទាន់ត្រូវបានអនុវត្តបានទូលំទូលាយនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ។ តួយ៉ាងដូចជា តើត្រូវធ្វើដូចម្តេចទើបដឹងថាមន្ត្រីទទួលបន្ទុកកិច្ចការផែនការ និងហិរញ្ញវត្ថុរបស់អង្គភាពនីមួយៗត្រូវការការបណ្តុះបណ្តាលបន្ថែម ហើយតើគាត់ត្រូវការការបណ្តុះបណ្តាលជំនាញចាំបាច់អ្វីបន្ថែមឬទេ ដើម្បីជំរុញប្រសិទ្ធភាពការងាររបស់គាត់ឱ្យស្របតាមលក្ខណៈស្តង់ដាកំណត់ ?

## ២.៥. លទ្ធផលនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ

ការដែលអនុវត្តនូវផែនការប្រតិបត្តិប្រចាំឆ្នាំសម្រេចតាមផែនការកំណត់ អាចឆ្លុះបញ្ចាំងពីលទ្ធផលនៃការអនុវត្តដើម្បីគ្រោងសកម្មភាព និងថវិកាសម្រាប់ឆ្នាំបន្តបន្ទាប់ដោយប្រសិទ្ធភាព ។ ក្នុងន័យនេះ លទ្ធផលសំដៅដល់ភាគរយនៃការអនុវត្តសកម្មភាពលើថវិកាទាំងមូលដែលបានគ្រោង ។ មិនមានស្ថាប័ន ឬអង្គភាពណាមួយដែលអនុវត្តសកម្មភាពសម្រេចបាន ១០០% នោះទេ តែងតែជួបប្រទះនូវបញ្ហាប្រឈមនានា ដែលទាមទារឱ្យមានការធ្វើបុរេប្រទាន ឬបង្វែរថវិកាទៅសកម្មភាពដែលមិនបានគ្រោង ឬ បង្វែរថវិកាជូនរដ្ឋវិញ ។ ដោយឡែក ចំពោះអង្គភាពណាដែលអនុវត្តផែនការបានក្រោម ៥០% មានន័យថាអង្គភាពនោះគ្រោងថវិកាមិនស៊ីគ្នាជាមួយស្ថានភាពនៃតម្រូវការរបស់អង្គភាព ឬដោយប្រការណាមួយពាក់ព័ន្ធអ្នកគ្រោង និងអ្នកអនុវត្ត ។ ដូចនេះ ដើម្បីសម្រេចបានចំណុចអាទិភាពរបស់ក្រសួង ក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបានជោគជ័យលុះត្រាតែ បញ្ហាប្រឈមខាងលើត្រូវបានដោះស្រាយ ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៦** ) ដែលកន្លងមកមិនទាន់មានការស្រាវជ្រាវបែបវិទ្យាសាស្ត្រណាមួយត្រូវបានបង្ហាញនៅឡើយទេ អំពីការអនុវត្តផែនការប្រតិបត្តិ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។

ជាក់ស្ដែងមន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីបានអនុវត្តសកម្មភាពក្នុងឆ្នាំ ២០២០ បានចំនួនតែ ១០៦ សកម្មភាពប៉ុណ្ណោះលើសកម្មភាពសរុបប្រចាំឆ្នាំ មានចំនួន ១២៩ ស្មើនឹង ៨២.១៨% ហើយសកម្មភាពដែលអនុវត្តមិនបានមានចំនួន ២៣ សកម្មភាព ស្មើនឹង ១៧.៨២% ការណ៍ដែលសកម្មភាពចំនួន ២៣ មិនត្រូវបានអនុវត្តដោយហេតុសកម្មភាពនោះត្រូវបានកាត់ថវិកា ២៥% ចេញដែលនាំឱ្យកង្វះថវិកា និងសកម្មភាពខ្លះមានថវិកាតែមិនអាចអនុវត្តបានដោយសារការរីករាលដាល់នៃជម្ងឺកូវីដ-១៩ **( របាយការណ៍សមិទ្ធកម្ម ប្រចាំឆ្នាំ ២០២០ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី )** ។

លទ្ធផលការអនុវត្តគឺឆ្លុះបញ្ចាំងឬជាកញ្ចក់សម្រាប់បញ្ចាំងពីការធ្វើផែនការសម្រាប់ឆ្នាំបន្ត បន្ទាប់ ។ ក្រសួងអប់រំយុវជន និងកីឡាពង្រឹងប្រសិទ្ធភាពនៃការរៀបចំផែនការថវិកាតាមអង្គភាពជំនាញ នីមួយៗ ដើម្បីធានាថា ផែនការសកម្មភាពទាំងនោះសមស្របទៅតាមសកម្មភាពដែលបានគ្រោងទុកក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ២០១៩-២០២៣ ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៩** ) ។

## ២.៦. ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ

ទោះបីប្រទេសកម្ពុជាបានជួបនូវវិបត្តិនៃការរីករាលដាលជម្ងឺកូវីដ-១៩ រហូតឈានដល់បិទសាលាទូទាំងប្រទេសក្នុងដំណាក់កាលទី១ ដំណាក់កាលទី២ និងដំណាក់កាលទី ៣ ប៉ុន្តែក្រសួងក៏ដូចជាមន្ទីរអប់រំយុវជន និងកីឡាខេត្តបានបន្តខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់សុធន្ទះរួមកម្លាំងគ្នាឱ្យមានការបង្រៀន-រៀនពីចម្ងាយតាមប្រព័ន្ធអនឡាញ និងមានភាពបត់បែនទៅតាមស្ថានភាពនៃសាលានីមួយៗ

ការគ្រោងថវិកាប្រចាំឆ្នាំត្រូវតែបន្សីគ្នាទៅនឹងគោលនយោបាយអប់រំ ដែលជាការបង្កើនប្រសិទ្ធភាពនៃការអនុវត្តសកម្មភាព ( **ក្រសួងអប់រំយុវជន និងកីឡា ២០១៩** ) ។

ប្រសិទ្ធភាពសំដៅលើការអនុវត្ត តាមគោលការណ៍ ៩ យ៉ាងគឺ៖ (១). ការចូលរួម (២). នីតិរដ្ឋ (៣). តម្លាភាព (៤). ការព្រមព្រៀង និងឯកភាព (៥). សមធម៌ (៦). ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ (៧). គណនេយ្យភាព (៨). ការឆ្លើយ តប និង (៩). ចក្ខុវិស័យជាយុទ្ធសាស្ត្រ **( អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ឆ្នាំ ២០១០ )** ។ ក្នុងន័យនេះ ក្រសួងពង្រឹងគុណភាពនៃគោលនយោបាយអប់រំ និងប្រព័ន្ធគ្រប់គ្រងផែនការឱ្យស្របទៅនឹងផែនការថវិកានៅគ្រប់ឋានានុក្រមគ្រប់គ្រង ( **ក្រសួងអប់រំយុវជន និង**

**កីឡា ២០១៩** ) ។ ដូចនេះ ការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់មន្ទីរ អាចជួយបំពេញចំណុចខ្វះចន្លោះ និងសម្រេចអាទិភាពនៃថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ( **ក្រសួងអប់រំ យុវជន និងកីឡា ២០១៩** ) ។

ដោយអនុវត្តតាមគោលការណ៍ច្បាប់ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តិ ក្រសួងបានណែនាំសាលា និងមន្ទីរអប់រំទាំងអស់ពីនីតិវិធី និងបែបបទនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីធានាប្រសិទ្ធភាព និងភាពឆ្លើយតប ( **ក្រសួងអប់រំយុវជន និងកីឡា ២០២០** ) ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពកម្មវិធី និងប្រើប្រាស់ថវិកាបានចំគោលដៅក្រសួងអប់រំយុវជន និងកីឡាបានធ្វើកំណែទម្រង់ ១៥ ចំណុចដែលក្នុងនោះការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជនជាចំណុចអាទិភាពមួយដែលមានសកម្មភាពជាច្រើនគាំទ្រ ។ ផែនការសកម្មភាពទាំងនេះសំដៅលើការរៀបចំយន្តការ និងក្របខណ្ឌពេលវេលាដើម្បីសម្រេចចំណុចដៅ ឬសូចនាករស្នូលដោយប្រើប្រាស់ធនធានគាំទ្រ ។

ការរៀបចំប្រតិបត្តិប្រចាំឆ្នាំដែលមានប្រសិទ្ធភាព គួរតែតម្រង់ឆ្ពោះទៅរកសរសរស្តម្ភទាំង ៥ នៃកម្មវិធីកំណែទម្រង់វិស័យអប់រំ រួមមាន៖ (១). ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២). ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា (៣). ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤). ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និង(៥). ការកែទម្រង់ឧត្តមសិក្សា ។ សកម្មភាពនៃផែនការប្រតិបត្តិត្រូវឆ្លុះបញ្ចាំងពីសរសរស្តម្ភនីមួយៗដើម្បីបង្ហាញពីភាពស្របគ្នា ។ ឧទាហរណ៍ៈ គោលការណ៍ក្រសួង ដើម្បីសម្រេចនូវចក្ខុវិស័យខាងលើ ក្រសួងអប់រំយុវជនបានកំណត់គោលនយោបាយអប់រំចំនួន ២ គឺៈ គោលនយោបាយទី១៖ ធានាឱ្យការអប់រំមាន គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ឯគោលនយោបាយទី២ ៖ ធានាភាពស័ក្តសិទ្ធិ នៃភាពជាអ្នកដឹកនាំគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។ ដូចនេះ ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំគឺចាំបាច់ត្រូវបន្សុីគ្នារវាងគោលនយោបាយដែលពាក់ព័ន្ធ និងសកម្មភាពដែលត្រូវអនុវត្ត ។

ការរៀបចំផែនការប្រតិបត្តិដែលមានប្រសិទ្ធភាព មានន័យថាលទ្ធផលដែលបានអនុវត្តអាចឱ្យយើងដឹងបានថាយើងដើរដល់ណា ដើរបានយូរប៉ុណ្ណាហើយ អ្នកណាជាអ្នកអនុវត្ត អ្នកណាជាអ្នកទទួលផល សម្រេចបានអ្វីខ្លះ ព្រោះផែនការសកម្មភាពជាការកំណត់នូវទិសដៅដែលត្រូវដើរ ពេលវេលាដែលត្រូវដើរទៅតាមវិធីសាស្ត្រណាដែលងាយ ចំណេញពេល ចំណេញធនធានមិនឱ្យខ្ជះខ្ជាយ ។ ហេតុនេះប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ វាអាស្រ័យទាំងស្រុកលើប្រសិទ្ធភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងការគ្រោងធនធានបម្រុងសម្រាប់ប្រើប្រាស់បានសមស្រប ។ ការណ៍នេះ នៅមិនទាន់មានការស្រាវជ្រាវបែបវិទ្យាសាស្ត្រណាមួយ ត្រូវបានសិក្សានៅឡើយទេអំពីបេកគំហើញមួយនេះ ពាក់ព័ន្ធមន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្ដីពី " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " មានគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត ថាតើឆ្លើយតបទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលបានដាក់ចេញកម្រិតណា និងដើម្បីរកដំណោះស្រាយដែលមានប្រសិទ្ធភាពនានា ក្នុងការជួយជម្រុញឱ្យការអនុវត្តការងារមន្ទីរអប់រំខេត្តកាន់តែមានលក្ខណៈល្អប្រសើរជាងមុន ។ រីឯវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ និងតាមបែបគុណវិស័យ ។

## ៣.១ គម្រោងវិភាគ (Analysis Plan)

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ សម្រាប់ធ្វើការសម្ភាសន៍ប្រមូលទិន្នន័យដោយផ្ទាល់ទាំងតាមបែបបរិមាណវិស័យ និងបែបគុណវិស័យ ទៅតាមចំនួន និងផែនការនៃការដែលបានគ្រោងទុក និងស្របទៅតាមផែនការនៃការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សាព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី **១៤ ខែវិច្ឆិកា ឆ្នាំ២០២១** តាមផែនការគ្រោងទុក ។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅមធ្យមសិក្សាទុតិយភូមិចំនួន ១០ ក្នុងខេត្តរតនគិរី និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន ៦ ប្រភេទគឺៈ

### ក. វិធីសាស្ត្របរិមាណវិស័យ (Quantitative Research Design)៖

ប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀន ប្រធាន-អនុប្រធានការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក ប្រធាន-អនុប្រធានការិយាល័យចំណុះមន្ទីរអប់រំខេត្តការប្រើប្រាស់កម្រសំណួរដើម្បីចុះប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធដែលកម្រងសំណួរចែកចេញជា ៣ ផ្នែក ៖

- ផ្នែកទី ១ ៖ ព័ត៌មានទូទៅ ( ប្រជាសាស្ត្រ )

- ផ្នែកទី ២ ៖ ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន
- ផ្នែកទី ៣ ៖ បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន

**ខ. វិធីសាស្ត្រគុណវិស័យ (Qualitative Research Design)៖**

ប្រើប្រាស់សំណួរសម្រាប់សម្ភាសន៍ ពីអ្នកចូលរួមផ្តល់ទិន្នន័យគុណវិស័យ រួមមាន៖ ១) ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត ២) មន្ត្រីនៅនាយកដ្ឋានផែនការ ៣) ដៃគូអភិវឌ្ឍ ។ ការរៀបចំសំណួរក្នុងការសម្ភាសន៍ គឺផ្សារភ្ជាប់សូចនាករដែលបានប្រើប្រាស់ក្នុងការប្រមូលទិន្នន័យបរិមាណវិស័យផងដែរ ដើម្បីផ្ទៀងផ្ទាត់រវាងតម្លៃមធ្យមភាគពិន្ទុដែលទទួលបាន និងទស្សនៈនៃការយល់ឃើញលើគោលគំនិតសំខាន់ៗដើម្បីលើកយកមកពិភាក្សា ។ ការប្រើប្រាស់កម្រសំណួរសម្ភាសន៍ដើម្បីចុះប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធដែលកម្រងសំណួរនោះចែកចេញជា ៣ ផ្នែក ៖

- ផ្នែកទី ១ ៖ ព័ត៌មានទូទៅ ( ប្រជាសាស្ត្រ )
- ផ្នែកទី ២ ៖ ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវ ជន និងកីឡាខេត្តរតនគិរី
- ផ្នែកទី ៣ ៖ បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវ ជន និងកីឡាខេត្តរតនគិរី

ទាំង ៣ ផ្នែក ខាងលើប្រើកម្រងសំណួរដើម្បីធ្វើការសម្ភាសន៍ ដោយការកត់ត្រា ការថតសម្លេងដោយប្រើមធ្យោបាយ ការសម្ភាសន៍តាមទូរស័ព្ទ តាម Google Meet និងតាមកម្ម វិធី Zoom ។

### ៣.១.១ ការសិក្សាស្រាវជ្រាវតាមបរិមាណវិស័យ

#### ៣.១.១.១ ទំហំសំណាក និងការធ្វើសំណាក (Sample Size and Sampling Technique)

ប្រមូលទិន្នន័យពីសាលាមធ្យមទាំង ១០ ក្នុងមួយសាលា ៣ នាក់ ស្មើនឹង ៣០ នាក់ មន្ត្រីការិយាល័យអប់រំស្រុកទាំង ៩ ក្នុងមួយការិយាល័យ ៣ នាក់ ស្មើនឹង ២៧ នាក់ មន្ត្រីការិយាល័យនៃមន្ទីរអប់រំយុវជន និងកីឡាខេត្តទាំង ៨ ការិយាល័យ ក្នុងមួយការិយាល័យ ៣ នាក់ ស្មើនឹង ២៤ នាក់

ប្រមូលទិន្នន័យពីប្រធានមន្ទីរ/អនុប្រធានចំនួន ០៣ រូប ប្រមូលទិន្នន័យពីមន្ត្រីនាយកដ្ឋានផែនការចំនួន ០៣ រូប ប្រមូលទិន្នន័យពីអ្នកជំនាញធ្វើផែនការសាលារៀនចំនួន ០៣ រូប ។

ការវិភាគទិន្នន័យសិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥ កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

ស្ថានភាពនៅពេលចុះប្រមូលទិន្នន័យគឺ ឋិតក្នុងបរិបទនៃការរក្សាគម្លាតសង្គម ដោយសារជំងឺកូវីដ-១៩។ រតនគិរីជាខេត្តមួយស្ថិតនៅភូមិភាគឥសាន្ត ដែលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ទៅកាន់ទីរួមស្រុកមួយចំនួនពិបាកក្នុងការធ្វើដំណើរខែប្រាំងដីហុយខ្លាំង ឯខែវស្សារអិល ស្ថានភាពនៃទីតាំងភូមិសាស្ត្រសាលារៀនមានភាពខុសៗគ្នា ។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសក្រុង/ស្រុកចំនួន ៨ក្នុងខេត្តរតនគិរី គឺ៖ ក្រុងបានលុង ស្រុកអូរជុំ ស្រុកលំផាត់ ស្រុកកូនមុំ ស្រុកបរកែវ វឺនសៃ អណ្ដូងមាស និងស្រុកអូរយ៉ាដាវ ។ ការចុះប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរទៅលើគណៈគ្រប់គ្រងសាលាមធ្យមសិក្សាទុតិយភូមិចំនួន ១០ មានសំណាកសរុបចំនួន ៣០ នាក់ មន្ត្រីការិយាល័យអប់រំស្រុកទាំង ៩ ក្នុងមួយការិយាល័យ ៣ នាក់ ស្មើនឹង ២៧ នាក់ មន្ត្រីការិយាល័យនៃមន្ទីរអប់រំយុវជន និងកីឡាខេត្តទាំង ៨ ការិយាល័យ ក្នុងមួយការិយាល័យ ៣ នាក់ ស្មើនឹង ២៤ នាក់ ប្រមូលទិន្នន័យពីប្រធានមន្ទីរ/អនុប្រធានចំនួន ០៣ រូប ប្រមូលទិន្នន័យពីមន្ត្រីនាយកដ្ឋានផែនការចំនួន ០៣ រូប ប្រមូលទិន្នន័យពីអ្នកជំនាញធ្វើផែនការសាលារៀនចំនួន ០៣ រូប ។

**តារាង៣.១ ៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំនួរ ( បរិមាណវិស័យ )**

| **សាលារៀន** | | | |
|---|---|---|---|
| **ល.រ** | **ឈ្មោះវិទ្យាល័យ** | **ស្រុក** | **ចំនួនគណៈគ្រប់គ្រងដែលត្រូវធ្វើសម្ភាសន៍** |
| ១ | វិទ្យាល័យ សម្ដេចឪ សម្ដេចម៉ែ | បានលុង | ៣ |
| ២ | វិទ្យាល័យ ហ៊ុន សែន ភូមិថ្មី | បានលុង | ៣ |

| | | | |
|---|---|---|---|
| ៣ | វិទ្យាល័យអន្តេវាសិកដ្ឋានក្រុងបានលុង | បានលុង | ៣ |
| ៤ | វិទ្យាល័យ ប៊ូ ថង អូរជុំ | អូរជុំ | ៣ |
| ៥ | វិទ្យាល័យវីរៈជ័យ | វ៉ឺនសៃ | ៣ |
| ៦ | វិទ្យាល័យ លំផាត់ | លំផាត់ | ៣ |
| ៧ | វិទ្យាល័យ ត្រពាំងក្រហម | កូនមុំ | ៣ |
| ៨ | វិទ្យាល័យ បរកែវ | បរកែវ | ៣ |
| ៩ | វិទ្យាល័យ អូរយ៉ាដាវ | អូរយ៉ាដាវ | ៣ |
| ១០ | វិទ្យាល័យអណ្ដូងមាស | អណ្ដូងមាស | ៣ |
| **សរុប** | | | ៣០ |

**ការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក**

| **ល.រ** | **បរិយាយ** | **ក្រុង/ស្រុក** | **ចំនួនគ្រូវសម្ភាសន៍** |
|---|---|---|---|
| ១ | មន្ត្រីការិយាល័យអប់រំយុវជន និងកីឡា | បានលុង | ៣ |
| | | អូរជុំ | ៣ |
| | | វ៉ឺនសៃ | ៣ |
| | | លំផាត់ | ៣ |
| | | កូនមុំ | ៣ |
| | | បរកែវ | ៣ |
| | | អូរយ៉ាដាវ | ៣ |
| | | អណ្ដូងមាស | ៣ |
| **សរុប** | | | **២៤** |

**ការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្ត**

| ល.រ | ឈ្មោះការិយាល័យ | ចំនួន |
|---|---|---|
| ១ | បឋមសិក្សា និងមតេយ្យ | ៣ |
| ២ | មធ្យមសិក្សាចំណេះទូទៅ | ៣ |
| ៣ | អប់រំក្រៅប្រព័ន្ធ | ៣ |
| ៤ | រដ្ឋបាលបុគ្គលិក និងបណ្តុះបណ្តាល | ៣ |
| ៥ | ផែនការ និងគ្រប់គ្រងជំនួយ | ៣ |
| ៦ | យុវជន និងកីឡា | ៣ |
| ៧ | គណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ | ៣ |
| ៨ | អធិការកិច្ច | ៣ |
| **សរុប** | | **២៤** |

### ៣.១.១.២ ឧបករណ៍សម្រាប់ការស្រាវជ្រាវ (Research Instrument)

ការសិក្សាស្រាវជ្រាវលើ" **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " អ្នកសិក្សាស្រាវជ្រាវ ប្រើប្រាស់កម្រងសំណួរចំនួន ៤ ប្រភេទ ក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ និងបែបគុណវិស័យពីគណៈគ្រប់គ្រងសាលារៀន មន្ត្រីការិយាល័យអប់រំយុវជន និងកីឡាស្រុក មន្ត្រីការិយាល័យចំណុះមន្ទីរអប់រំខេត្ត ប្រធាន/អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ អ្នកជំនាញធ្វើផែនការសាលារៀន ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានាដែលមានដូចជា៖ ការអនុវត្តកម្មវិធីសិក្សាស្តង់ដាទាំង ៩ របស់នាយកសាលារៀន របាយការណ៍សន្និបាតឆ្នាំ២០២០ សៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ កម្មវិធីសិក្សាពលរដ្ឋពេញលេញ និងការធានាគុណភាពអប់រំជាដើម ស្វែងយល់ពីស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត ថាតើឆ្លើយតបទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំដែលបានដាក់ចេញកម្រិតណា និងដើម្បីរកដំណោះស្រាយដែលមានប្រសិទ្ធភាពនានា ក្នុងការជួយជម្រុញឱ្យការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំកាន់តែមានលក្ខណៈល្អប្រសើរជាងមុន ។

### ៣.១.១.៣ កម្រិតចង្កុលបង្ហាញ

កម្រិតចង្កុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្កុលបង្ហាញ អាចបំពេញដោយផ្ទាល់នៅលើកម្រងសំណួរកំឡុងពេលចុះប្រមូលទិន្នន័យ ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្កុលបង្ហាញចំនួន ៥ កម្រិត។ តួលេខចង្កុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្តប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ ។ តួលេខចង្កុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករវាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការអនុវត្តសកម្មភាព ទៅតាមផែនការរបស់អ្នកពាក់ព័ន្ធ ។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្កុលបង្ហាញនៃកម្រងសំណួរនីមួយៗ មានចំនួន ៥ កម្រិតពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥) ។

រូបមន្តនៃកម្រិតចង្កុលបង្ហាញមានដូចខាងក្រោម៖

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ ពុំមានយោបល់

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើ ពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best. 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត - ពិន្ទុទាបបំផុត}}{\text{លេខរៀងនៃកម្រិត}} = \frac{៥ - ១}{៥} = \frac{៤}{៥} = 0.៨0$$

| | | |
|---|---|---|
| 1.00 — 1.80 | មានន័យថា | ខ្សោយខ្លាំង |
| 1.81 — 2.60 | មានន័យថា | ខ្សោយ |
| 2.61 — 3.40 | មានន័យថា | មធ្យម |

| | | |
|---|---|---|
| 3.41 — 4.20 | មានន័យថា | ល្អ |
| 4.21 — 5.00 | មានន័យថា | ល្អណាស់ |

### ៣.១.១.៤ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តផែនការសកម្មភាព ថាតើឆ្លើយតបទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំដែលបានដាក់ចេញកម្រិតណា និងដើម្បីរកដំណោះស្រាយដែលមានប្រសិទ្ធភាពនានា ក្នុងការជួយជម្រុញឱ្យការអនុវត្តសកម្មភាព កាន់តែមានលក្ខណៈល្អប្រសើរជាងមុន ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគ ប្រៀបធៀប កែលម្អ និងលើកកម្ពស់ប្រសិទ្ធនៃការអនុវត្តផែនការប្រតិបត្តិរបស់មន្ទីរអប់រំខេត្ត កាន់តែទទួលបានលទ្ធផលល្អប្រសើរ ។ ហើយទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

**កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន ប្រធាន-អនុប្រធាន ការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក ប្រធាន-អនុប្រធានការិយាល័យចំណុះមន្ទីរអប់រំខេត្ត ចែកជា ៣ ផ្នែក ៖**

» ផ្នែកទី ១ ៖ មាន ៧ សំណួរ តួនាទី បម្រើការងារនៅ ភេទ អាយុ កម្រិតវប្បធម៌ មុខជំនាញឯកទេស និងបទពិសោធន៍ការងារ ។

» ផ្នែកទី ២ ៖ ផ្តោតលើ ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន មានសូចនាករគោលចំនួន ៧ គឺ(ក) ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ (ខ) ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន (គ) ចូលរួមសកម្មភាពលើការងារបង្រៀន និងរៀន (ឃ) កសាងធន ធានសមត្ថភាពគ្រូ និងសេវាជួយសិស្ស (ង) កសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន (ច) កៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ (ឆ) មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស

» ផ្នែកទី ៣ ៖ ផ្ដោតទៅលើ បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន មានសូចនាករគោលចំនួន ៤ គឺ (ក) ការកំណត់គោលនយោបាយអប់រំ (ខ) ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ (គ) ការអនុវត្តផែនការ (ឃ) ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង

### ៣.១.១.៥ ការប្រមូលទិន្នន័យតាមបរិមាណវិស័យ (Data Collection Procedure)

ការប្រមូលទិន្នន័យសម្រាប់កិច្ចការស្រាវជ្រាវលើប្រធានបទ គឺអ្នកសិក្សាស្រាវជ្រាវត្រូវបានទទួលលិខិតអនុញ្ញាតផ្លូវការសម្រាប់ការចុះប្រមូលទិន្នន័យ នៅតាមសាលាគោលដៅនៃគម្រោងស្រាវជ្រាវ រៀបចំដោយវិទ្យាស្ថានជាតិអប់រំ មានរយៈពេល១ខែសម្រាប់ការចុះប្រមូលទិន្នន័យនៅតាមសាលា ការិយាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំខេត្ត ស្ថិតនៅក្នុងខេត្តរតនគិរី ។ អ្នកសិក្សាស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមដែលបានចេញដោយវិទ្យាស្ថានជាតិអប់រំ ទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំចំណាងកកាពក្នុងការបំពេញភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់មន្ទីរអប់រំខេត្ត និងការងារសម្របសម្រួលផ្សេងៗ ។ បន្ទាប់មកទៀត អ្នកសិក្សាស្រាវជ្រាវបានយកលិខិតឧទ្ទេសនាម ជូននាយក ឬគណៈគ្រប់គ្រងសាលារៀន ក្រុង/ស្រុក និងការិយាល័យចំណុះមន្ទីរ ដើម្បីស្នើសុំកិច្ចសហការក្នុងការចុះប្រមូលទិន្នន័យ និងការងារចាំបាច់ផ្សេងៗ ។ ការចុះប្រមូលទិន្នន័យ គឺអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យ ។

### ៣.១.១.៦ ការវិភាគទិន្នន័យតាមបរិមាណវិស័យ (Data Analysis)

កម្រងសំណួរដែលប្រមូលបានពីក្រុមគោលដៅក្នុងការផ្ដល់ទិន្នន័យ ត្រូវបានយកមករៀបចំតាមផ្នែកសម្រាប់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបរិមាណវិស័យ ។ ការវិភាគទិន្នន័យដោយផ្ដោតសំខាន់ទៅលើៈ (១) មធ្យមភាគពិន្ទុ (Mean) និង (២) តម្លៃគម្លាតស្ដង់ដា (Standard Deviation) ។ សំណួរស្រាវជ្រាវទី ១ គឺវិភាគទៅលើកម្រងសំណួរដែលផ្ដោតសំខាន់ទៅលើសូចនាករគន្លឹះទាំង ៧ នៃប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន និងសំណួរស្រាវជ្រាវទី២ គឺបញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀនដោយផ្ដោតសំខាន់ទៅលើសូចនាករគន្លឹះទាំង ៤ ។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរដែលមានលក្ខណៈជាពហុជ្រើសរើសទៅតាមកម្រិតចង្អុល

បង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីមធ្យមភាគពិន្ទុ និងគម្លាតស្តង់ដា ។

### ៣.១.២ ការសិក្សាស្រាវជ្រាវតាមគុណវិស័យ

ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវ កាន់តែមានសង្គតិភាព និងឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សា ទិន្នន័យគុណវិស័យត្រូវបានរៀបចំប្រមូលបន្ថែម ដើម្បីផ្ទៀងផ្ទាត់ទៅលើលទ្ធផលនៃមធ្យមភាពពិន្ទុដែលទទួលបានពីទិន្នន័យបរិមាណវិស័យ និងបានឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃពីគ្រូដឹកនាំ។ អ្នកស្រាវជ្រាវបានរៀបចំការសម្ភាសន៍ (semi-structured interview) ជាមួយអ្នកចូលរួមពី ៣ ស្ថាប័ន ចំនួន ៧ នាក់។ សំណួរសម្ភាសន៍មានទម្រង់ជាសំណួរបើក ដើម្បីសួរទៅភាគីអ្នកចូលរួមសម្ភាសន៍ផ្តល់ទិន្នន័យតាមរយៈបទពិសោធន៍ បើកកិច្ចពិភាក្សា និងវិភាគស៊ីជម្រៅទៅលើបញ្ហាដែលបានកើតមានឡើងលើប្រធានបទដែលយកមកសិក្សា ។ ការសម្ភាសន៍គឺប្រើប្រាស់ភាសាខ្មែរជាគោល នៅក្នុងកិច្ចសម្ភាសន៍។ ជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវបានប្រើប្រាស់ការសង្កេត (Observation protocol) ក្នុងពេលធ្វើការសម្ភាសន៍ផងដែរ ។

#### ៣.១.២.១ អ្នកចូលរួមសម្ភាសន៍ (Key informants)

អ្នកចូលរួមក្នុងកិច្ចសម្ភាសន៍មានចំនួន ៧ នាក់ (ស្រី ២ នាក់) ទៅលើក្រុមគោលដៅចំនួន ៣ គឺ៖ (១). ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត (២). មន្រ្តីនៃនាយកដ្ឋានផែនការ (៣). ដៃគូអភិវឌ្ឍ ។ អ្នកស្រាវជ្រាវបានជ្រើសរើសអ្នកចូលរួមទៅតាមលក្ខខណ្ឌកំណត់ និងមានគោលបំណងច្បាស់លាស់ (Purposive Sampling) ដោយផ្តោតលើចំណេះដឹង និងបទពិសោធន៍ការងារក្នុងវិស័យអប់រំ ។

**តារាង៣.៣ ៖ អ្នកចូលរួមផ្តល់សម្ភាសន៍**

| ល.រ | ការិយាល័យ/ស្ថាប័ន | ទីតាំង | ចំនួនត្រូវធ្វើសម្ភាសន៍ |
|---|---|---|---|
| ១ | នាយកដ្ឋានផែនការ | ភ្នំពេញ | ៣ |
| ២ | អ្នកជំនាញធ្វើផែនការសាលារៀន | ភ្នំពេញ | ២ |

| | | | |
|---|---|---|---|
| ៣ | ប្រធាន/អនុប្រធានមន្ទីរអប់រំខេត្ត | រតនគិរី | ២ |
| សរុបរួម | | | ០៧ នាក់ |

**៣.១.២.២ នីតិវិធីនៃការសម្ភាសន៍** ( Interview protocol )

អ្នកស្រាវជ្រាវប្រើសំណួរសម្ភាសន៍ សម្រាប់សំណួរស្រាវជ្រាវទី ១ ដែលមានសំណួរគាំទ្រសរុបចំនួន ១០ ដោយផ្តោតទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ សំណួរសម្ភាសន៍ សម្រាប់សំណួរស្រាវជ្រាវទី ២ ដែលមានសំណួរគាំទ្រសរុបចំនួន ០៨ ដោយផ្តោតទៅលើបញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ សំណួរសម្ភាសន៍ មានជូនភ្ជាប់ក្នុង ឧបសម្ព័ន្ធ "ខ" ។

**៣.១.២.៣ ការប្រមូលទិន្នន័យតាមគុណវិស័យ** ( Data Collection Procedure )

ការប្រមូលទិន្នន័យតាមគុណវិស័យគឺ ប្រើប្រាស់ការសម្ភាសន៍ និងមានសំណួរគោលសំខាន់ៗទាក់ទងទៅនឹងសំណួរស្រាវជ្រាវទី ១ និងសំណួរស្រាវជ្រាវទី ២ ។ អ្នកសិក្សាស្រាវជ្រាវបានជូនលិខិតស្នើសុំសម្ភាសន៍ជាមួយក្រុមគោលដៅ ដោយបញ្ជាក់ពីពេលវេលា និងបង្ហាញសំណួរគោលជាមុនដើម្បីអាចផ្តល់ទិន្នន័យ និងពិភាក្សាលើចំណុចរួមអំឡុងពេលសម្ភាសន៍។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ការសម្ភាសន៍តាមប្រព័ន្ធអនឡាញ ( Google Meet និង Zoom ) លើក្រុមគោលដៅទាំង ៣ និងប្រើប្រាស់សំណួរបើកចំហបន្ថែមទៅលើសំណួរគោល ដើម្បីទទួលបានការយល់ដឹងទូលំលាយ ក្នុងពេលធ្វើការសម្ភាសន៍ ។ អ្នកស្រាវជ្រាវធ្វើការសង្កេតទៅលើការផ្តល់ចម្លើយទាំងអស់របស់ក្រុមគោលផងដែរ។ មុននឹងធ្វើការសម្ភាសន៍ អ្នកស្រាវជ្រាវបានប្រាប់ពីវត្ថុបំណងនៃការស្រាវជ្រាវទៅដល់អ្នកចូលរួម ឱ្យបានជ្រាបជាមុន និងទិន្នន័យដែលទទួលបានពីការសម្ភាសន៍ គឺប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវលើប្រធានបទនេះតែម្យ៉ាងប៉ុណ្ណោះ ។ អ្នកស្រាវជ្រាវយកចិត្តទុកដាក់ស្តាប់ កត់ត្រា និងបានស្នើសុំការថតសម្លេងលើដំណើរការនៃកិច្ចសម្ភាសន៍ ។ អ្នកស្រាវជ្រាវបានចុះកូដ ពេលទទួលបានទិន្នន័យពីការសម្ភាសន៍នីមួយៗទុកសម្រាប់ធ្វើការវិភាគតាមនីតិវិធីដែលបានកំណត់ច្បាស់លាស់ ។

**៣.១.២.៤ ការវិភាគទិន្នន័យតាមគុណវិស័យ** ( Data Analysis )

ក្រោយពីបានប្រមូលទិន្នន័យតាមរយៈសម្ភាសន៍រួចមក ទិន្នន័យគុណវិស័យត្រូវបានយកមករៀបចំវិភាគទៅតាមនីតិវិធីច្បាស់លាស់ ដោយការចាប់បណ្តុំនៃពាក្យលើអថេរគោលតាមប្រភេទនៃសំណួរនីមួយៗ និងឆ្លើយតបទៅនឹងគោលគំនិតចម្បងៗ ពីអ្នកផ្តល់ទិន្នន័យ ។ អ្នកស្រាវជ្រាវបានកត់ត្រារាល់ពាក្យសម្តីដែលអ្នកចូលរួមសម្ភាសន៍បានផ្តល់ឱ្យ ហើយទិន្នន័យដែលបានមកនោះដែរ អ្នកស្រាវជ្រាវមានការគិតដោយប្រុងប្រយ័ត្នដើម្បីវិភាគក្នុងការកំណត់គោលគំនិតសំខាន់ (Themes) ។ អ្នកសិក្សាស្រាវជ្រាវបានកត់ត្រាទិន្នន័យពីការធ្វើសម្ភាសន៍ ទៅតាមផ្នែកនៃសំណួរស្រាវជ្រាវទី ១ និងទី ២ ។ ការរៀបចំត្រូវបានអនុវត្តទៅតាមជំហានដូចជា៖ (១). រៀបចំទៅលើទិន្នន័យប្រមូលបានតាមរយៈការថតចម្លងបទសម្ភាសន៍ ការបកប្រែទិន្នន័យ ការកត់ត្រាព័ត៌មានលម្អិត និងការកំណត់ខ្លឹមសារ (Transcript) (២). កំណត់ក្របខណ្ឌនៃការវិភាគទិន្នន័យ ដោយធ្វើការដាក់កូដទិន្នន័យក្នុងគម្រោងវិភាគ ដាក់សញ្ញា និងកំណត់ទិន្នន័យ (Coding and Consolidation) (៣). សំយោគក្របខណ្ឌនៃគោលគំនិតរួម (Themes) តាមរយៈការវិភាគពិពណ៌នាដោយផ្អែកលើក្របខណ្ឌ (Content analysis) ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ។

## ៣.២ ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានប្រកាន់ខ្ជាប់នូវគោលការណ៍ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការចុះប្រមូលទិន្នន័យ នៅតាមក្រុមគោលដៅដែលបានកំណត់នៅក្នុងការស្រាវជ្រាវប្រធានបទ ។ លិខិតឧទ្ទេសនាមសម្រាប់បំពេញបេសកកម្ម ត្រូវបានអនុញ្ញាតដោយវិទ្យាស្ថានជាតិអប់រំ និងបានប្រគល់ជូនទៅតាមអង្គភាពពាក់ព័ន្ធ ។ ការចុះប្រមូលទិន្នន័យ គឺអ្នកសិក្សាស្រាវជ្រាវបានប្រាប់ពីគោលបំណងច្បាស់លាស់ និងរក្សាការសម្ងាត់នៃការផ្តល់ទិន្នន័យលើកម្រងសំណួរ ក៏ដូចជាសំណួរសម្ភាសន៍ ។ ទិន្នន័យដែលបានផ្តល់តាមបរិមាណវិស័យ និងគុណវិស័យនេះ គឺសម្រាប់ប្រើប្រាស់ក្នុងគោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះតែប៉ុណ្ណោះ។ ការផ្តល់ទិន្នន័យពីក្រុមគោលដៅគឺក្នុងលក្ខខណ្ឌពេញចិត្ត មានការចូលរួមទាំងអស់គ្នាក្នុងការសហការគ្នា និងផ្តល់ព័ត៌មានដោយឈរលើភាពពិតប្រាកដ និងបទពិសោធន៍ជាក់ស្តែងទៅលើការងារអប់រំ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

នៅក្នុងជំពូកទី ៤ នេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ការបកស្រាយ និងការពិភាក្សាទៅលើព័ត៌មានដែលបានរកឃើញ តាមរយៈការបំពេញកម្រងសំណួរ ពីសំណាក់ក្រុមគោលដៅដែលត្រូវបានកំណត់ជ្រើសរើសក្នុងវិធីសាស្ត្រនៃការប្រមូលទិន្នន័យ នាយក នាយករងសាលា ប្រធាន-អនុប្រធានការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក មន្ត្រីការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្ត ។ ព័ត៌មានមួយចំនួនទៀតក៏ត្រូវបានរកឃើញតាមរយៈការសម្ភាសន៍ជាមួយក្រុមគោលដៅដូចបានកំណត់ក្នុងជំពូក៣ (តារាង៣.២) ។

ចំណុចសំខាន់ៗមួយចំនួនទាក់ទងនឹង " **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី** " ត្រូវបានលើកយកមកធ្វើការបកស្រាយ និងពិភាក្សាសម្រាប់ធ្វើការសន្និដ្ឋានចេញជាអនុសាសន៍ និងសំណូមពរ ។

## ៤.១ ទិន្នន័យព័ត៌មានទូទៅ គណៈគ្រប់គ្រងសាលានៅមធ្យមសិក្សា មន្ត្រីការិយាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំយុវជននិងកីឡាខេត្ត

នៅក្នុងផ្នែកនេះ មានបង្ហាញព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលា ប្រធាន-អនុប្រធានការិ-យាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្ត ដែលជាសំណាកស្រាវជ្រាវទាំងអស់ ដែលមានព័ត៌មានលម្អិតពីតួនាទី ទីកន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌មុខជំនាញ និងបទពិសោធន៍ការងារ ដូចនឹងមានបង្ហាញជូននូវផ្នែកខាងក្រោមនេះ ។

### ៤.១.១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលាមធ្យមសិក្សា

តាមទិន្នន័យបានទទួលពីគណៈគ្រប់គ្រងសាលានៅកម្រិតមធ្យមសិក្សា ទុតិយភូមិបានបង្ហាញថាមានចំនួន ៥០% ជានាយកសាលា និងមានចំនួន ៥០% ជានាយករងសាលា ។ ដែលក្នុងនោះគណៈគ្រប់គ្រងសាលាជាបុរសមានចំនួន ៧២.៧ % និងគណៈគ្រប់គ្រងសាលាជាស្ត្រី មានចំនួន ២៧.៣% ។

ជាមួយគ្នានេះគណៈគ្រប់គ្រងសាលាចំនួន ៤.៥% មានអាយុចន្លោះពី ២៥-៣០ឆ្នាំ គណៈគ្រប់គ្រងសាលាចំនួន ១៨.២% មានអាយុចន្លោះពី ៣១-៣៥ឆ្នាំ គណៈគ្រប់គ្រងសាលាចំនួន ៣១.៨% មានអាយុចន្លោះពី ៣៦-៤០ឆ្នាំ និងគណៈគ្រប់គ្រងសាលាចំនួន ៤៥% មានអាយុលើស ពី ៤០ ឆ្នាំ ។ គណៈគ្រប់គ្រងសាលាចំនួន ១៨% បានបញ្ចប់ការសិក្សានៅថ្នាក់ទី ១២ គណៈគ្រប់គ្រងសា លាចំនួន ៥៥% បានបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រ គណៈគ្រប់គ្រងសាលាចំនួន ២៧% បាន បញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ។ គណៈគ្រប់គ្រងសាលាចំនួន ២៣% មានបទពិសោធន៍ ការងារចន្លោះពី ៦-១០ឆ្នាំ គណៈគ្រប់គ្រងសាលាចំនួន ២៧% មានបទពិសោធន៍ការងារចន្លោះពី ១១-១៥ឆ្នាំ និងគណៈគ្រប់គ្រងសាលាចំនួន ៥០% មានបទ ពិសោធន៍ការងារលើសពី ១៥ឆ្នាំ ។

### ៤.១.២ ព័ត៌មានទូទៅមន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅ ការិយាល័យអប់រំយុវជន និងកីឡាចំណុះមន្ទីរអប់រំ

តាមទិន្នន័យបានទទួលពីមន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានបង្ហាញថា មានចំនួន ៣៤% ជាប្រធានការិយាល័យ និងមានចំនួន ៦៦% ជាអនុប្រធានការិយាល័យ ។ ក្នុងនោះ ដែរមន្ត្រីការិយាល័យជាបុរសមានចំនួន ៨៧.៥ % និងជាស្ត្រីមានចំនួន ១២.៥% ។ ជាមួយគ្នានេះមន្ត្រីនៅការិយាល័យចំនួន ៣.១៣% មានអាយុចន្លោះពី ២៥-៣០ ឆ្នាំ មន្ត្រីនៅការិយាល័យចំនួន ៩.៣៨% មានអាយុចន្លោះពី ៣១-៣៥ឆ្នាំ មន្ត្រីនៅការិយាល័យចំនួន ៤១% មានអាយុចន្លោះពី ៣៦-៤០ឆ្នាំ និងមន្ត្រីនៅការិយាល័យចំនួន ៤៧% មានអាយុលើសពី ៤០ឆ្នាំ ។ មន្ត្រីនៅការិយាល័យចំនួន ៣១% បានបញ្ចប់ការសិក្សានៅថ្នាក់ទី ១២ មន្ត្រីនៅការិយាល័យ ចំនួន ៥៩% បានបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រ និងមន្ត្រីនៅការិយាល័យលាចំនួន ៩.៤% បានបញ្ចប់ការសិក្សានៅ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ។ មន្ត្រីនៅការិយាល័យចំនួន ៣.១% មានបទពិសោធន៍ការងារចន្លោះពី ១-៥ឆ្នាំ មន្ត្រីនៅការិយាល័យចំនួន ៣.១% មានបទពិសោធន៍ការងារចន្លោះពី ៦-១០ឆ្នាំ មន្ត្រីនៅការិយាល័យចំនួន ២៨% មានបទពិសោធន៍ការងារចន្លោះពី ១១-១៥ឆ្នាំ និងមន្ត្រីនៅការិយាល័យចំនួន ៦៦% មានបទពិសោធន៍ការងារលើសពី ១៥ ឆ្នាំ ។

## ៤.២ ប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

### ៤.២.១ ទិន្នន័យតាមបែបបរិមាណវិស័យ ពីគណៈគ្រប់គ្រងសាលា មន្ត្រីការិយាល័យអប់រំស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំខេត្ត

ជាមួយគ្នានេះ លទ្ធផលនៃការស្រាវជ្រាវឆ្លុះបញ្ចាំងពីចម្លើយទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចខាងលើ ។ លទ្ធផលទាំងនេះកើតចេញពីទិន្នន័យដើម ដែលអ្នកចូលរួមបានបំពេញកម្រងសំណួរដែលអ្នកស្រាវជ្រាវបានចែកជូនទៅតាមមុខសញ្ញាដែលបានកំណត់ ។ គំនិតយោបល់ ការយល់ឃើញរបស់អ្នកចូលរួម ត្រូវបានយកមកវិភាគស្របទៅតាមវត្ថុបំណងនៃការស្រាវជ្រាវ ដើម្បីធ្វើឱ្យលទ្ធផលមានលក្ខណៈវិទ្យាសាស្ត្រ និងអាចទទួលយកបាន ។ គំនិតយោបល់ ការយល់ឃើញរបស់អ្នកចូលរួម វិធីសាស្ត្រស្រាវជ្រាវ ការបញ្ចូលទិន្នន័យ វិធីវិភាគទិន្នន័យ និងចំនួនសំណាក ត្រូវបានពូនផ្តុំបង្កើតបានជាលទ្ធផលស្រាវជ្រាវឆ្លើយតបទៅនឹងប្រធានបទដូចខាងក្រោម ៖

តារាងទិន្នន័យខាងក្រោមនេះ បានបង្ហាញពីមធ្យមភាគសរុបនៃការឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់របស់សាលារៀននាឆ្នាំកន្លងមក ។

**តារាង៤.១ ៖ ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | មានទស្សនៈវិស័យនិងគោលដៅដឹកនាំគ្រប់គ្រងសាលារៀនច្បាស់លាស់ | 3.77 | 0.53 | ល្អ | 3.59 | 0.87 | ល្អ |
| ២ | បានអភិវឌ្ឍកម្លាំងពលកម្មមូលធនមនុស្សទៅតាមតម្រូវការសង្គម | 3.64 | 0.66 | ល្អ | 3.13 | 0.91 | មធ្យម |
| ៣ | បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោបាយជាតិ និងការអប់រំ | 3.82 | 0.50 | ល្អ | 3.41 | 0.91 | ល្អ |
| ៤ | ផ្តល់សេវាកម្មការសិក្សាអប់រំកម្មវិធីពលរដ្ឋពេញលេញដល់ សិស្សានុសិស្ស | 4.05 | 0.72 | ល្អ | 3.47 | 0.95 | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | អនុវត្តកម្មវិធីសិក្សាស្របទៅតាមបទបញ្ញត្តិ និងតម្រូវការសហគមន៍ | 3.73 | 0.83 | ល្អ | 3.47 | 0.92 | ល្អ |
| ៦ | បានរៀបចំគោលការណ៍ស្ដីពីអភិបាលកិច្ចល្អ | 3.82 | 0.73 | ល្អ | 3.38 | 1.01 | មធ្យម |
| ៧ | មានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវការងារ ច្បាស់លាស់ | 4.36 | 0.73 | ល្អណាស់ | 3.97 | 1.12 | ល្អ |
| ៨ | មានផែនការប្រកបដោយនិរន្ត សម្រាប់ការអភិវឌ្ឍសាលារៀន | 3.86 | 0.56 | ល្អ | 3.66 | 0.79 | ល្អ |
| ៩ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់និងប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ | 3.91 | 0.87 | ល្អ | 3.56 | 0.95 | ល្អ |
| ១០ | បានរៀបចំបង្កើនយន្តការ ចុះឈ្មោះចូលរៀន | 4.55 | 0.51 | ល្អណាស់ | 3.75 | 1.11 | ល្អ |
| សរុប | | **3.95** | **0.13** | **ល្អ** | **3.54** | **0.10** | **ល្អ** |

តារាង៤.១ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្ដល់ទិន្នន័យជាសរុប ពីកម្រិត **ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៩៥)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "បានរៀបចំបង្កើនយន្តការចុះឈ្មោះចូលរៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.៥៥)។ សូចនាករទទួលបានពិន្ទុទាបជាងគេ គឺ "បានអភិវឌ្ឍកម្លាំងពលកម្មមូលធនមនុស្សទៅតាមតម្រូវការសង្គម" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៦៤)។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្ដល់ទិន្នន័យជាសរុបពីកម្រិត **ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៥៤)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " មានបំណែងចែកភារកិច្ច និងការទទួលខុសត្រូវការងារច្បាស់លាស់ " ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ=៣.៩៧) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "បានអភិវឌ្ឍកម្លាំងពលកម្មមូលធនមនុស្សទៅតាមតម្រូវការសង្គម" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ៣.១៣)។

**តារាង៤.២ ៖ ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យអប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | បានកសាងផែនការការងារប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ | 4.23 | 0.69 | ល្អណាស់ | 3.50 | 1.08 | ល្អ |
| ២ | បានបែងចែកភារកិច្ច និងការទទួលខុសត្រូវដល់បុគ្គលិកអប់រំ ក្រោមឱវាទ | 4.23 | 0.75 | ល្អណាស់ | 3.88 | 1.07 | ល្អ |
| ៣ | បានអនុវត្តការងារទៅតាមតួនាទីភារកិច្ចនិងកាតព្វកិច្ចបានត្រឹមត្រូវ | 4.27 | 0.55 | ល្អណាស់ | 3.81 | 1.12 | ល្អ |
| ៤ | ប្រើប្រាស់ធនធានសាលារៀនអស់លទ្ធភាព | 4.14 | 0.71 | ល្អ | 3.66 | 0.94 | ល្អ |
| ៥ | ស្រឡាញ់រាប់អានគ្រូបង្រៀន និងបុគ្គលិកអប់រំស្មើៗគ្នាដោយមិនមានប្រកាន់ បក្ខពួក ឬក្រុម | 4.59 | 0.59 | ល្អណាស់ | 3.94 | 1.08 | ល្អ |
| ៦ | មានរបាយការណ៍វាយតម្លៃស្តីពីប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ | 3.77 | 0.87 | ល្អ | 3.16 | 1.02 | មធ្យម |
| ៧ | មានរៀបចំការប្រជុំ ស្តីពីការងារបង្រៀន និងរដ្ឋបាលសាលារៀន តាមកាល កំណត់រវាងគណៈគ្រប់គ្រង និងភាគីពាក់ព័ន្ធ | 4.09 | 0.61 | ល្អ | 3.34 | 1.00 | មធ្យម |
| ៨ | គណៈគ្រប់គ្រង ពិនិត្យតាមដានលើការអនុវត្តផែនការសកម្មភាព និងផែន ការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន | 3.82 | 0.80 | ល្អ | 3.22 | 1.04 | មធ្យម |
| ៩ | គណៈគ្រប់គ្រង បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម តាមបច្ចុប្បន្នភាព ដើម្បីពង្រីកទំនាក់ទំនងឆាប់រហ័ស | 4.18 | 0.50 | ល្អ | 3.22 | 1.07 | មធ្យម |
| សរុប | | **4.15** | **0.12** | **ល្អ** | **3.54** | **0.05** | **ល្អ** |

តារាង៤.២ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៥)។ សូចនាករ

ទទួលបានពិន្ទុខ្ពស់ជាងគេគឺ "ស្រឡាញ់រាប់អានគ្រូបង្រៀន និងបុគ្គលិកអប់រំស្មើៗគ្នាដោយមិនមានប្រកាន់បក្ខពួក ឬក្រុម" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៥៩)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "មានរបាយការណ៍វង្វាយតម្លៃស្ដីពីប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៧៧)។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្ដល់ទិន្នន័យជាសរុបពីកម្រិត **ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៥២)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " ស្រឡាញ់រាប់អានគ្រូបង្រៀន និងបុគ្គលិកអប់រំស្មើៗគ្នាដោយមិនមានប្រកាន់បក្ខពួក ឬក្រុម" ក្នុងកម្រិត " ល្អណាស់ " (មធ្យមភាគពិន្ទុ=៣.៩៤) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "មានរបាយការណ៍វង្វាយតម្លៃស្ដីពីប្រសិទ្ធភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ៣.១៦)។

**តារាង៤.៣ ៖ ចូលរួមសកម្មភាពលើការងារបង្រៀន និងរៀន**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | បានត្រួតពិនិត្យលើការអនុវត្តកម្មវិធីសិក្សា និងនិយាមសិក្សា | 4.23 | 0.61 | ល្អណាស់ | 3.28 | 0.99 | មធ្យម |
| ២ | បានបង្កើតបរិយាកាស ក្នុងការផ្លាស់ប្ដូរចំណេះដឹង និងបទពិសោធន៍ តាមរយៈ ថ្នាក់និទស្សន៍ | 3.59 | 0.80 | ល្អ | 2.94 | 1.11 | មធ្យម |
| ៣ | បានសហការជាមួយគ្រូដើម្បីរៀបចំយន្តការធានាគុណភាពលើការបង្រៀន និងរៀន | 4.00 | 0.69 | ល្អ | 3.25 | 0.88 | មធ្យម |
| ៤ | បានលើកទឹកចិត្តគ្រូឱ្យស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ និងប្រើប្រាស់ បច្ចេកវិទ្យាក្នុងការបង្រៀនសិស្ស | 3.86 | 0.56 | ល្អ | 3.34 | 0.94 | មធ្យម |
| ៥ | ផ្ដល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 4.27 | 0.63 | ល្អណាស់ | 3.56 | 0.95 | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | គ្រូ បានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា | 4.55 | 0.60 | ល្អណាស់ | 3.72 | 1.11 | ល្អ |
| ៧ | បានផ្តល់ចំណេះដឹងជំនាញរឹង និងការត្រិះរិះពិចារណាដល់សិស្ស | 4.00 | 0.53 | ល្អ | 3.34 | 0.83 | មធ្យម |
| ៨ | សិស្សមានសមត្ថភាព ចំណេះដឹងនិងជំនាញទទួលបានពីការបណ្តុះ បណ្តាល | 3.59 | 0.67 | ល្អ | 3.31 | 0.82 | មធ្យម |
| ៩ | លើកទឹកចិត្តសិស្សដោយជំរុញបរិបទនៃការសិក្សាដោយខ្លួនឯង | 4.14 | 0.64 | ល្អ | 3.53 | 0.95 | ល្អ |
| សរុប | | **4.03** | **0.08** | **ល្អ** | **3.36** | **0.11** | **ល្អ** |

តារាង៤.៣ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការចូលរួមសកម្មភាពលើការងារបង្រៀន និងរៀន** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០៣)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "គ្រូបានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥៥)។ សូចនាករទទួលបានពិន្ទុទាបជាងគេមានចំនួន ២ គឺ ទី១/ "បានបង្កើតបរិយាកាស ក្នុងការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍តាមរយៈថ្នាក់និទស្សន៍" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៥៩)ទី២/ "សិស្សមានសមត្ថភាព ចំណេះដឹង និងជំនាញទទួលបានពីការបណ្តុះ បណ្តាល" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៥៩) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការចូលរួមសកម្មភាពលើការងារបង្រៀន និង រៀន** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ=៣.៣៦)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " គ្រូបានបង្រៀនតាមកាលវិភាគ និងបំណែងចែកកម្មវិធីសិក្សា" ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ=៣.៧២) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "បានបង្កើត បរិយាកាសក្នុងការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ តាមរយៈថ្នាក់និទស្សន៍" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ=២.៩៣)។

**តារាង៤.៤ ៖ ការកសាងធនធានសមត្ថភាពគ្រូ និងសេវាជួយសិស្ស**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | ការិយាល័យ<br>អប់រំស្រុក និងការិ.មន្ទីរ |
|---|---|---|---|

| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
|---|---|---|---|---|---|---|---|
| ១ | បានអភិវឌ្ឍគុណភាព និងសមត្ថភាពជំនាញបច្ចេកទេសដល់គ្រូ | 3.41 | 0.67 | ល្អ | 3.03 | 1.03 | មធ្យម |
| ២ | បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន | 3.50 | 0.74 | ល្អ | 3.31 | 1.00 | មធ្យម |
| ៣ | មានទំនាក់ទំនងល្អ ជាមួយគ្រូបង្រៀន និងបុគ្គលិកក្រោមបង្គាប់ | 4.41 | 0.67 | ល្អណាស់ | 3.88 | 1.01 | ល្អ |
| ៤ | គណៈគ្រប់គ្រង មានផែនការសម្រាប់ការបណ្ដុះបណ្ដាលគ្រូ និងសមត្ថភាព លើការអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗ | 3.77 | 0.92 | ល្អ | 2.88 | 0.98 | មធ្យម |
| ៥ | អនុវត្តការបែងចែកគ្រូបង្រៀន តាមនិយាមប្រើប្រាស់ម៉ោងបង្រៀន និងតាមមុខវិជ្ជាឯក ទេស | 4.45 | 0.51 | ល្អណាស់ | 3.59 | 1.24 | ល្អ |
| ៦ | បានរក្សាគ្រូបង្រៀនដែលមានគុណវុឌ្ឍិ នៅក្នុងសាលារៀន និងមានការលើកទឹក ចិត្តខ្ពស់ | 3.95 | 0.58 | ល្អ | 3.34 | 0.94 | មធ្យម |
| ៧ | វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងបុគ្គលិកដោយតម្លាភាព | 4.18 | 0.50 | ល្អ | 3.53 | 1.08 | ល្អ |
| ៨ | បានពង្រឹងការអនុវត្តគោលការណ៍ ស្ដីពីការលើកកម្ពស់ការអភិវឌ្ឍ សមត្ថភាព បង្កើនការសិក្សាស្រាវជ្រាវ និងឱកាសសិក្សាបន្ត | 4.18 | 0.59 | ល្អ | 3.34 | 1.04 | មធ្យម |
| ៩ | បានអនុវត្តការផ្តល់ប្រព័ន្ធលាភការត្រឹមត្រូវដល់គ្រូបង្រៀន និងបុគ្គលិកអប់រំ | 4.00 | 0.62 | ល្អ | 3.41 | 0.98 | ល្អ |
| ១០ | បានបង្កលទ្ធភាពអោយគ្រូមានការ ផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹង ទៅវិញទៅមក | 4.23 | 0.69 | ល្អណាស់ | 3.31 | 1.06 | មធ្យម |
| សរុប | | **4.01** | **0.12** | **ល្អ** | **3.36** | **0.08** | **មធ្យម** |

តារាង៤.៤ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការកសាងធនធានសមត្ថភាពគ្រូ និងសេវាជួយសិស្ស** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០១)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "អនុវត្តការបែងចែកគ្រូបង្រៀនទៅតាមនិយាមប្រើប្រាស់ម៉ោង

បង្រៀន និងតាមមុខវិជ្ជាឯកទេស˝ ក្នុងកម្រិត " ល្អណាស់ " (មធ្យមភាគពិន្ទុ=៤.៤៥)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ ˝បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន˝ ក្នុងកម្រិត ˝ល្អ˝ (មធ្យមភាគពិន្ទុ= ៣.៥០) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការកសាងធនធានសមត្ថភាពគ្រូ និងសេវាជួយសិស្ស** ក្នុងកម្រិត ˝មធ្យម˝ (មធ្យមភាគពិន្ទុ=៣.៣៦)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " មានទំនាក់ទំនងល្អជាមួយគ្រូបង្រៀន និងបុគ្គលិកក្រោមបង្គាប់˝ ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ= ៣.៨៨) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ ˝គណៈគ្រប់គ្រង មានផែនការសម្រាប់ការ បណ្តុះបណ្តាលគ្រូ និងសមត្ថភាព លើការអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗ˝ ក្នុងកម្រិត ˝មធ្យម˝ (មធ្យមភាគ ពិន្ទុ= ២.៨៨

**តារាង៤.៥ ៖ ការកសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | បានរៀបចំបរិស្ថាន សោភ័ណភាព អនាម័យ និងសណ្តាប់ធ្នាប់សាលារៀន | 4.32 | 0.65 | ល្អណាស់ | 3.53 | 0.98 | ល្អ |
| ២ | ថ្នាក់រៀន មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | 4.14 | 0.71 | ល្អ | 3.56 | 0.95 | ល្អ |
| ៣ | មានកិច្ចគាំទ្រ និងឆ្លើយតបទាន់ពេលវេលានៃតម្រូវការ សម្ភារៈសម្រាប់ ការរៀន និងបង្រៀន | 3.73 | 0.70 | ល្អ | 3.38 | 0.83 | មធ្យម |
| ៤ | បានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀនជាប្រចាំ | 4.00 | 0.76 | ល្អ | 3.38 | 0.87 | មធ្យម |
| ៥ | ធនធានរូបវន្ត ធានាបាននូវស្តង់ដារសុវត្ថិភាព | 3.91 | 0.68 | ល្អ | 3.13 | 0.79 | មធ្យម |
| សរុប | | **4.02** | **0.04** | **ល្អ** | **3.39** | **0.08** | **មធ្យម** |

តារាង៤.៥ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការកសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០២)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "បានរៀបចំបរិស្ថាន សោភ័ណភាព អនាម័យ និងសណ្តាប់ធ្នាប់សាលារៀន" ក្នុងកម្រិត " ល្អណាស់ " (មធ្យមភាគពិន្ទុ=៤.៣២)។ សូចនាករទទួល បានពិន្ទុទាបជាងគេគឺ "មានកិច្ចគាំទ្រ និងឆ្លើយតបទាន់ពេលវេលានៃតម្រូវការ សម្ភារៈសម្រាប់ការរៀន និងបង្រៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាគ ពិន្ទុ= ៣.៧៣) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការកសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣៩)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " ថ្នាក់រៀនមានបរិយាកាសសិក្សាល្អធ្វើឲ្យសិស្សងាយស្រួលសិក្សា" ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ=៣.៥៦) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "ធនធានរូបវន្ត ធានាបាននូវស្តង់ដារសុវត្ថិភាព" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ៣.១៣)។

**តារាង៤.៦ ៖ កៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការតាមផែនការប្រតិបត្តិប្រចាំឆ្នាំ | 4.05 | 0.72 | ល្អ | 3.44 | 1.01 | ល្អ |
| ២ | បានប្រើប្រាស់ថវិកាឆ្លើយតបទៅនឹងសកម្មភាពរបស់ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍សាលារៀន | 3.82 | 0.80 | ល្អ | 3.41 | 1.07 | ល្អ |
| ៣ | បានរៀបចំការប្រជុំជាមួយបុគ្គលិកពិនិត្យមើលការអនុវត្តសកម្មភាពនៅក្នុងផែនការសាលារៀន និងលើកទិសដៅបន្ត | 3.95 | 0.65 | ល្អ | 3.16 | 1.08 | មធ្យម |
| ៤ | បានកៀរគរថវិកាពីសហគមន៍ អាណាព្យាបាលសិស្សអជ្ញាធរមូលដ្ឋានដើម្បីអភិវឌ្ឍសាលារៀន | 3.59 | 0.85 | ល្អ | 2.69 | 1.00 | មធ្យម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | មានតម្លាភាពក្នុងការប្រើថវិកាសាលារៀន | 4.09 | 0.68 | ល្អ | 3.34 | 1.15 | មធ្យម |
| ៦ | បានផ្តល់ស្វ័យភាពនៃការលើកសំណើប្រើថវិកាសម្រាប់បម្រើឱ្យការងារបង្រៀន និងរៀន | 4.05 | 0.65 | ល្អ | 3.50 | 1.05 | ល្អ |
| ៧ | បានប្រជុំផ្សព្វផ្សាយស្តីពីការចំណាយថវិកាជូនទៅដល់អាណាព្យាបាលសិស្ស សហគមន៍ និងអង្គាធរមូលដ្ឋាន | 3.86 | 0.89 | ល្អ | 3.13 | 1.24 | មធ្យម |
| ៨ | សាលាមានបញ្ជីសម្ភារបរិក្ខារ និងការត្រួតពិនិត្យជាប្រចាំច្បាស់លាស់ | 3.68 | 0.84 | ល្អ | 3.31 | 1.06 | មធ្យម |
| សរុប | | **3.89** | **0.09** | **ល្អ** | **3.25** | **0.08** | **មធ្យម** |

តារាង៤.៦ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការកៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៩)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "មានតម្លាភាពក្នុងការប្រើប្រាស់ថវិកាសាលារៀន" ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ=៤.០៩)។ សូចនាករទទួល បានពិន្ទុទាបជាងគេគឺ "បានកៀរគរថវិកាពីសហគមន៍ អាណាព្យាបាលសិស្សអង្គាធរមូលដ្ឋានដើម្បីអភិវឌ្ឍសាលារៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាគ ពិន្ទុ= ៣.៥៩) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការកៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.២៥)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " បានផ្តល់ស្វ័យភាពនៃការលើកសំណើប្រើប្រាស់ថវិកាសម្រាប់បម្រើឱ្យការងារបង្រៀន និងរៀន" ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ=៣.៥០) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "បានកៀរគរថវិកាពីសហគមន៍ អាណាព្យាបាលសិស្សអង្គាធរមូលដ្ឋានដើម្បីអភិវឌ្ឍសាលារៀន" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ២.៦៩)។

**តារាង៤.៧ ៖ មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | បានកសាងភាពជាដៃគូល្អប្រសើរជាមួយសហគមន៍ ដើម្បីជំរុញការសិក្សា របស់សិស្ស និងកែលម្អបរិស្ថានសាលារៀន | 3.91 | 0.81 | ល្អ | 3.44 | 0.88 | ល្អ |
| ២ | ប្រមូលផ្តុំធនធានសហគមន៍ ក្នុងការចូលរួមអភិវឌ្ឍការអប់រំក្នុងសាលារៀន | 3.41 | 0.85 | ល្អ | 3.03 | 1.00 | មធ្យម |
| ៣ | បានរៀនចំកម្មវិធីប្រជុំនិងមានទំនាក់ទំនងល្អជាមួយភាគីពាក់ព័ន្ធក្រៅសាលា | 3.55 | 0.86 | ល្អ | 3.09 | 1.09 | មធ្យម |
| ៤ | ចែករំលែកធនធានសម្ភារៈ និងចំណេះដឹង ដល់សាលារៀននានា | 3.68 | 0.78 | ល្អ | 3.00 | 1.08 | មធ្យម |
| ៥ | បង្កើតទំនាក់ទំនងទ្វេភាគីជាមួយឪពុកម្តាយ សហគមន៍ និងសាលាដទៃ | 3.73 | 0.77 | ល្អ | 3.09 | 1.09 | មធ្យម |
| ៦ | បង្កើតបណ្តាញអប់រំជាមួយស្ថាប័ន និងអ្នកអប់រំដទៃទៀត | 3.50 | 0.67 | ល្អ | 2.78 | 1.21 | មធ្យម |
| ៧ | អនុវត្តយន្តការការងារលើការធ្វើការសម្រេចចិត្តដោយមានភាគីពាក់ព័ន្ធ ចូលរួម | 3.77 | 0.69 | ល្អ | 3.28 | 1.05 | មធ្យម |
| សរុប | | **3.65** | **0.07** | **ល្អ** | **3.10** | **0.08** | **មធ្យម** |

តារាង៤.៧ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិតនៃ **មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៦៥)។ សូចនាករទទួលបាន ពិន្ទុខ្ពស់ជាងគេគឺ "បានកសាងភាពជាដៃគូល្អប្រសើរជាមួយសហគមន៍ ដើម្បីជំរុញការសិក្សារបស់សិស្ស និងកែលម្អបរិស្ថានសាលារៀន " ល្អ " (មធ្យមភាគ ពិន្ទុ=៣.៩១)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "ប្រមូលផ្តុំធនធានសហគមន៍ ក្នុងការចូលរួមអភិវឌ្ឍការអប់រំក្នុងសាលារៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាគ ពិន្ទុ= ៣.៤១) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.១០)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " បានកសាងភាពជាដៃគូល្អប្រសើរជាមួយសហគមន៍ ដើម្បីជំរុញ ការសិក្សារបស់សិស្ស និងកែលម្អបរិស្ថានសាលារៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៤៤)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ

"បង្កើតបណ្តាញអប់រំជាមួយស្ថាប័ន និងអ្នកអប់រំដទៃទៀត" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ២.៧៨)។

### ៤.២.២ ទិន្នន័យតាមគុណវិស័យ (ទិន្នន័យបានពីប្រធាន អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយក ដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ)

មន្ទីរអប់រំយុវជន និងកីឡាខេត្តបានខិតខំប្រឹងប្រែងជំនះបញ្ហាប្រឈមនានាអនុវត្តសកម្មភាពទៅតាមផែនការដែលបានកសាងជាផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងគោលបំណងបង្កើនការធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដល់កុមារ យុវជន និងប្រជាពលរដ្ឋគ្រប់រូប គ្រប់ជនជាតិនៅក្នុងខេត្ត លើការលើកកម្ពស់គុណភាព និងភាពឆ្លើយតបគ្រប់ភូមិសិក្សាឱ្យកាន់តែទទួលបានលទ្ធផលល្អប្រសើរឡើង ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្តរបស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...មានការពេញចិត្តដោយគ្រប់ការិយាល័យអនុវត្តការងារបានល្អ ព្រោះថាសកម្មភាពមិនជាន់គ្នាទាំងផ្នែករដ្ឋ និងដៃគូ ព្រមទាំងបានធ្វើការឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍សមិទ្ធិកម្មលើការអនុវត្តនាពេលកន្លងមកទាំងប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ និងបានអនុវត្តទៅតាមគន្លងនៃផែនការយុទ្ធសាស្ត្រអប់រំបើទោះបីជាយើងជួបប្រទះនឹងវិបត្តិសកលក៏ដោយ... "

( POE#.1.2 )

"...លទ្ធផលអាចល្អប្រសើរប្រសិនបើគ្មានវិបត្តិសកល ពិសេសប្រសិនបើចំណុចដៅរបស់ថ្នាក់ខេត្ត បង្រួមឱ្យរួមតូចបន្តិចកាន់តែប្រសើរ ។ ម្យ៉ាងវិញទៀត ការដែលយើងទៅមើលពីលទ្ធផលនាំការអនុវត្តបានល្អប្រសើរ យើងត្រូវទៅមើលពីគុណភាពនៃផែនការជាមុនសិន ថាតើផែនការនោះបានរៀបចំសមស្របទៅតាមគោលនយោបាយ ឬបានកំណត់នូវបញ្ហាច្បាស់លាស់ ឬបានធ្វើការស្រាវជ្រាវប្រតិបត្តិជាមុនសិន ដែរឬទេមុននឹងយកទៅអនុវត្ត ដើម្បីឱ្យផែនការនោះមានលក្ខណៈបរិយាប័ន និងមានការគាំទ្រពេល អនុវត្ត ហើយអ្នកអនុវត្តត្រូវចាំបាច់អនុលោមទៅតាមផែនការគ្រោង..."

( Expert#.1.2 )

កាអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្លើយតបយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ បានជួយឱ្យការអនុវត្តផែនការនៅមន្ទីរកាន់តែមានលក្ខណៈល្អប្រសើរឡើង ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្តរបស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...វាបានធ្វើឱ្យមានភាពប្រសើរឡើងនូវផ្នែកពាក់ព័ន្ធ ដូចជាការគ្រប់គ្រងនៅតាមសាលារៀនមានភាពល្អប្រសើរដោយសាលាបានអនុវត្តតាមផែនការយុទ្ធសាស្ត្រអប់រំ មានសមត្ថភាព និងមានការចូលរួមពីមាតាបិតាសិស្ស ចំណែកការសិក្សាមានការពិនិត្យតាមដាន ការកែប្រែវិធីសាស្ត្របង្រៀន និងបានអនុវត្តទៅតាមកម្មវិធីសិក្សា រីឯផ្នែកហិរញ្ញវត្ថុមានប្រព័ន្ធច្បាស់លាស់ លឿនរហ័ស និងសុក្រឹត្យភាព..."

( POE#.1.2 )

"...វាបានជួយឱ្យមន្ទីរអាចសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្សមានភាពល្អប្រសើរ តាមរយៈការធ្វើឱ្យមានភាពបន្សុីគ្នារវាងផែនការប្រតិបត្តិសាលា ផែនការរបស់ការិយាល័យអប់រំស្រុក និងផែនការប្រតិបត្តិរបស់មន្ទីរ..."

( DOP#.1.2.3 )

"...បានធ្វើឱ្យលទ្ធផលសិក្សារបស់សិស្ស មានចំនួនកើនឡើងបើធៀបជាមួយឆ្នាំសិក្សាកន្លងមកជាមួយថ្នាក់ជាតិ ដោយហេតុសិស្សតាមភូមិសិក្សាមានការយល់ដឹងច្រើនលើការប្រើប្រាស់បច្ចេកវិទ្យា នឹងចេះបត់បែនការសិក្សាតាមបរិបទថ្មី..."

( Expert#.1.2 )

កាអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ធៀបទៅនឹងបរិបទកំណែទម្រង់ការគ្រប់គ្រងការសិក្សានៅកម្រិតសាលារៀន បានជួយឱ្យការអនុវត្តផែនការនៅមន្ទីរកាន់តែមានលក្ខណៈល្អប្រសើរឡើង ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...មានប្រសិទ្ធភាពអាចទទួលយកបាន ដោយសាលាបានធ្វើផែនការបន្សុីគ្នារវាងសាលា ការិយាល័យអប់រំស្រុក និងផែនការរបស់មន្ទីរ តែប្រសិទ្ធភាពកម្រិតណាវាអាស្រ័យទៅលើឆន្ទៈនៃការអនុវត្តរបស់លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រង ថាតើពួកគាត់បានអនុវត្តសកម្មភាពនៃការដឹកនាំគ្រប់គ្រងផែនការដែលបានដាក់ចេញបានក្នុងកម្រិតណា..."

( POE#.1.2 )

"...ជួយឱ្យមានកិច្ចសហការល្អរវាងសាលារៀន និងការិយាល័យជំនាញរបស់មន្ទីរ ព្រមទាំងអាចសម្រេចបានទៅតាមផែនការ ឬចំណុចដៅរបស់មន្ទីរដោយសាលាបានចូលរួមពេញលេញ ទាំងគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ ។ ជាមួយគ្នានេះ ទទួលបានការគាំទ្រដោយសារលទ្ធផលសិក្សារបស់សិស្សល្អប្រសើរ បើធៀបជាមួយចំណុចដៅរបស់ថ្នាក់ជាតិ..."

( DOP#.1.2.3 )

"...លទ្ធផលការសិក្សារបស់សិស្សហាក់មិនសុីគ្នាជាមួយចំណុចដៅរបស់សាលា ឬរបស់ខេត្ត ព្រោះ សាលាខ្លះហាក់ដូចជាដាក់ចេញនូវសូចនាករធំពេក នាំឱ្យពិបាកក្នុងការអនុវត្តឱ្យសម្រេចទៅតាមផែនការមួយវិញទៀតផែនការរបស់សាលា ក្រុង/ស្រុក និងផែនការអប់រំរបស់មន្ទីរអប់រំខេត្តមិនសុីគ្នា ព្រោះសាលា ធ្វើដោយសាលា ស្រុកដោយស្រុក ខេត្តដោយខេត្ត ចឹងទេនៅពេលដែលតួអង្គទាំងបីមិនបានជួយពិ ភាក្សាគ្នានាំឱ្យលទ្ធផលការសិក្សារបស់សិស្សមិនទទួលបានលទ្ធល្អ..."

( Expert#.1.2 )

កាអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ធៀបនឹងបរិបទកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលនៅកម្រិតសាលារៀន បានជួយឱ្យការអនុវត្តផែនការនៅមន្ទីរកាន់តែមានលក្ខណៈល្អប្រសើរឡើង ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍ ៖

"...មានប្រសិទ្ធភាពដោយមិនសូវឃើញមានបញ្ហាចោទ ពីព្រោះយើងបានធ្វើឱ្យផែនការរបស់សាលា ស្រុក និងមន្ទីរមានសង្គតិភាពនឹងគ្នា ពិសេសលើការងារដឹកនាំ និងគ្រប់គ្រងដោយមានការទទួល

ខុសត្រូវតាមរយៈការអភិវឌ្ឍសមត្ថភាពនាយកសាលាឱ្យមានការច្នៃប្រឌិត ឆន្ទៈមុះមុត សាមគ្គីភាពផ្ទៃក្នុង រួមជាមួយបំណិនគរុកោលស្យ បច្ចេកទេស និងទំនាក់ទំនងផ្នែកខាងក្រៅផងដែរ..."

( POE#.1.2 )

"...បុគ្គលិកក្រោមឱវាទបំពេញការងារតាមឋានានុក្រមច្បាស់លាស់ ព្រមទាំងមានការចែករំលែកចំណេះដឹងទៅផ្នែកពាក់ព័ន្ធបានទូលំទូលាយ ជាមួយគ្នានេះប្រព័ន្ធការងារនៅមន្ទីរមានភាពស៊ីចង្វាក់គ្នា ដែលជះឥទ្ធិពលល្អដល់សាលា ការិយាល័យស្រុក ជាមួយការចុះបណ្តុះបណ្តាល ណែនាំទៅលើផែនការសកម្មភាពដែលត្រូវធ្វើសម្រាប់ឆ្នាំសិក្សា និងតម្រូវការចំពោះមុខនៃរបត់សង្គម..."

( DOP#.1.2.3 )

"...មានឱកាសបានជួយសាលាបានច្រើនតាមរយៈការចុះបើកវគ្គបណ្តុះបណ្តាល ទៅលើអ្វីដែលជាតម្រូវការរបស់សាលាដូចជាការណែនាំពីរបៀបនៃការធ្វើផែនការ ការគ្រោងផែនការថវិកា កិច្ចបញ្ជីការគណនេយ្យ កត់ត្រាចំណូល ចំណាយ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធមានមន្ត្រីការិយាល័យអប់រំស្រុក ការិយាល័យជំនាញនៅមន្ទីរ ដែលទាំងនេះក៏ព្រោះតែផែនការប្រតិបត្តិរបស់សាលា របស់ការិយាល័យអប់រំស្រុក និងរបស់មន្ទីរមានភាពប្រទាក់គ្នា..."

( Expert#.1.2 )

កាអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអេប់រំយុវជន និងកីឡាខេត្តរតនគិរី ធៀបនឹងបរិបទកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្រិតសាលារៀន បានជួយឱ្យការអនុវត្តផែនការនៅមន្ទីរកាន់តែមានលក្ខណៈល្អប្រសើរឡើង ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអេប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...មានភាពល្អប្រសើរដោយសាលាមានកញ្ចប់ថវិកាទាំងថវិការដ្ឋ និងឯកជនសមស្របទៅតាមចំនួនសិស្សជាក់ស្តែង លើសពីនេះរាល់ការចាយវាយត្រូវបានបែងចែកទៅតាមមុខសញ្ញាទទួលខុសត្រូវអ្នកពាក់ព័ន្ធ រួមបញ្ចូលទាំងបុគ្គលិក និងគណៈគ្រប់គ្រងសាលារៀនផងដែរ ។ ម្យ៉ាងវិញទៀត សាលាតែង

តែសិក្សាពីតម្រូវការរបស់អង្គភាព មុននឹងលើកផែនការថវិកា ដើម្បីឱ្យការប្រើប្រាស់ថវិកានោះឆ្លើយតបទៅនឹងចំណុចដៅរបស់អង្គភាពទាំងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ..."

( POE#.1.2 )

"...អាចទទួលយកបានដោយការអនុវត្តកញ្ចប់ថវិកា បានផ្សារភ្ជាប់ជាមួយគោលនយោបាយ ជាមួយគ្នានេះខាងហិរញ្ញវត្ថុបានចងក្រងជាប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការសាច់ប្រាក់បានជាក់លាក់ ដែលធ្វើឱ្យប្រព័ន្ធការងារកាន់តែមានភាពច្បាស់លាស់ ឆាប់រហ័ស និងសុក្រឹត្យភាព..."

( DOP#.1.2.3 )

"...ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យា បានឆ្លើយតបទាន់ពេលវេលាទៅតាមយុទ្ធសាស្ត្រកំណែទម្រង់របស់ក្រសួងពាក់ព័ន្ធ និងអាចកាត់បន្ថយបាននូវបាតុភាពមិនប្រក្រតីទៅលើចរន្តលំហូសាច់ប្រាក់ពីស្ថាប័នមួយទៅស្ថាប័នមួយ ពីស្ថាប័នទៅបុគ្គល ជាងនេះទៅទៀតឃើញថា នីតិវិធីនៃការទូទាត់មានភាពរហ័ស ច្បាស់លាស់ ដោយថវិកាតាមអនុគណនីនីមួយៗត្រូវបានកំណត់..."

( Expert#.1.2 )

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ធៀបនឹងបរិបទកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សនៅកម្រិតសាលារៀន បានជួយឱ្យការអនុវត្តផែនការនៅមន្ទីរកាន់តែមានលក្ខណៈល្អប្រសើរ ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្តរបស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍ ៖

"...ថ្នាក់មន្ទីរបានគិតគូរពីគុណវុឌ្ឍិគ្រូស្របតាមគោលនយោបាយក្រសួង ដោយបានជ្រើសរើសគ្រូដើម្បីឱ្យទទួលការបណ្តុះបណ្តាល ពន្លឿន បានបញ្ជូននាយកឱ្យទៅទទួលការបណ្តុះបណ្តាលបន្ថែមទៅលើកការងារដឹកនាំ និងគ្រប់គ្រង ( SEIP/GEIP ) ការលើកទឹកចិត្តឱគ្រូនៅបន្តក្របខ័ណ្ឌ ការលើកទឹកចិត្តឱ្យគ្រូប្តូរទៅសាលាជំនាន់ថ្មីស្របតាមចំណេះជំនាញ សមត្ថភាពពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាតាមសាលារៀនដើម្បីធានាដល់ការបង្រៀន រៀនស្របតាមបរិបទអប់រំថ្មី ។ បានរៀបចំឱ្យមានគោល

ការណ៍ប្រឡងប្រណាំងនាយកល្អ គ្រូល្អ ក្នុងស្មារតីឱ្យការងារដឹកនាំ និងគ្រប់គ្រងនៅតាមសាលារៀនកាន់តែមានភាពផុលផុស ហើយយើងបានលើករឿងទាំងនេះនៅក្នុងសន្និបាតអប់រំផងដែរ..."

( POE#.1.2 )

"...បានជួយឱ្យការគ្រប់គ្រងស្ថិតិបុគ្គលិកមានភាពងាយស្រួល ច្បាស់លាស់ រហ័ស ដោយមានប្រព័ន្ធគ្រប់គ្រងទិន្នន័យរវាងសាលា ការិយាល័យអប់រំស្រុក និងមន្ទីរដែលការណ៍នេះនាំឱ្យការស្នើតម្លើងឋានន្តរស័ក្ត ថ្នាក់ មានភាពច្បាស់លាស់ និងកាត់បន្ថយនូវបញ្ហាប្រឈមបានច្រើន..."

( DOP#.1.2.3 )

"...បានជួយសម្រួលការងារដល់គណៈគ្រប់គ្រងសាលាបានច្រើន តាមរយៈកម្មវិធីបណ្ដុះបណ្ដាល ឬការចែករំលែកនូវបទពិសោធន៍ល្អៗរបស់សាលាដែលមានស្នាដៃ ឬសាលាដែលមានការគាំទ្រពីអ្នកទទួលសេវា ។ លោកគ្រូ អ្នកគ្រូបានចែករំលែកចំណេះដឹងដែលខ្លួនមាន ពិសេសផ្នែកបច្ចេកវិទ្យាទៅដល់បុគ្គលិកអប់រំដទៃ ដើម្បីធ្វើយ៉ាងណាឱ្យការបង្រៀន-រៀនតាមបរិបទថ្មីកាន់តែទទួលលទ្ធផលល្អប្រសើរ..."

( Expert#.1.2 )

ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ពិតជាបានឆ្លើយតបដល់ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...បានធ្វើប្រឹក្សាអាជីពតាមរយៈអ្នកពាក់ព័ន្ធផ្នែកឧត្តមសិក្សា ពិសេសសកលវិទ្យាល័យដែលមានទីតាំងក្នុងខេត្ត ឬខេត្តក្បែរៗក្នុងតំបន់មកចែករំលែក ដើម្បីតម្រង់ទិសសិស្សនៅមធ្យមសិក្សា ។ ជាមួយគ្នានេះ មន្ត្រីនៅការិយាល័យជំនាញ បានចូលរួមនៅពេលមានការណែនាំដល់សិស្សតាមសាលារៀនលើការជ្រើសរើសជំនាញ ការត្រៀមលក្ខណៈផ្សេងៗ និងអ្វីដែលជាតម្រូវការ ជាក់ស្ដែងនៃទីផ្សារការងារនៅពេលដែលសាលាមានការប្រជុំផ្សព្វផ្សាយអាហារូបករណ៍ឧត្តមសិក្សា..."

( POE#.1.2 )

"...មានការណែនាំសិស្សដើម្បីតម្រង់ទិសដោយ ការិយាល័យជំនាញមានការិយាល័យមធ្យម ឬការិយាល័យក្រៅប្រព័ន្ធជាដើម ។ ការិយាល័យដែលពាក់ព័ន្ធបានរៀបចំគោលការណ៍សមស្របដើម្បីធ្វើយ៉ាង ណាបង្ករលក្ខណៈងាយស្រួលដល់សិស្ស និងស្របតាមតម្រូវការរបស់ឧត្តមសិក្សា..."

( DOP#.1.2.3 )

"...ការចេញសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្រោយពេលប្រឡងចប់បានទាន់ពេលវេលា ដើម្បីសិស្សអាចយកទៅប្រើប្រាស់បានបន្តតាមការចាំបាច់ជាក់ស្តែង ម្យ៉ាងទៀត មន្ទីរបានត្រឹមសម្របស្រួលទៅលើការផ្តល់ តែទិន្នន័យ ជាស្ថិតិសិស្ស ឬអាចថាជាស្ថានភាពនៃសាលាមធ្យមសិក្សាដែលមានសិស្សត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ប៉ុន្តែបញ្ហាផ្ទៃក្នុងរបស់ខាង ឧត្តមសិក្សាថ្នាក់មន្ទីរមិនអាចលូកដៃបានឡើយ ជាមួយគ្នានេះ មន្ទីរត្រូវសម្របសម្រួលធ្វើយ៉ាងណាជានា ដល់ការបញ្ចប់ការសិក្សានៅមធ្យមសិក្សាបានទាន់ពេលវេលាស្របតាមការណែនាំរបស់ថ្នាក់ក្រសួង..."

( Expert#.1.2 )

ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន ពិតជាបានឆ្លើយតបដល់ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ខាងក្រោមនេះ ជាទិន្នន័យដែល បានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...ធ្វើឱ្យមានការផុលផុសនូវសន្ទុះក្រុមយុវជន ឬយុវសហគ្រិនភាព និងបានធ្វើឱ្យក្រុមប្រឹក្សាកុមារ យុវជននៅថ្នាក់ខេត្ត មានការអភិវឌ្ឍប្រាជ្ញាស្មារតី ចំណេះដឹង បំណិន និងឥរិយាបថ តាមរយៈការផ្សព្វផ្សាយយ៉ាងទូលំទូលាយដើម្បីឱ្យពួកគេមានគំនិតច្នៃប្រឌិត ការបង្កើតថ្មី និងស្មារតីសហគ្រិនភាព ។ ជាមួយគ្នានេះ ថ្នាក់ខេត្តបានរៀបចំវគ្គខ្លីៗដើម្បីធ្វើការបណ្តុះបណ្តាលដល់យុវជនជាប្រចាំស្របទៅតាមគោលការណ៍យុវជនថ្នាក់ជាតិ..."

( POE#.1.2 )

"...បានចងក្រងក្រុមយុវជនតាមផ្នែក ដែលពួកគេទាំងនោះអាចជាផ្នែកមួយជួយដល់សកម្មភាពសង្គមកាន់តែល្អប្រសើរ ។ ក្រុមប្រឹក្សាកុមារ យុវជន នៅតាមសាលារៀន មានដំណើរការល្អប្រសើរ ដោយមានការយកចិត្តទុកដាក់ពីលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលា និងសហគមន៍..."

( DOP#.1.2.3 )

"...អាចរៀបចំក្រុមយុវជនបាន ដោយមានកញ្ចប់ថវិកាត្រឹមត្រូវ និងច្បាស់លាស់ដែលធានាដល់ស្ថេរភាពក្រុម ព្រមទាំងអាចសម្រេចបាននូវផែនការរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តដែលចង់ឱ្យយុវជនមានការអភិវឌ្ឍទាំងប្រាជ្ញាស្មារតី កាយសម្បទា ចេះចូលរួមក្នុងសកម្មភាពសង្គម ឱកាសបញ្ចេញមតិយោបល់ ការធ្វើសេចក្តីសម្រេចចិត្ត និងចេះរួមរស់ក្នុងសង្គមមួយប្រកបដោយសុខដុមនីយកម្ម ។ ជាមួយគ្នានេះ ឃើញមានសកម្មភាពចូលរួមរបស់ក្រុមកាកបាទក្រហម ក្រុមយុវជនកាយរិទ្ធិទៅលើ សកម្មភាពសង្គម ការផ្សព្វផ្សាយ និងការចូលរួមក្នុងកម្មវិធីផ្សេងៗ..."

( Expert#.1.2 )

ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍអប់រំកាយ និងកីឡា ពិតជាបានឆ្លើយតបដល់ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ខាងក្រោមនេះជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍ ៖

"...ធ្វើឱ្យមានការចូលរួមផុលផុសទាំងផ្នែករដ្ឋ និងឯកជនដោយបានពង្រីកវិសាលភាពគ្រប់ភូមិសិក្សា ដោយមានជាក្លិបកីឡា ក្រុមកីឡាមហាជន ព្រមទាំងមានកិច្ចសហការជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍក្នុងកិច្ចគាំទ្របច្ចេកទេស ដែលការណ៍នេះយើងអង្កេតឃើញថាទាំងក្រុមកុមារ និងយុវជនមានស្មារតីចូលរួម និងការយកចិត្តទុកដាក់ធ្វើលំហាត់ប្រាណដើម្បីសុខមាលភាព និងបណ្តុះដំនាញកីឡាមួយសម្រាប់ជីវិត..."

( POE#.1.2 )

"...មានលទ្ធភាពរៀបចំឱ្យមានក្រុម និងសកម្មភាពកីឡា ព្រោះមានកញ្ចប់ថវិកាគ្រប់គ្រាន់ទៅលើសកម្មភាពអប់រំកាយ និងកីឡាដែលធានាដល់ការចូលរួមរាល់សកម្មភាពចាំបាច់របស់ថ្នាក់ជាតិ ។ សកម្មភាពទាំងនោះបានពីកិច្ចខិតខំប្រឹងប្រែងរៀបចំចងក្រងរបស់ការិយាល័យជំនាញរបស់មន្ទីរ ព្រមទាំងមានការចូលរួមពីសំណាក់សិស្សានុសិស្ស មហាជន ដែលនាំឱ្យសកម្មភាពអប់រំកាយ និងកីឡាកាន់តែមានការវិវត្តរីកចម្រើនជាមួយការរៀបចំឱ្យមានការប្រកួតប្រជែងទាំងថ្នាក់សាលា ថ្នាក់ស្រុក ថ្នាក់ខេត្ត ក្នុងតំបន់ និងទូទៅប្រទេសជាដើម..."

( DOP#.1.2.3 )

"...ទទួលបានគ្រូដែលមានជំនាញឯកទេស តាមរយៈការឆ្លងកាត់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស តិចនិចល្អៗ ព្រមទាំងមានឆន្ទៈនៃការចូលរួមរបស់ក្រុមយុវជនឱ្យមានការប្រកួតប្រជែងទៅតាមការរៀបចំចាត់ចែងរបស់ការិយាល័យជំនាញ ។ ជាមួយគ្នានេះ នៅតាមសាលារៀនតម្រូវឱ្យមានការរៀបចំជា សេវាសម្រាប់ឱ្យមានសកម្មភាពទាំងផ្នែកទ្រឹស្តី និងអនុវត្តជាក់ស្តែង..."

( Expert#.1.2 )

ដើម្បីឱ្យការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកាន់តែល្អប្រសើរខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីការពេញចិត្ត របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...បន្តធ្វើ និងអនុវត្តផែនការឱ្យមានសង្គតិភាព ដាក់បញ្ចូលនូវយុទ្ធសាស្ត្រថ្មីៗតាមបរិបទសង្គមដាក់បញ្ចូលគោលនយោបាយអាទិភាពរបស់ក្រសួង បញ្ចូលជាតុចូលសមស្របនៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ( ពហុភាសា ) លើសពីនេះការធ្វើផែនការត្រូវឆ្លើយតបទៅនឹងបញ្ហា ប្រឈមជាក់ស្តែង មិនមែនជាបញ្ហាដែលកើតចេញពីការនិម្មិត ឬស្រមៃរបស់អ្នកធ្វើផែនការនោះទេ ដែលធ្វើយ៉ាងណាឱ្យផែនការរបស់សាលា របស់ស្រុក និងរបស់មន្ទីរត្រូវតែបន្សុីគ្នា..."

( POE#.1.2 )

"...ការរៀបចំផែនការត្រូវធ្វើទៅតាមយន្តការច្បាស់លាស់ និងមានការចូលរួមពីភាគីពាក់ព័ន្ធរវាងអង្គភាពសាមី ដៃគូអភិវឌ្ឍ ជាមួយគ្នានេះថ្នាក់ដឹកនាំមន្ទីរត្រូវតែដឹកនាំធ្វើផែនការ ដោយធានាថាផែនការនោះ ស្របតាមយុទ្ធសាស្ត្រ ព្រមទាំងមានការត្រួតពិនិត្យជាប្រចាំ ខែ ឆមាស និងប្រចាំឆ្នាំ..."

( DOP#.1.2.3 )

"...ការធ្វើផែនការត្រូវស្របតាមគោលនយោបាយ មានធ្វើការស្រាវជ្រាវប្រតិបត្តិ ត្រូវមានលក្ខណៈបរិយាបន្ន និងការអនុវត្តត្រូវប្រកបដោយប្រសិទ្ធភាព មានគណនេយ្យភាព សុច្ចរិតភាព ព្រមទាំងបរិស្ថានជំរុញដែលមានផ្នែកនយោបាយ ច្បាប់បទដ្ឋានគតិយុត្តិ ទិដ្ឋភាពផ្នែកសេដ្ឋកិច្ច ព្រមទាំង លក្ខខ័ណសង្គមដែលទាំងនេះសុទ្ធសឹងតែពាក់ព័ន្ធដល់ដំណើរការរៀបចំ និងអនុវត្តផែនការ..."

( Expert#.1.2 )

តារាង ៤.៨ សរុបស្ថានភាពនៃការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន ដែលទទួលបានពីការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលា មន្ត្រីនៅការិយាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្ត ៖

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ | 3.95 | **0.29** | ល្អ | **3.54** | **0.23** | ល្អ |
| ២ | ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន | 4.15 | **0.24** | ល្អ | **3.52** | **0.31** | ល្អ |
| ៣ | ចូលរួមសកម្មភាពលើការងារបង្រៀន និងរៀន | 4.03 | **0.31** | ល្អ | **3.36** | **0.22** | មធ្យម |
| ៤ | កសាងធនធានសមត្ថភាពគ្រូ និងសេវាជួយ សិស្ស | 4.01 | 0.36 | ល្អ | **3.36** | 0.28 | មធ្យម |
| ៥ | កសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន | 4.02 | **0.22** | ល្អ | **3.39** | **0.17** | មធ្យម |
| ៦ | កៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ | 3.89 | **0.18** | ល្អ | **3.25** | **0.26** | មធ្យម |
| ៧ | មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស | 3.65 | **0.17** | ល្អ | **3.10** | **0.21** | មធ្យម |

| | | | | | | |
|---|---|---|---|---|---|---|
| សរុប | **3.96** | **0.25** | **ល្អ** | **3.36** | **0.24** | **មធ្យម** |

តារាង៤.៨ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៩៦) ។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន" ក្នុងកម្រិត " ល្អ " (មធ្យមភាគ ពិន្ទុ=៤.១៥)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "មាតាបិតា និងសហគមន៍ជួយការសិក្សារបស់ សិស្ស" ក្នុងកម្រិត "ល្អ" (មធ្យមភាគ ពិន្ទុ= ៣.៦៥) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ស្ថានភាពនៃការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣៦)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ" ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ= ៣.៥៤) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ២.៦៩) ។

ផ្អែកលើលទ្ធផលស្រាវជ្រាវខាងលើ បានបង្ហាញឱ្យឃើញថា គណៈគ្រប់គ្រងសាលា មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំបានយល់ឃើញស្របគ្នាទៅលើ ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀនដែលមានប្រសិទ្ធភាពចាំបាច់ត្រូវអនុលោមទៅតាមសូចនាករគន្លឹះទាំង ៧ ដែលធ្វើឱ្យការអនុវត្តផែនការទទួលបាននូវភាពជោគជ័យ ឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង ។

ទិន្នន័យខាងលើបានបង្ហាញឱ្យឃើញថា ដើម្បីឱ្យការអនុវត្តផែនការរបស់សាលារៀនមួយទទួលបាននូវប្រសិទ្ធភាព ទាមទារចាំបាច់នូវការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារបស់នាយក ( ទទួលបានមធ្យមភាគពិន្ទុ ៤.១៥ ) ព្រមជា មួយមានការរៀបចំផែនការ និងអនុវត្តគោលនយោបាយបានល្អ ( ទទួលបានមធ្យមភាគពិន្ទុ ៣.៥៤ ) ។

"...នៅពេលដែលសាលាអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំបានល្អ នោះបង្ហាញឱ្យឃើញថាការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំខេត្តក៏ទទួលបានលទ្ធផលល្អផងដែរ ដោយសាលាគឺជាអ្នកអនុវត្ត ផ្ទាល់នូវផែនការស្របទៅតាមការណែនាំរបស់ស្រុក ថ្នាក់ខេត្ត និងក្រសួងជាដើម ។ ផ្ទុយទៅវិញប្រសិនបើ ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលាមិនបានល្អវិញ វាច្បាស់ជាមានផលជះដល់ការអនុវត្តផែន ការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរជាមិនខាន..."

( Expert#1.2 )

ជាមួយគ្នានេះដែរ ទិន្នន័យខាងលើក៏បានបង្ហាញដែរថា ការអនុវត្តផែនការរបស់សាលារៀន ទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៅលើ តួនាទីរបស់មាតាបិតា និងសហគមន៍ជួយការសិក្សា របស់សិស្ស ( ទទួលបានមធ្យមភាគពិន្ទុ ៣.១០ ) ដែលទាំងនេះសុទ្ធសឹង តែជាការយល់ឃើញរួមគ្នា របស់គណៈគ្រប់គ្រងសាលា មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ ស្រុក និងមន្ត្រីនៅការិយា ល័យចំណុះមន្ទីរអប់រំ ។ នាយកសាលាត្រូវយកចិត្តទុកដាក់ ទៅលើទំនាក់ទំនងជាមួយអាណាព្យាបាល សិស្ស សហគមន៍ អង្គការដៃគូ ភាគីពាក់ព័ន្ធ និងត្រូវមានកិច្ចសហការគ្នាល្អរវាងសាលានៅក្នុងភូមិសិក្សា ការិយាល័យអប់រំក្រុងស្រុក និងជាមួយមន្ទីរអប់រំខេត្ត ។

"...ពិបាកធ្វើឱ្យសម្រេចតាមផែនការ ដោយជាខេត្តដាច់ស្រយាលប្រមូលផ្តុំទៅដោយសិស្សជន ជាតិដើមភាគតិច មិនសូវមានការចូលរួមពីសំណាក់អាណាព្យាបាល សហគមន៍ដែលនាំឱ្យការបោះបង់ មានចំនួនខ្ពស់ ។ ជាដំណោះស្រាយ សុំឱ្យមានការចូលរួមគាំទ្រពេញលេញពីសំណាក់អាណាព្យាបាល សហគមន៍ ព្រមទាំងបរិស្ថានសាលារៀនត្រូវមានផាសុខភាព និងទាក់ទាញ..."

( DOP#.1.2.3 )

បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិមិនទទួលបាននូវលទ្ធផលល្អ ដែលទទួលបានពីការ ស្រាវជ្រាវបានបង្ហាញថា ការពិនិត្យតាមដាន និងវាយតម្លៃទៅលើកម្មវិធី ផែនការ ជាចំណុចមួយដែលទាម ទារឱ្យមានការយកចិត្តទុកដាក់ ។ ដូចនេះ ប្រសិនបើការពិនិត្យតាមដានមិនត្រូវបានយកចិត្តទុកដាក់ទេ នោះនាំឱ្យការអនុវត្តផែនការពុំទទួលបានលទ្ធផលសម្រេចទៅតាមពេលវេលា និងផែនការថវិកាឡើយ ។

ដូចនេះ ដើម្បីឱ្យការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំកាន់តែមានលក្ខណៈល្អប្រសើរឡើង គឺត្រូវទាមទារចាំបាច់នូវការរៀបចំផែនការ និងការអនុវត្តគោលនយោបាយអប់រំ ការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀន ចូលរួមសកម្មភាពលើការងារបង្រៀន និងរៀន កសាងធនធានសមត្ថភាពគ្រូ និងសេវាជួយសិស្ស កសាងធនធានរូបវន្ត និងបរិស្ថានសាលារៀន កៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុ មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស ព្រមទាំងត្រូវមានយន្តការពិនិត្យតាមដានច្បាស់លាស់ ។

ការពិភាក្សាត្រូវបានធ្វើឡើងអំពីលទ្ធផលនៃការស្រាវជ្រាវ ធៀបទៅនឹងរកគំហើញថ្មីចំពោះមន្ទីរអប់រំយុវជន និងកីឡាខេត្តដែលកំពុងអនុវត្តការងារស្របតាមបរិបទនៃប្រទេសកម្ពុជា ។ ផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវនេះ អនុសាសន៍មួយចំនួនត្រូវបានដាក់ចេញ ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហាដោយបង្ហាញពីតួនាទីភារកិច្ច របស់អង្គភាពពាក់ព័ន្ធ ។ ជាមួយគ្នានេះ សេចក្ដីសន្និដ្ឋាន នឹងលើកពីផលប៉ះពាល់របស់លទ្ធផលនៃការស្រាវជ្រាវ អាចមានផលជះដល់សាលារៀន ការិយាល័យអប់រំ យុវជន និងកីឡាស្រុកនៅទូទាំងខេត្ត ឬអាចមានឥទ្ធិពលទៅផ្នែកខាងក្រៅជាបន្តបន្ទាប់ ។ ជំពូកនេះ នឹងគ្រប់ដណ្ដប់ទៅលើបីចំណុចធំៗគឺ ទី១/ ការពិភាក្សា ទី២/ អនុសាសន៍ និងទី៣/ សេចក្ដីសន្និដ្ឋាន ដែលនឹងត្រូវបង្ហាញជូនដូចខាងក្រោម ៖

ផ្អែកនេះផ្ដោតទៅលើលទ្ធផលនៃការស្រាវជ្រាវ ដែលអ្នកស្រាវជ្រាវទទួលបានពីការបំពេញកម្រងសំណួរពីអ្នកពាក់ព័ន្ធ ៦១ នាក់ ដោយបានឆ្លើយទៅនឹងសំណួរស្រាវជ្រាវចំនួន ២ គឺទី១/ តើស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីមានប្រសិទ្ធភាពយ៉ាងដូចម្ដេចខ្លះ? និងទី២/ តើស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ជួបបញ្ហាប្រឈមយ៉ាងដូចម្ដេចខ្លះ? ជាលទ្ធផលមន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីបានអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំទទួលបានលទ្ធផលល្អបង្គួរ ពីព្រោះនៅក្នុងចំណោមសកម្មភាពសរុបដែល មានក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំចំនួន ១២៩ សកម្មភាព មន្ទីរបានអនុវត្តបានតែ ១០៦ សកម្មភាពប៉ុណ្ណោះ នៅសល់ចំនួន ២៣ សកម្មភាពមិនត្រូវបានអនុវត្តដោយសាក្នុងបរិបទកូវីដ១៩នេះថវិកាក្នុងមន្ទីរចំនួន ២៥ % ត្រូវបានរដ្ឋកាត់ ដែលនាំឱ្យសកម្មភាពមួយចំនួនមិនបានអនុវត្ត ( **របាយ**

**ការណ៍សមិទ្ធ កម្មប្រចាំឆ្នាំ ២០២០ របស់មន្ទីរអេនប់រំខេត្តរតនគិរី** ) សន្និបាតអប់រំឆ្នាំ ២០២០ បានលើកទិសដៅ ១៨២ ក្នុងនោះទិសដៅកំណែទម្រង់សំខាន់ៗមានចំនួន ៥១ ទិសដៅអនុវិស័យមានចំនួន ៧៦ និងទិស ដៅឆ្លងអនុវិស័យ មានចំនួន ៥៥ ។ ទិសដៅអនុវត្តចប់មានចំនួន ៨៦ ស្មោះនឹង ៤៧.៣ ភាគរយ កំពុងអនុវត្តមានចំនួន ៧៧ ស្មើនឹង ៤២.៣ ភាគរយ និងមិនបានអនុវត្តមានចំនួន ១៩ ស្មើនឹង ១០.៤ ភាគរយ ( **សន្និបាតបូក សរុបការងារអេប់រំយុវជន និងកីឡាឆ្នាំ ២០១៩-២០២០** ) ។

ជាមួយគ្នានេះដែរ ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរ អប់រំយុវជន និងកីឡាខេត្តរតនគិរីទទួលបានប្រសិទ្ធភាព ដោយហេតុថាគណៈគ្រប់គ្រងតាមសាលារៀន ដែលជាអង្គភាពមួយធ្វើសកម្មភាពដោយផ្ទាល់ជាមួយអ្នកទទួលសេវា បានអនុវត្តតួនាទីភារកិច្ចស្របទៅតាមផែនការដែលបានរៀបចំការអនុវត្តភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀនទទួលបានលទ្ធផលល្អ ដោយបានកសាងផែនការតាមដំណាក់កាល លោកគ្រូ អ្នកគ្រូមានការយោគយល់អាធ្យាស្រ័យ មិនប្រកាន់បក្សពួក អនុវត្តតួនាទីទៅតាមភារកិច្ចចាត់តាំង ការចូលរួមសកម្មភាពបង្រៀន និងរៀនបានផុលផុស ដោយអនុវត្តទៅតាមកម្មវិធីសិក្សាផ្តល់តម្លាភាព ក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងបានកសាងធនធានរូបវន្ត និងបរិស្ថានសាលារៀនកាន់តែមានភាពទាក់ទាញ ដែលទាំងនេះជាផ្នែកមួយដែល ស្ថិតនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ហើយផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន គឺបានបន្សុីគ្នាជាមួយផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ស្រុក ព្រមទាំងផែនការរបស់មន្ទីរផងដែរ ។ ទន្ទឹមនឹងនេះក៏មានបញ្ហាប្រឈមផងដែរ ដោយពេលធ្វើកំណែទម្រង់ធនធានថវិកា ហើយយើងបានដាក់ថវិកានោះបញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ វាទាមទារឱ្យមានការវិនិយោគច្រើនជាងនេះ ដែលជាបញ្ហាដល់ការអនុវត្តផែនការមិនទទួលបានលទ្ធភលដូចការរំពឹងទុក ។ ជាមួយគ្នានេះ ខាងថ្នាក់មន្ទីរខ្វះខាត់ធនធានដែលមានសមត្ថភាព និងយន្តការគាំទ្រមិនទាន់ពេញលេញ ព្រមទាំងធនធាននៅមន្ទីរមានចំនួនតិចមិនទានឆ្លើយតបទៅនឹងផ្នែកនៃការងារ និងខ្វះសមត្ថភាពធន ធានជំនាញ ម្យ៉ាងវិញទៀតថ្នាក់មន្ទីរហាក់មិនបានធ្វើការស្រាវជ្រាវច្បាស់លាស់ទៅលើអ្វីដែលជាតម្រូវការ ជាក់ស្តែងរបស់សាលារៀន ដែលនាំឱ្យការចុះជួយមិនចំគោលដៅ ។ ក្នុងន័យនេះ មន្ត្រីជំនាញរបស់មន្ទីរអេប់រំយុវជន និងកីឡាដែលទទួលបន្ទុកផែនការ និងគណនេយ្យត្រូវ

ធ្វើការបណ្តុះបណ្តាលបន្តដល់គណៈគ្រប់គ្រងសាលា បុគ្គលិក ដែលទទួលបន្ទុកកិច្ចការផែនការ គណនេយ្យតាមសាលារៀន ហេតុវិនិច្ឆ័យអប់រំ ការគ្រប់គ្រងកម្មវិធី គម្រោងអប់រំ ការកំណត់គោលនយោបាយអប់រំ ការអនុវត្តផែនការ ការពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង ការបង្កើតក្របខ័ណ្ឌកម្មវិធីដែលមានសូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃផែនការ ។ សមត្ថភាពរបស់មន្ត្រីទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុតាមរាជធានីខេត្តនៅមានកម្រិត ដែលទាមទារឱ្យមានការបណ្តុះបណ្តាលជាប្រចាំ ( **ក្រសួងអប់រំយុវជន និងកីឡា ២០២០** ) ។ បើទោះបីជា យ៉ាងណាក៏ដោយ នាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការបានខិតខំរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលជាច្រើនស្តីពីគោលការណ៍ហិរញ្ញវត្ថុ ការរៀបចំកសាងផែនការ ការអនុវត្តផែនការ ការពិនិត្យតាមដាន និងវាយតម្លៃ ការធ្វើរបាយការណ៍សមិទ្ធកម្មដល់ថ្នាក់មន្ទីរ ថ្នាក់ការិយាល័យអប់រំយុវជន និងកីឡាស្រុក ព្រមទាំងថ្នាក់សាលាដែលជាអ្នកអនុវត្តផ្ទាល់ជាមួយអ្នកទទួលសេវាផងដែរ ។ តម្រូវការបណ្តុះបណ្តាលមន្ត្រីតាមអង្គភាពនីមួយៗត្រូវតែធ្វើឡើង ពីព្រោះបញ្ហាដែលកើតមានឡើងបណ្តាលមកពីសមត្ថភាពមន្ត្រីធ្វើផែនការតាមគោលការណ៍ និងស្តង់ដាមិនដូចគ្នា ( McConnell. 2003 )។

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពនីមួយៗ អាចប្រែប្រួលទៅតាមលក្ខខ័ណ្ឌកំណត់ជាច្រើន ហើយភាគរយនៃការអនុវត្តក៏ប្រែប្រួលទៅតាមនោះដែរ ។ ឧទាហរណ៍ ក្នុងឆ្នាំ ២០២០ កន្លងទៅតាមរបាយការណ៍បានបង្ហាញថា មានខេត្តចំនួន ៣ ដែលបានអនុវត្តផែនការចប់ ១០០ ភាគរយ ក្នុងនោះរួមមានខេត្ត ព្រះវិហារ ខេត្តព្រៃវែង និងខេត្តកំពត ។ ៦ រាជធានី/ខេត្ត បានអនុវត្តចប់លើសពី ៩០ ភាគរយរួមមានខេត្តកំពង់ចាម ព្រះសីហនុ ប៉ៃលិន សៀមរាប និងរាជធានីភ្នំពេញ ។ ដោយឡែកខេត្តកោះកុង អនុវត្តបានតិចជាងគេបានត្រឹមតែ ៦៦.០ ភាគរយ និងមិនបានអនុវត្ត ៣៤.០ ភាគរយ ( **សន្និបាតបូកសរុបការងារអប់រំយុវជន និងកីឡាឆ្នាំ ២០១៩-២០២០** )។

ជាមួយគ្នានេះដែរ មានអ្នកចូលរួមមួយចំនួនតូចបានលើកឡើងថា ពួកគេនៅមិនទាន់ពេញចិត្តទាំងស្រុកទៅនឹងលទ្ធផលសម្រេចបានរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីនៅឡើយទេ ដោយសំអាងថា

"...ការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តមិនទាន់ទទួលបាន ចំណាត់ថ្នាក់ល្អប្រសើរនៅឡើយទេគឺបានត្រឹមចន្លោះពិន្ទុ ៧៥-៧៩ ដែលការណ៍នេះអាចមកពីបញ្ហាផ្ទៃក្នុងមួយចំនួនដែលអាច នាំឱ្យគុណភាពផែនការប្រតិបត្តិប្រចាំឆ្នាំនៅមានកម្រិត..."

( DOP#.1.2.3 )

ហើយសកម្មភាពមួយចំនួនមិនត្រូវទៅតាមផែនការដែលបានគ្រោងទុក ដែលនាំឱ្យលទ្ធផលគ្រោងទុកមានមិនឆ្លើយតបទៅនឹងចំណុចដៅប្រចាំឆ្នាំរបស់មន្ទីរដែលបានកំណត់ ។ មានអង្គភាពនៅថ្នាក់ក្រោមជាតិមួយចំនួនដែលមិនបានអនុវត្តផែនការបាន ១០០ ភាគរយ ហើយស្ថិតនៅក្រោម ៩០ ភាគរយ មានខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តស្វាយរៀងជាដើម ។ ក្នុងន័យនេះ អាចបណ្តាលមកពីហេតុផលណាមួយដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្ត ដែលអាចមកពីចំនួនមន្ត្រីនៅតាមការិយាល័យជំនាញក្នុងមន្ទីរ មានចំនួនតិចពេកធៀបជាមួយចំនួនសកម្មភាព និងថវិកាដែលបានគ្រោង និងមានសកម្មភាពថ្មីច្រើន ដែលទាមទារឱ្យមានការធ្វើនិយ័តថវិកាពីខ្ទង់មួយទៅខ្ទង់មួយទៀត ដើម្បីអាចចាយបាន ឬថវិកាដែលធ្លាក់មកមិនទាន់តាមក្របខ័ណ្ឌពេលវេលា និងផែនការដែលបានគ្រោងទុក ។ ទោះបីជាយ៉ាងណាក៏ដោយការណ៍នេះជាបទពិសោធន៍របស់មន្ទីរនីមួយៗ ហើយក៏ជាភាពបត់បែនមួយរវាងមន្ទីរសាមី និងមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុក្នុងប្រតិបត្តិការចាយវាយថវិកាទាំងរដ្ឋ និងដៃគូ ។ ក្នុងបរិបទកូវីដ១៩ មន្ទីរអប់រំយុវជន និងកីឡាជាច្រើនមានបទពិសោធន៍ និងបច្ចេកទេសល្អៗក្នុងការបត់ បែនទៅលើការគ្រោងថវិកា និងការចាយវាយថវិកាស្របទៅតាមបរិបទរបស់សង្គម និងតម្រូវការសកល ។

ចំណុចអវិជ្ជមាន ឬចំណុចខ្សោយដែលបានកើតឡើងដែលទាមទារឱ្យមន្ត្រីជំនាញទាំងអស់ត្រូវបន្តការយកចិត្តទុកដាក់ដែលរួមមានការបង្កើតក្របខ័ណ្ឌកម្មវិធី ដែលមានសូចនាករពិនិត្យតាមដាន និងវាយតម្លៃ ការកំណត់យុទ្ធសាស្ត្រអប់រំ និងរៀបចំផែនការរយៈពេលវែង និងមធ្យមជាដើម ។ បញ្ហានេះអាចបណ្តាលមកបីមន្ត្រីជំនាញតាមការិយាល័យមិនធ្លាប់មានបទពិសោធន៍ អ្នកចូលរួមទទួលការបណ្តុះបណ្តាលមិនមែនជាអ្នកធ្វើផែនការ មានការផ្លាស់ប្តូរអ្នកទទួលបន្ទុកកាន់កិច្ចការ ឬផែនការនោះញឹកញាប់ ហើយការរៀបចំផែនការនោះមិនមានការពិនិត្យតាមដាន និងវាយតម្លៃទៅលើប្រសិទ្ធនៃការអនុវត្ត ។

ប្រសិទ្ធភាពនៃការអនុវត្តផែនការមួយជោគជ័យ អាស្រ័យលើលក្ខណៈអំណោយផល កត្តាវិជ្ជមាន ឬបញ្ហាប្រឈម ។ ក្នុងន័យនេះ ប្រសិនបើអង្គភាពមួយមានលក្ខខ័ណ្ឌអំណោយផលច្រើនជាងបញ្ហាប្រឈមមានន័យថាការអនុវត្តផែនការនោះ និងទទួលបានប្រសិទ្ធភាពស្របតាមចំណុចដៅរបស់អង្គភាពជាមិនខាន់ ។ នៅក្នុងលទ្ធផលសម្រេចបានបង្ហាញពីអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦០.៧០ ភាគរយ កើន ០.៨០ ភាគរយ ស្រី ៦៦.៦០ ភាគរយ កើន ១.៥០ ភាគរយ ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៥៧.៤០ ភាគរយ ស្រី ៦៣.២០ ភាគរយ និងឯកជន ៣.៣០ ភាគរយ ស្រី ៣.៤០ ភាគរយ ។ អត្រាឆ្លងភូមិសិក្សានៅមធ្យមសិក្សាបឋមភូមិ ៨១.៣០ ភាគរយ កើន ៦.៤០ ភាគរយ ស្រី ៨២.៤០ ភាគរយ កើន ៣.៨០ ភាគរយ ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ៣២.២០ ភាគរយ កើន ១.៣០ ភាគរយ ស្រី ៣៦.៤០ ភាគរយ កើន ១.៣០ ភាគរយ ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៣០.១០ ភាគរយ ស្រី ៣៤.២០ ភាគរយ និងឯកជន ២.១០ ភាករយ ស្រី ២.២០ ភាគរយ ( **សន្និបាតបូកសរុបការងារអប់រំយុវជន និងកីឡាឆ្នាំ ២០១៩-២០២០** )។

តម្រូវការធនធានមនុស្សពិសេសមន្ត្រីជំនាញនៅតាមការិយាល័យ ដើម្បីអនុវត្តផែនការសកម្មភាពដែលបានគ្រោងទុកឱ្យទាន់ពេលវេលា ព្រមទាំងលទ្ធផលដែលសម្រេចបានប្រកបដោយប្រសិទ្ធភាពស្របទៅតាមចំណុចដៅប្រចាំឆ្នាំ ។ បុគ្គលិកអប់រំសរុបចំណុះឱ្យមន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីសរុបមានចំនួន ១៥៣២ នាក់ ក្នុងនោះស្រី ៦៥២ នាក់ ( ***របាយការណ៍សមិទ្ធកម្មនៃមន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្នាំ ២០២០*** ) ។ ជាក់ស្តែងមន្ត្រីជំនាញតាមការិយាល័យនៅក្នុងមន្ទីរអប់រំយុវជន និង កីឡាខេត្តរតនគិរី បច្ចុប្បន្នមានចំនួន ៤៩ នាក់ ស្រី ១៣ នាក់ ( ***របាយការណ៍សមិទ្ធកម្មនៃមន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្នាំ ២០២០*** ) ។ ចំនួននេះមិនទាន់ឆ្លើយតបទៅនឹងទំហំនៃការងារនៅឡើយទេ អាចរាំងស្ទះដល់លំហូការងារ ប៉ះពាល់ដល់ប្រសិទ្ធភាព និងគុណភាពអប់រំ ដែលទាមទារឱ្យមានការយក ចិត្តទុកដាក់ ពង្រឹងសមត្ថភាពមន្ត្រីជំនាញតាមផ្នែក ទាំងបរិមាណ និងគុណភាពមន្ត្រីឱ្យបានគ្រប់គ្រាន់ ស្របតាមគោលការណ៍ និងសេចក្តីណែនាំរបស់ក្រសួង ។

## ៤. ៣ បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ

### ៤.៣.១ ទិន្នន័យតាមបែបបរិមាណវិស័យ ពីគណៈគ្រប់គ្រងសាលា មន្ត្រីការិយាល័យអប់រំស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរអប់រំខេត្ត

ជាមួយគ្នានេះ លទ្ធផលនៃការស្រាវជ្រាវឆ្លុះបញ្ចាំងពីចម្លើយទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចខាងលើ ។ លទ្ធផលទាំងនេះកើតចេញពីទិន្នន័យដើម ដែលអ្នកចូលរួមបានបំពេញកម្រងសំណួរដែលអ្នកស្រាវជ្រាវបានចែកជូនទៅតាមមុខសញ្ញាដែលបានកំណត់។ គំនិតយោបល់ ការយល់ឃើញរបស់អ្នកចូលរួម ត្រូវបានយកមកវិភាគស្របទៅតាមវត្ថុបំណងនៃការស្រាវជ្រាវ ដើម្បីធ្វើឱ្យលទ្ធផលមានលក្ខណៈវិទ្យាសាស្ត្រ និងអាចទទួលយកបាន ។ គំនិតយោបល់ ការយល់ឃើញរបស់អ្នកចូលរួម វិធីសាស្ត្រស្រាវជ្រាវ ការបញ្ចូលទិន្នន័យ វិធីវិភាគទិន្នន័យ និងចំនួនសំណាក ត្រូវបានពូនផ្តុំបង្កើតបានជាលទ្ធផលស្រាវជ្រាវឆ្លើយតបទៅនឹងប្រធានបទដូចខាងក្រោម ៖

តារាងទិន្នន័យខាងក្រោមនេះ បានបង្ហាញពីមធ្យមភាគសរុបនៃការឆ្លុះបញ្ចាំងពីបញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់របស់សាលារៀននាឆ្នាំកន្លងមក ។

**តារាង៤.៩ ៖ ការកំណត់គោលនយោបាយអប់រំ**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | ហេតុវិនិច្ឆ័យវិស័យអប់រំ | 3.36 | 0.79 | មធ្យម | 3.16 | 0.77 | មធ្យម |
| ២ | កំណត់ជម្រើសគោលនយោបាយដោយផ្អែកលើហេតុវិនិច្ឆ័យ | 3.59 | 0.73 | ល្អ | 3.25 | 0.76 | មធ្យម |
| ៣ | កំណត់យុទ្ធសាស្ត្រអប់រំ | 3.50 | 0.60 | ល្អ | 3.50 | 0.76 | ល្អ |
| សរុប | | **3.48** | **0.10** | **ល្អ** | **3.30** | **0.01** | **មធ្យម** |

តារាង៤.៨ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការកំណត់គោលនយោបាយ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៤៨)។ សូចនាករទទួលបានពិន្ទុ

ខ្ពស់ជាងគេគឺ"កំណត់ជម្រើសគោលនយោបាយដោយផ្អែកលើហេតុវិនិច្ឆ័យ"ក្នុងកម្រិត"ល្អ" (មធ្យមភាគពិន្ទុ=៣.៥៩)។ សូចនាករទទួលបានពិន្ទុទាបជាងគេ គឺ "ហេតុវិនិច្ឆ័យវិស័យអប់រំ" ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣៦)។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការកំណត់គោលនយោបាយ** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣០)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " កំណត់យុទ្ធសាស្ត្រអប់រំ " ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ=៣.៥០) ។ សូចនាករដែល ទទួលបានពិន្ទុទាបជាងគេគឺ "ហេតុវិនិច្ឆ័យវិស័យអប់រំ" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ៣.១៦)។

**តារាង៤.១០ ៖ ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | ហេតុវិនិច្ឆ័យវិស័យអប់រំ | 2.95 | 0.79 | មធ្យម | 3.13 | 0.94 | មធ្យម |
| ២ | កំណត់ជម្រើសគោលនយោបាយដោយផ្អែកលើហេតុវិនិច្ឆ័យ | 3.82 | 0.73 | ល្អ | 3.59 | 1.07 | ល្អ |
| ៣ | កំណត់យុទ្ធសាស្ត្រអប់រំ | 4.05 | 0.79 | ល្អ | 3.72 | 1.05 | ល្អ |
| ៤ | រៀបចំកម្មវិធី ឬគម្រោងអប់រំ | 3.64 | 0.66 | ល្អ | 3.19 | 0.82 | មធ្យម |
| សរុប | | **3.61** | **0.06** | **ល្អ** | **3.41** | **0.12** | **ល្អ** |

តារាង៤.១០ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការ រៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៦១)។ សូចនាករទទួល បានពិន្ទុខ្ពស់ជាងគេគឺ "ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០៥)។ សូចនាករទទួលបានពិន្ទុទាបជាងគេ គឺ "បង្កើតគំរូ (simulation)" ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ២.៩៥)។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨១)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " កំណត់យុទ្ធសាស្ត្រអប់រំ " ក្នុងកម្រិត " ល្អ " (មធ្យមភាគ ពិន្ទុ=៣.៧២) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "ហេតុវិនិច្ឆ័យវិស័យអប់រំ" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ៣.១៣)។

**តារាង៤.១១ ៖ ការអនុវត្តផែនការ**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ | 4.23 | 0.81 | ល្អណាស់ | 3.94 | 1.11 | ល្អ |
| ២ | ការរៀបចំផែនការថវិកាប្រចាំឆ្នាំ | 4.05 | 0.84 | ល្អ | 3.97 | 1.12 | ល្អ |
| ៣ | គ្រប់គ្រងកម្មវិធី និងគម្រោង | 3.73 | 0.83 | ល្អ | 3.34 | 0.97 | មធ្យម |
| សរុប | | **4.00** | **0.02** | **ល្អ** | **3.75** | **0.08** | **ល្អ** |

តារាង៤.១១ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការអនុវត្តផែនការ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.០០)។ សូចនាករទទួល បានពិន្ទុខ្ពស់ជាងគេគឺ "ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.២៣)។ សូចនាករទទួលបានពិន្ទុទាបជាងគេ គឺ "គ្រប់គ្រងកម្មវិធី និងគម្រោង" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៧៣)។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ការអនុវត្តផែនការ** ក្នុងកម្រិត "ល្អ" (មធ្យមភាគ ពិន្ទុ= ៣.៧៥)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " ការរៀបចំផែនការថវិកាប្រចាំឆ្នាំ " ក្នុងកម្រិត " ល្អ " (មធ្យមភាគ ពិន្ទុ=៣.៩៧) ។ សូចនាករដែល ទទួលបានពិន្ទុទាបជាងគេគឺ "គ្រប់គ្រងកម្មវិធី និងគម្រោង" ក្នុងកម្រិត "មធ្យម" (មធ្យមភាគ ពិន្ទុ= ៣.៣៤)។

តារាង៤.១២ ៖ **ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង**

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | បង្កើតក្របខណ្ឌកម្មវិធីដែលមានសូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | 3.32 | 0.78 | មធ្យម | 3.00 | 1.02 | មធ្យម |
| ២ | ប្រមូលទិន្នន័យ ដំណើរការ និងវិភាគទិន្នន័យ | 3.50 | 0.74 | ល្អ | 3.13 | 0.98 | មធ្យម |
| ៣ | តាមដានប្រតិបត្តិការថវិកា | 3.77 | 0.87 | ល្អ | 3.56 | 1.11 | ល្អ |
| សរុប | | **2.35** | **0.07** | ខ្សោយ | **2.26** | **0.07** | ខ្សោយ |

តារាង៤.១២ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង** ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគពិន្ទុ= ២.៣៥)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "តាមដានប្រតិបត្តិការថវិកា" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៧៧)។ សូចនាករទទួលបានពិន្ទុទាបជាងគេ គឺ "សូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង" ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣២)។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង** ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគពិន្ទុ= ២.២៦)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "តាមដានប្រតិបត្តិការថវិកា" ក្នុងកម្រិត "ល្អ" (មធ្យម ភាគពិន្ទុ= ៣.៥៦)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "បង្កើតក្របខណ្ឌកម្មវិធីដែលមានសូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង" ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.០០)។

### ៤.៣.២ ទិន្នន័យតាមគុណវិស័យ ពីបញ្ហាប្រឈមនៅការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ( ទិន្នន័យបានពីប្រធាន-អនុប្រធាន មន្ទីរអប់រំយុវជន និងកីឡា ខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ )

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំពិតជាមិនអាចជៀសផុតពីបញ្ហាប្រឈមឡើយ ។ ខាងក្រោមនេះជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហាប្រឈមនានា របស់ប្រធាន-អនុប្រធាន មន្ទីរអប់រំយុវជន និងកីឡាខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...មានបញ្ហាដោយពេលយើងធ្វើកំណែទម្រង់ ធនធានថវិកាដែលយើងមានហើយបានដាក់បញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ វាទាមទារឱ្យមានការវិនិយោគច្រើនជាងនេះ ។ ជាដំណោះស្រាយយើងនឹងគិតគូពិនិត្យលើការគ្រោងថវិកាឱ្យបានល្អប្រសើរជាមួយអ្នកពាក់ព័ន្ធទាំងរដ្ឋ និងឯកជននៅពេលវេលាសមស្រប..."

( POE#.1.2 )

"...ខ្វះខាតធនធានដែលមានសមត្ថភាព និងយន្តការគាំទ្រនៅមានកម្រិត និងមិនទាន់បានពេញលេញ ។ ជាដំណោះស្រាយត្រូវរៀបចំធ្វើការបណ្តុះបណ្តាលមន្ត្រីនៅតាមការិយាល័យ ដើម្បីឱ្យពួកគាត់មានជំនាញឆ្លើយតបក្នុងការអនុវត្តការងារឱ្យមានប្រសិទ្ធភាព..."

( DOP#.1.2.3 )

"...ធនធាននៅមន្ទីរមានចំនួនតិចមិនទានឆ្លើយតបទៅនឹងផ្នែកនៃការងារ និងខ្វះសមត្ថភាពធនធានជំនាញ ម្យ៉ាងវិញទៀតថ្នាក់មន្ទីរហាក់មិនបានធ្វើការស្រាវជ្រាវច្បាស់លាស់ទៅលើអ្វីដែលជាតម្រូវការជាក់ស្តែងរបស់សាលារៀន ដែលនាំឱ្យការចុះជួយមិនចំគោលដៅ ។ ជាមួយគ្នានេះ គួរមានការប្រជុំរវាងអ្នកពាក់ព័ន្ធដែលមានបញ្ហាដើម្បីស្វែងរកដំណោះស្រាយសមស្រប..."

( Expert#.1.2 )

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងការសិក្សានៅកម្រិតសាលារៀន ពិតជាមិនអាចជៀសផុតពីបញ្ហាប្រឈមឡើយ ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហាប្រឈមនានា របស់ប្រធាន-អនុប្រធាន មន្ទីរអប់រំយុវជន និងកីឡាខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍ

"...លទ្ធផលការសិក្សារបស់សិស្សមិនទាន់ឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុក ដោយសមត្ថភាពគណៈគ្រប់គ្រងនៅសាលាខ្លះនៅមានកម្រិត ទាំងបច្ចេកទេស និងគោលការណ៍ថ្មីៗ ហើយលោកគ្រូ អ្នកគ្រូមួយចំនួនបំពេញការងារទៅតាមតែសេវា ការចាត់តាំង ការរុញពីក្រោយ ដោយបំពេញការងារមិនទាន់ចេញពីចិត្ត និងបេះដូង ។ លើកទឹកចិត្តឱ្យពួកគាត់បង្កើនគុណវុឌ្ឍិ បំប៉នសមត្ថភាពបន្ថែម ព្រមទាំងរៀបចំឱ្យមានការធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ចំពោះសាលា ឬគ្រូដែលមានស្នាដៃល្អ ឬមានការគាំទ្រច្រើនពីអ្នកទទួលសេវា..."

( POE#.1.2 )

"...ពិបាកធ្វើឱ្យសម្រេចតាមផែនការ ដោយជាខេត្តដាច់ស្រយាលប្រមូលផ្តុំទៅដោយសិស្សជនជាតិដើមភាគតិច មិនសូវមានការចូលរួមពីសំណាក់អាណាព្យាបាល សហគមន៍ដែលនាំឱ្យការបោះបង់មានចំនួនខ្ពស់ ។ ជាដំណោះស្រាយ សុំឱ្យមានការចូលរួមគាំទ្រពេញលេញពីសំណាក់អាណាព្យាបាលសហគមន៍ ព្រមទាំងបរិស្ថានសាលារៀនត្រូវមានផាសុខភាព និងទាក់ទាញ..."

( DOP#.1.2.3 )

"...អត្រាសិស្សជាប់ អត្រាសិស្សឆ្លងភូមិសិក្សាមានការធ្លាក់ចុះ ដោយសាលាហាក់ដូចជាមិនទាន់បានត្រៀមលក្ខណៈគ្រប់គ្រាន់ឆ្លើយតបទៅនឹងការផ្តល់ការអប់រំនៅបរិបទថ្មីទាំងសិស្ស គ្រូ គណៈគ្រប់គ្រងសាលាព្រមទាំងអាណាព្យាបាលផងដែរ ដែលជាហេតុនាំឱ្យលទ្ធផលសិក្សាមិនទាន់ទទួលយកបានទាំងបរិមាណ និងគុណភាព ម្យ៉ាងវិញទៀតខ្វះធនធានជំនាញបច្ចេកវិទ្យាទាំងនៅថ្នាក់មន្ទីរ សាលារៀន ព្រមទាំងសម្ភារគាំទ្រដល់ការបង្រៀន រៀនពីចម្ងាយ ។ ប្រការនេះជំរុញឱ្យភាគីពាក់ព័ន្ធត្រូវតែមានការចូលរួមឱ្យបានផុសផុលធ្វើយ៉ាងណាឱ្យបរិយាកាសការងារកាន់តែមានភាពល្អប្រសើរឡើង..."

( Expert#.1.2 )

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលនៅកម្រិតសាលារៀន ពិតជាមិនអាចជៀសផុតពីបញ្ហាប្រឈមឡើយ ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហាប្រឈម នានា របស់ប្រធាន-អនុប្រធាន មន្ទីរអប់រំយុវជន និងកីឡាខេត្តមន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...គណៈគ្រប់គ្រងសាលាមួយចំនួននៅមានភាពស្ពឹកស្រពន់ និងមិនព្រមអភិវឌ្ឍខ្លួនឱ្យសមស្របទៅនឹងរបៀបនៃការបំពេញការងារតាមបរិបទថ្មីនៅឡើយ ព្រមទាំងខ្វះស្មារតីចូលរួម ។ ជាដំណោះស្រាយល្អ យើងត្រូវរៀបចំផែនការជាក់លាក់ និងដោយធ្វើផែនការស្រាវជ្រាវប្រតិបត្តិមួយដើម្បីរកឱ្យឃើញនូវអ្វីដែលជាតម្រូវការចាំបាច់របស់សាលារៀន ធៀបជាមួយយុទ្ធសាស្ត្រកំណែទម្រង់ថ្នាក់ជាតិ ដើម្បីរកវិធីសាស្ត្រដោះស្រាយឱ្យបានទាន់ពេលវេលា..."

( POE#.1.2 )

"...មន្ទីរហាក់ដូចជាក្តាប់បញ្ហារបស់សាលារៀន ការិយាល័យអប់រំស្រុក មិនបានដោយសារមន្ត្រីនៅតាមការិយាល័យជំនាញក្នុងមន្ទីរមានចំនួនតិច ព្រមទាំងខ្វះខាតមន្ត្រីពិនិត្យតាមដាន ហើយថវិកានៅតាមការិយាល័យសម្រាប់ចុះធ្វើសកម្មភាពមានចំនួនតិច ។ បញ្ហាខាងលើ មន្ទីរគួរមានមន្ត្រីគ្រប់គ្រាន់ព្រមទាំងជាមន្ត្រីដែលមានសមត្ថភាពដើម្បីចុះពិនិត្យតាមដានសកម្មភាពការងារក្រោមឱវាទ ព្រមទាំងមានថវិកាគាំទ្រឆ្លើយតបទៅនឹងសកម្មភាពទាំងនោះ..."

( DOP#.1.2.3 )

"...មន្ត្រីជំនាញតាមការិយាល័យនៅមន្ទីរមានចំនួនតិច នៅពេលមានការកែទម្រង់តម្រូវឱ្យមានកម្មវិធីបណ្តុះបណ្តាលច្រើននៅតាមការិយាល័យស្រុក សាលារៀន ។ នៅក្នុងបរិបទការងារថ្មីនេះ ថ្នាក់ជាតិត្រូវយកចិត្តទុកដាក់ចុះបណ្តុះបណ្តាលមន្ត្រីជំនាញទទួលបន្ទុក ដើម្បីឱ្យពួកគេអាចយកទៅចែករំលែកបន្តដល់អ្នកពាក់ព័ន្ធ..."

( Expert#.1.2 )

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្រិតសាលារៀន ពិតជាមិនអាចជៀសផុតពីបញ្ហាប្រឈមឡើយ ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហាប្រឈមនានារបស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...មន្ត្រីទទួលបន្ទុកផ្នែកហិរញ្ញវត្ថុនៅតាមអង្គភាពក្រោមឱវាទមួយចំនួនជាមន្ត្រីថ្មី ហើយប្រព័ន្ធគ្រប់គ្រងថវិកា គឺគេប្រើតាមបច្ចេកវិទ្យាដូចនេះមានបញ្ហាលំបាក ហើយការបែងចែក និងការប្រើប្រាស់ថវិកានៅតាមសាលារៀនហាក់ដូចជាមិនទាន់ស្របទៅនឹងការណែនាំ ឬអាចនិយាយបានថា អ្នកចូលរួមទទួលការបណ្តុះបណ្តាល មិនមែនជាអ្នករៀបចំ និងធ្វើផែនការនោះទេ មួយវិញទៀតមួយរយៈនេះខាងថ្នាក់ក្រសួងហាក់រង្វើលក្នុងការចុះអធិការកិច្ច ដែលនាំឱ្យសាលាមួយចំនួនអាចនៅបន្តធ្វើខុសដដែលៗ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ មន្ត្រីនៅការិយាល័យជំនាញរបស់មន្ទីរត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងរកដើមចមឱ្យបានច្បាស់លាស់ រៀបចំផែនការដើម្បីបណ្តុះបណ្តាលដល់សាលា ឬមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុដើម្បីឱ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព..."

( POE#.1.2 )

"...ថវិកាទំលាក់មិនទាន់ពេលវេលា ហើយសាលាខ្លះអនុវត្តថវិកាមិនអស់ ព្រមទាំងនីតិវិធីចាយវាយ លុយនៅតាមសាលារៀនមិនទាន់សមស្រប ដែលនាំឱ្យបានបញ្ហាដល់ការិយាលល័យជំនាញរបស់មន្ទីរ ។ ជាមួយគ្នានេះ ការគ្រោងថវិកានៅតាមសាលារៀនមានភាពយឺតយ៉ាវ និងមិនស៊ីគ្នាជាមួយស្ថានភាពជាក់ស្តែងដែលពិបាកក្នុងការបូកសរុប និងចាត់ចែងបន្ត ។ ក្នុងន័យនេះ គួរតែទម្លាក់ថវិកាឱ្យបានទាន់ពេលវេលា និងមានមន្ត្រីចុះពិនិត្យសកម្មភាពចាយវាយ ការទូទាត់ ព្រមទាំងការចុះណែនាំពីរបៀបនៃការធ្វើផែន ការដល់សាលាដែលមានបញ្ហា..."

( DOP#.1.2.3 )

"...ផែនការមួយចំនួននៅមន្ទីរមិនសម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយមន្ត្រីទទួលបន្ទុកកិច្ចបញ្ជីការគណនីនៅតាមសាលាមានការផ្លាស់ប្តូរ ពិបាកដល់ការិយាល័យជំនាញក្នុងការចុះបណ្តុះបណ្តាលម្យ៉ាងវិញទៀតអ្នកទទួលបន្ទុកការងារផែនការនៅតាមសាលា និងអ្នកទទួលការបណ្តុះបណ្តាលមិនមែនជាមនុស្សតែមួយ ។ បញ្ហាខាងលើនេះ មានការប្រជុំណែនាំផ្សព្វផ្សាយឱ្យបានច្បាស់លាស់ និងទូលំទូលាយដើម្បីឱ្យអ្នកពាក់ព័ន្ធបានត្រៀមលក្ខណៈជាស្រេចក្នុងការអនុវត្ត..."

( Expert#.1.2 )

ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សនៅកម្រិតសាលារៀនពិតជាមិនអាចជៀសផុតពីបញ្ហាប្រឈមឡើយ។ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហាប្រឈមនានា របស់ប្រធាន-អនុប្រធាន មន្ទីរអប់រំយុវជន និងកីឡាខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ៖

"...មន្ត្រីទទួលបន្ទុកនៅតាមការិយាល័យជំនាញមួយចំនួន មិនទាន់មានភាពស្មោះត្រង់ចំពោះខ្លួនឯង មិនទទួលស្គាល់ការពិតទៅលើសមត្ថភាពខ្លួនដែលនាំឱ្យគុណភាពការងារមានការធ្លាក់ចុះ ។ ចឹងទេយើងត្រូវសិក្សាពីតម្រូវការជំនាញមួយនៅតាមការិយាល័យដែលយើងមើលឃើញថាមានបញ្ហា ដើម្បីរៀបចំឱ្យបានការបណ្តុះបណ្តាលសមត្ថភាពរបស់ពួកគាត់..."

( POE#.1.2 )

"...ខ្វះខាតធនធានដែលមានសមត្ថភាព ហើយអ្នកទទួលបន្ទុកទិន្នន័យនៅមានកម្រិតដែលនាំឱ្យមានបញ្ហាចំពោះការិយាល័យជំនាញ ឬអាចឃើតយ៉ាវដល់ការស្នើតែងតាំង ការតម្លើងឋានន្តរស័ក្ត ថ្នាក់ត្រូវបណ្តុះបណ្តាលជំនាញដល់មន្ត្រីទទួលបន្ទុក ដើម្បីធានាថាគាត់ពិតជាមានសមត្ថភាពឆ្លើយតប..."

( DOP#.1.2.3 )

"...ពេលថ្នាក់មន្ទីរអប់រំខេត្តធ្វើគោលនយោបាយនៅការអភិវឌ្ឍធនធានមនុស្ស មន្ទីរអប់រំខេត្តមិនបានយកគោលនយោបានអភិវឌ្ឍធនធានមនុស្សថ្នាក់ក្រសួងមកប្រើ មានដូចជាគោលនយោបាយ

សម្រាប់គ្រូបង្រៀន បុគ្គលិកមិនបង្រៀនជាដើម ម្យ៉ាងវិញទៀតការធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ថ្នាក់មន្ទីរហាក់បម្រើតែក្នុងមន្ទីរប៉ុណ្ណោះ ។ ដើម្បីដោះស្រាយបញ្ហាខាងលើ ការធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរត្រូវមានការគិតគូរពីថ្នាក់សាលា ថ្នាក់ស្រុក ដោយត្រូវមានការវិភាគពីតម្រូវការការអភិវឌ្ឍ សមត្ថភាពរបស់បុគ្គលិកទាំងបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន..."

( Expert#.1.2 )

បញ្ហាប្រឈមនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ពិតជាជះឥទ្ធិពលដល់ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ខាងក្រោមនេះ ជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហានានា របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...មន្ត្រីទទួលបន្ទុកផ្នែកតម្រង់ទិសវិជ្ជាជីវៈនៅមន្ទីរ មិនសូវមានភាពប៉ិនប្រសព្វទៅលើការតម្រង់ទិសវិជ្ជាជីវៈសម្រាប់សិស្សានុសិស្ស ដែលការនេះនាំឱ្យការតម្រង់ទិស ឬប្រឹក្សាអាជីពមិនបានគ្រប់ជ្រុងជ្រោយ និងសមស្របទៅតាមតម្រូវការរបស់ខាងឧត្តមសិក្សា ។ ជាដំណោះស្រាយ រវាងថ្នាក់មន្ទីរ និងខាងឧត្តមសិក្សាគួរណាស់តែមានគោលការណ៍ច្បាស់លាស់ មានទំនាក់ទំនងល្អជាមួយថ្នាក់មន្ទីរ ដើម្បីថ្នាក់មន្ទីរបានត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការអនុវត្តការងារឆ្លើយតបផ្នែកឧត្តមសិក្សា..."

( POE#.1.2 )

"...មន្ត្រីដែលទទួលបន្ទុកនៅការិយាល័យទទួលបន្ទុកនៅមន្ទីរ ហាក់មិនទាន់មានលក្ខណៈគ្រប់គ្រាន់តបទៅនឹងតម្រូវការរបស់មន្ទីរនោះទេ ដោយខាងមន្ទីរ និងឧត្តមសិក្សាមិនសូវមានទំនាក់ទំនងនឹងគ្នា ម្យ៉ាងវិញទៀត ការគ្រោងផែនការរបស់ថ្នាក់មន្ទីរមិនសូវបានផ្តោតស៊ីជម្រៅរឿងការងារឧត្តមសិក្សាឡើយ ។ ក្នុងន័យនេះ ក្រុមការងារខាងឧត្តមសិក្សា និងមន្ត្រីទទួលបន្ទុកថ្នាក់មន្ទីរគួរមានជាគោលការណ៍រួមមួយ ដើម្បីមានឱកាសបានដដែកពីអ្វីជាតម្រូវការរបស់ឧត្តមសិក្សា ហើយថ្នាក់មន្ទីរអាចជួយអ្វីបានខ្លះ..."

( DOP#.1.2.3 )

"...មន្ទីរបានត្រឹមលួចមើល និងលួចស្វែងយល់ពីគោលការណ៍របស់ឧត្តមសិក្សា និងមិនមានទំនាក់ទំនងទៅលើការងារបច្ចេកទេស រវាងមន្ទីរនិងឧត្តមសិក្សាទេ។ដើម្បីដោះស្រាយបញ្ហានេះ គួរមានសេចក្តី ណែនាំមួយពីថ្នាក់ក្រសួងពាក់ព័ន្ធបទដ្ឋានការងាររវាងមន្ទីរនិងឧត្តមសិក្សាដើម្បីឱ្យការអនុវត្តការងារ របស់ មន្ទីរឆ្លើយតបទៅនឹងតម្រូវការរបស់ឧត្តមសិក្សា..."

( Expert#.1.2 )

បញ្ហាប្រឈមនៃការអនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ការអភិវឌ្ឍយុវជន ពិតជាជះឥទ្ធិពលដល់ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ខាងក្រោមនេះជាទិន្នន័យដែលបានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហានានា របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្រ្តីនាយកដ្ឋានផែនការ និងដៃគូរអភិវឌ្ឍ ៖

"...ផែនការអភិវឌ្ឍផ្នែកយុវជនមានការពុំងស្ទះដោយកង្វះខាតថវិកា ខ្វះមន្រ្តីទទួលបន្ទុកតាមផ្នែក ឬសមត្ថភាពរបស់មន្រ្តីមិនទាន់ឆ្លើយតប និងថវិកាមិនទាន់ពេលវេលា ម្យ៉ាងវិញទៀតសកម្មភាពយុវជន មានការផុលផុសតែនៅទីប្រជុំជន។ដើម្បីដោះស្រាយបញ្ហាទាំងនេះ សូមឱ្យថ្នាក់ជាតិរៀបចំឱ្យមានកញ្ចប់ថវិកាឱ្យបានគ្រប់គ្រាន់ និងសូមទំលាក់ឱ្យបានទាន់ពេលវេលាព្រមទាំងសូមឱ្យមានការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការងារយុវជនឱ្យបានទូលំទូលាយ..."

( POE#.1.2 )

"...ខ្វះធនធាន នៅការិយាល័យយុវជន មានបុគ្គលិកតែសមត្ថភាពមិនទាន់ឆ្លើយតបទាំងជំនាញទន់ និងជំនាញរឹង ម្យ៉ាងវិញទៀតគោលនយោបាយថ្នាក់ជាតិធំពេក មិនស៊ីជាមួយថ្នាក់សាលា ថ្នាក់ស្រុក និង ថ្នាក់ខេត្ត..."

( DOP#.1.2.3 )

"...ថវិការបស់ក្រសួងមានចំនួនតិច មិនឆ្លើយតបទៅនឹងសកម្មភាពជាក់ស្តែង និងតម្រូវការរបស់ផែនការគ្រោងរបស់ការិយាល័យជំនាញនៅមន្ទីរឡើយ ។ ក្រសួងគួរបង្កើនកញ្ចប់ថវិកា ព្រមទាំងផ្តល់ថវិកាបានទាន់ពេល ដើម្បីធានាដល់និរន្តភាពគម្រោងឱ្យកាន់តែល្អប្រសើរឡើង..."

( Expert# 1. 2 )

បញ្ហាប្រឈមនៃការអនុវត្តយុទ្ធសាស្ត្រកំណែការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ពិតជាជះឥទ្ធិពលដល់ការអនុវត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរី ។ ខាងក្រោមនេះជាទិន្នន័យដែល បានពីការធ្វើសម្ភាសន៍លើការលើកឡើងពីបញ្ហានានា របស់ប្រធាន-អនុប្រធានមន្ទីរអប់រំខេត្ត មន្ត្រីនាយកដ្ឋានផែនការ និងដៃគូអភិវឌ្ឍ ៖

"...សន្ទុះចូលរួមមិនទាន់បានល្អប្រសើរ ដោយខ្វះការច្នៃប្រឌិតពីថ្នាក់ក្រោម ពីគណៈគ្រប់គ្រងសាលាដែលមិនមានការច្នៃប្រឌិតនូវសម្ភារងាយៗដើម្បីទ្រទ្រង់ផ្នែកអប់រំកាយ និងកីឡា ព្រមទាំងខ្វះគ្រូឯកទេសតាមផ្នែក តាមវិញ្ញាសា ថវិកាតិចហើយយឺត ហើយគ្រូដែលមានស្រាប់មានសមត្ថភាពមិនទាន់ឆ្លើយតប ។ ជាដំណោះស្រាយយើងត្រូវការគ្រូឯកទេសផ្នែកកីឡាមានគ្រប់គ្រាន់តាមសាលា ដើម្បីគាំទ្រដល់ផែនការរបស់មន្ទីរទទួលបានជោគជ័យ និងសុំឱ្យមានកញ្ចប់ថវិកាគ្រប់គ្រាន់ទាន់ពេលវេលា..."

( POE#.1.2 )

"...ខ្វះខាតថវិកាគាំទ្រ ទំហំថវិកាមិនស៊ីគ្នាជាមួយចង្កោមសកម្មភាព ខ្វះខាតយន្តការសម្របសម្រួល និងមិនសូវមានកិច្ចគាំទ្រពីប្រធានមន្ទីរ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ គួរមានកញ្ចប់ថវិកាគ្រាប់គ្រាន់ ទាន់ពេលវេលា ព្រមទាំងមានការចូលរួមពេញលេញពីអ្នកពាក់ព័ន្ធ..."

( DOP#.1.2.3 )

"...ការផ្តល់នូវគ្រូជំនាញផ្នែកកីឡាមិនទាន់ឆ្លើយតប និងស្របទៅតាមតម្រូវការ និងផែនការយុទ្ធសាស្ត្ររបស់ថ្នាក់ជាតិទេដែលនាំឱ្យផែនការគ្រោងរបស់មន្ទីរមិនទទួលបានលទ្ធផលល្អប្រសើរ ក្នុងន័យនេះ ថ្នាក់ក្រសួងគួរសិក្សាឱ្យបានស៊ីជម្រៅអំពីតម្រូវការពិតជាក់ស្តែង បញ្ហាប្រឈមរបស់ថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ដំណោះស្រាយឱ្យបានសមស្រប និងទាន់ពេលវេលា..."

( Expert#.1.2 )

តារាង ៤.១២ សរុបបញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ដែលទទួលបានពីការឆ្លើយតបរបស់គណៈគ្រប់គ្រងសាលា មន្ត្រីនៅការិយាល័យអប់រំក្រុង/ស្រុក និងមន្ត្រីការិយាល័យចំណុះមន្ទីរ អប់រំយុវជន និងកីឡាខេត្ត

| ល.រ | ការអនុវត្តគោលនយោបាយ | គណៈគ្រប់គ្រង | | | ការិយាល័យ អប់រំស្រុក និងការិ.មន្ទីរ | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | SD | កម្រិត | មធ្យមភាគ | SD | កម្រិត |
| ១ | ការកំណត់គោលនយោបាយអប់រំ | 3.48 | 0.11 | ល្អ | 3.30 | 0.18 | មធ្យម |
| ២ | ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ | 3.61 | 0.47 | ល្អ | 3.41 | 0.29 | ល្អ |
| ៣ | ការអនុវត្តផែនការ | 4.00 | 0.25 | ល្អ | 3.75 | 0.35 | ល្អ |
| ៤ | ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | 2.35 | 0.23 | ខ្សោយ | 2.26 | 0.30 | ខ្សោយ |
| សរុប | | **3.36** | **0.26** | **មធ្យម** | **3.18** | **0.28** | **មធ្យម** |

តារាង៤.១២ ខាងលើបានបង្ហាញថាគណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.៣៦)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ "ការអនុវត្តផែនការ" ក្នុងកម្រិត " ល្អ " (មធ្យមភាគ ពិន្ទុ=៤.០០)។ សូចនាករទទួលបានពិន្ទុទាបជាងគេគឺ "ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង" ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគ ពិន្ទុ= ២.៣៥) ។

មន្ត្រីនៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក និងមន្ត្រីនៅការិយាល័យចំណុះមន្ទីរអប់រំយុវជន និងកីឡាខេត្តបានផ្តល់ទិន្នន័យជាសរុបពីកម្រិត **បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន** ក្នុងកម្រិត "មធ្យម" (មធ្យមភាគពិន្ទុ= ៣.១៨)។ សូចនាករទទួលបានពិន្ទុខ្ពស់ជាងគេគឺ " ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ" ក្នុងកម្រិត " ល្អ " (មធ្យមភាគពិន្ទុ= ៣.៤១) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង" ក្នុងកម្រិត "ខ្សោយ" (មធ្យមភាគ ពិន្ទុ= ២.២៦) ។

តាមទិន្នន័យបែបបរិមាណវិស័យបានបង្ហាញឱ្យឃើញថា បញ្ហាប្រឈមនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំពុំទទួលបានជោគជ័យគឺដោយសារការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី និងគម្រោងនៅមានកម្រិត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ។

"...មន្ត្រីទទួលបន្ទុកផ្នែកហិរញ្ញវត្ថុនៅតាមអង្គភាពក្រោមឱវាទមួយចំនួនជាមន្ត្រីថ្មី ហើយប្រព័ន្ធគ្រប់គ្រងថវិកា គឺគេប្រើតាមបច្ចេកវិទ្យាដូចនេះមានបញ្ហាលំបាកហើយការបែងចែក និងការប្រើប្រាស់ថវិកានៅតាមសាលារៀនហាក់ដូចជាមិនទាន់ស្របទៅនឹងការណែនាំ ឬអាចនិយាយបានថា អ្នកចូលរួមទទួលការបណ្តុះបណ្តាល មិនមែនជាអ្នករៀបចំ និងធ្វើផែនការនោះទេ មួយវិញទៀតមួយរយៈនេះខាងថ្នាក់ក្រសួងហាក់រង្វើលក្នុងការចុះអធិការកិច្ច ដែលនាំឱ្យសាលាមួយចំនួនអាចនៅបន្តធ្វើខុសដដែលៗ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ មន្ត្រីនៅការិយាល័យជំនាញរបស់មន្ទីរត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងរកដើមចមឱ្យបានច្បាស់លាស់ រៀបចំផែនការដើម្បីបណ្តុះបណ្តាលដល់សាលា ឬមន្ត្រីទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុដើម្បីឱ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាព..."

( POE#.1.2 )

"...ថវិកាទំលាក់មិនទាន់ពេលវេលា ហើយសាលាខ្លះអនុវត្តថវិកាមិនអស់ ព្រមទាំងនីតិវិធីចាយវាយ លុយនៅតាមសាលារៀនមិនទាន់សមស្រប ដែលនាំឱ្យបានបញ្ហាដល់ការិយាលល័យជំនាញរបស់មន្ទីរ ។ ជាមួយគ្នានេះ ការគ្រោងថវិកានៅតាមសាលារៀនមានភាពយឺតយ៉ាវ និងមិនស៊ីគ្នាជាមួយស្ថានភាពជាក់ស្តែងដែលពិបាកក្នុងការបូកសរុប និងចាត់ចែងបន្ត ។ ក្នុងន័យនេះ គួរតែទម្លាក់ថវិកាឱ្យបានទាន់ពេលវេលា និងមានមន្ត្រីចុះពិនិត្យសកម្មភាពចាយវាយ ការទូទាត់ ព្រមទាំងការចុះណែនាំពីរបៀបនៃការធ្វើផែនការដល់សាលាដែលមានបញ្ហា..."

( DOP#.1.2.3 )

"...ផែនការមួយចំនួននៅមន្ទីរមិនសម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយមន្ត្រីទទួលបន្ទុកកិច្ចបញ្ជីការគណនីនៅតាមសាលាមានការផ្លាស់ប្តូរ ពិបាកដល់ការិយាល័យជំនាញក្នុងការចុះបណ្តុះបណ្តាល ម្យ៉ាងវិញទៀតអ្នកទទួលបន្ទុកការងារផែនការនៅតាមសាលា និងអ្នកទទួលការបណ្តុះបណ្តាលមិនមែន

ជាមនុស្សតែមួយនោះទេ ។ បញ្ហាខាងលើនេះ មានការប្រជុំណែនាំផ្សព្វផ្សាយឱ្យបានច្បាស់លាស់ ដើម្បីឱ្យអ្នកពាក់ព័ន្ធបានត្រៀមលក្ខណៈជាស្រេចក្នុងការអនុវត្តឱ្យទទួលបានជោគជ័យ..."

( Expert#.1.2 )

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

មានផែនការល្អ ដូចមានត្រីវិស័យសម្រាប់បង្ហាញទិសដែលអង្គភាពនោះត្រូវដើរទៅណា ពេលណា ដោយអ្នកណា ដើម្បីអ្នកណា ។ ដើម្បីជានាប្រសិទ្ធភាពនៅក្នុងអង្គភាព អង្គភាពនោះចាំបាច់ត្រូវអនុវត្តទៅតាមផែនការដែលបានគ្រោងទុក ។ ការដែលយើងទៅមើលពីលទ្ធផលនៃការអនុវត្តបានល្អប្រសើរ យើងត្រូវទៅមើលពីគុណភាពនៃផែនការជាមុនសិន ថាតើផែនការនោះបានរៀបចំសមស្របទៅតាមគោលនយោបាយ ឬបានកំណត់នូវបញ្ហាច្បាស់លាស់ ឬបានធ្វើការស្រាវជ្រាវប្រតិបត្តិជាមុនសិនដែរឬទេ មុនអនុវត្ត ដើម្បីឱ្យផែនការនោះមានលក្ខណៈបរិយាបន្ន និងមានការគាំទ្រពេលអនុវត្ត ហើយអ្នកអនុវត្តត្រូវចាំបាច់អនុលោមទៅតាមផែនការដែលបានគ្រោងទាំងនោះ ។

ការអនុវត្តផែនការវាស្តែងចេញនូវលទ្ធផលចំនួន ២ គឺទី១/ គុណភាពនៃផែនការ ឬផលដែលទទួលបានពីការអនុវត្តផែនការនោះ ទី២/ គឺផលប៉ះពាល់ដែលទទួលបានក្រោយពេលអនុវត្តផែនការនោះ ប្រសិនបើផែនការនោះគ្មានគុណភាព ឬការអនុវត្តផែនការនោះពុំទទួលបានជោគជ័យ ។ ឧទាហរណ៍ថា លទ្ធផលដែលទទួលបានពីការអនុវត្តផែនការ គឺគុណភាពសិក្សា ដែលទាំងអ្នកទទួលសេវា និងអ្នកផ្តល់សេវារួមមានសិស្ស គ្រូ គណៈគ្រប់គ្រង មាតាបិតា សហគមន៍ និងដៃគូអភិវឌ្ឍ មានការសប្បាយចិត្តទៅនឹងលទ្ធផលសម្រេចបានពីសកម្មភាពដែលមន្ទីរបានធ្វើនោះគឺ អត្រាបោះបង់របស់សិស្សមានការធ្លាក់ចុះ អត្រាចូលរៀនមានការកើនឡើង អត្រាឆ្លងភូមិសិក្សាមានចំនួនខ្ពស់ អត្រាបញ្ចប់ការសិក្សាមានចំនួនច្រើន ។ ការប្រមូលកុមារចូលរៀនអាយុ ៥ ឆ្នាំ សរុប ៦០.០៨ ភាគរយ ស្រី ៦១.០៥ នៃចំនួនប្រជាជនអាយុ ៥ ឆ្នាំ មានការកើនឡើងជាងឆ្នាំកន្លងទៅចំនួន ៦.៣៥ ភាគរយ ស្រីកើនឡើង ៨.៥៤ ភាគរយ ហើយអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា សរុប ៩០.២៣ ភាគរយ ស្រី ៩១ ភាគរយ បើប្រៀបធៀបឆ្នាំកន្លងមកបានកើនឡើង ៧.៧៤ ភាគរយ ស្រីកើន ៨.៦២ ភាគរយ ហើយអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សា

បឋមភូមិ សរុប ៥៧.៧៧ ភាគរយ ស្រី ៥៤.២១ ភាគរយ ប្រៀបធៀបឆ្នាំកន្លងមក បានកើនឡើង ១.៩២ ភាគរយ ស្រី ១៥.៣៦ ភាគរយ ។ សូចនាករនេះ បានបង្ហាញថាអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិមានការកើនឡើង ហើយអត្រានេះ មានការកើនឡើងខ្ពស់សម្រាប់កុមារី ( **របាយការណ៍សន្និបាតឆ្នាំសិក្សា ២០១៩-២០២០ របស់មន្ទីរអប់រំខេត្តរតនគិរី** ) ។

នៅពេលដែលថ្នាក់មន្ទីរធ្វើផែនការដោយផ្អែកទៅលើលទ្ធផលស្រាវជ្រាវច្បាស់លាស់ ព្រមជាមួយមានការចូលរួមពីភាគីពាក់ព័ន្ធ ទាំងអ្នកទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុ ប្រាកដណាស់ថាភាគរយនៃការអនុវត្តផែនការសកម្មភាពនឹងមានការកើនឡើង ព្រមទាំងទទួលបានលទ្ធផលការងារកាន់តែប្រសើរ ។

បញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព អាចជាមេរៀនមួយសម្រាប់ជាកញ្ចក់ឆ្លុះបញ្ចាំងសម្រាប់កែលម្អនូវចំណុចខ្វះខាត់នៅឆ្នាំបន្តបន្ទាប់ និងទាមទារឱ្យមន្ត្រីជំនាញទាំងអស់ត្រូវបន្តការយកចិត្តទុកដាក់ដែលរួមមានការបង្កើតក្របខណ្ឌកម្មវិធីដែលមានសូចនាករពិនិត្យតាមដាន និងវាយតម្លៃ ការកំណត់យុទ្ធសាស្ត្រអប់រំ និងរៀបចំផែនការរយៈពេលវែង និងមធ្យមជាដើម ។

សរុបសេចក្តីមក ការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តរតនគិរីគឺស្ថិតនៅក្នុងកម្រិតល្អ ដោយមានផ្នែកជាច្រើនដែលមន្ទីរបានអនុវត្ត ដោយហេតុថាគ្រប់ភាគីពាក់ព័ន្ធបានអនុវត្តការងារស្របទៅតាមផែនការដែលបានគ្រោង ព្រមទាំងបានធ្វើការបន្សុីគ្នារវាងផែនការរបស់សាលារៀន ផែនការរបស់ការិយាល័យក្រុង/ស្រុក និងផែនការរបស់មន្ទីរអប់រំខេត្ត ប៉ុន្តែនៅក្នុងនោះដែរការចូលរួមពីផ្នែកសហគមន៍ មាតាបិតាសិស្សគាំទ្រដល់គុណភាពសិក្សា ជាអ្វីដែលមន្ទីរត្រូវយកចិត្តទុកដាក់ពង្រឹងបន្ថែម ។ មួយវិញទៀត ការអនុវត្តទៅលើដំណើរការនៃការពិនិត្យតាមដាន និងវាយតម្លៃផែនការកម្មវិធី និងគម្រោង ហើយការងារអធិការកិច្ចសាលារៀន ជាអ្វីដែលមន្ទីរត្រូវដោះស្រាយទៅលើបញ្ហាដែលបានកើតមានឡើងតាមរយៈការបំពេញនូវធនធានមនុស្សដែលមានសមត្ថភាព ដើម្បីឱ្យឆ្លើយតបទៅនឹងបញ្ហាដែលបានកើតមានឡើង ។ ដើម្បីទទួលបានលទ្ធផលល្អ អង្គភាពដែលមានការរៀបចំផែនការល្អ មានការចូលរួមគ្រោងសកម្មភាពពីអ្នកពាក់ព័ន្ធ ទើបទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព ( Mateljak & Mihanovic. 2016 ) ។

## ៥.២ សំណូមពរ

តបនឹងលទ្ធផលបានពីការសិក្សាស្រាវជ្រាវខាងលើ វិធានការអនុវត្តគួរគប្បីមានដូចខាងក្រោម៖

- គណៈគ្រប់គ្រងមន្ទីរគួរតែធ្វើការស្រាវជ្រាវប្រតិបត្តិមួយដើម្បីរកឱ្យឃើញនូវបញ្ហា និងចំណុចខ្សោយនានានៅតាមការិយាល័យជំនាញដែលកើតមានធ្វើឱ្យលទ្ធផលការងារមិនសម្រេចបានទៅតាមលទ្ធផលរំពឹងទុក និងចំណុចដៅប្រចាំឆ្នាំ ។
- ប្រធានមន្ទីរគួរផ្តល់លទ្ធភាពឱ្យមន្ត្រីនៅតាមការិយាល័យនីមួយៗអាចធ្វើការគ្រោងសកម្មភាព ថវិកា ពេលវេលា ដោយធៀបទៅនឹងធនធានដែលមានស្រាប់ និងអាចអនុវត្តបាន
- ប្រធានមន្ទីរគួរគប្បីជំរុញ និងលើកទឹកចិត្តទៅដល់មន្ត្រីជំនាញទទួលបន្ទុកធ្វើផែនការ និងផ្នែកហិរញ្ញវត្ថុឱ្យមានការអភិវឌ្ឍខ្លួនជាប់ជាប្រចាំ ដើម្បីប្រសិទ្ធភាពការងារក្នុងបរិបទថ្មី
- មន្ត្រីជំនាញគួរគប្បីធ្វើការសិក្សាស្រាវជ្រាវប្រតិបត្តិមួយ ដើម្បីរកឱ្យឃើញពីបញ្ហាដែលនាំឱ្យការអនុវត្តផែន ការប្រតិបត្តិប្រចាំឆ្នាំមិនទទួលបានជោគជ័យ ទៅលើផ្នែកពាក់ព័ន្ធជាពិសេសនៅថ្នាក់សាលា និងថ្នាក់ក្រុង/ស្រុក
- មន្ត្រីជំនាញផ្នែកផែនការនៅមន្ទីរ ត្រូវចុះបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកផែនការនៅតាមសាលារៀន មន្ត្រីទទួលបន្ទុកផែនការនៅថ្នាក់ការិយាល័យអប់រំក្រុង/ស្រុក ក្នុងន័យនេះដើម្បីធានាថារវាងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ការិយាល័យអប់រំក្រុង/ស្រុក និងផែនការប្រតិបត្តិរបស់មន្ទីរត្រូវតែមានភាពស៊ីគ្នា និងមានសុគត្តភាព
- មន្ត្រីដែលទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុនៅមន្ទីរ ចាំបាច់ត្រូវតែជាធនធានដែលមានសមត្ថភាព ព្រោះថាផែនការខាងលើមានភាពស្មុកស្មាញច្រើន ព្រមទាំងមានយន្តការដាក់លាក់ក្នុងការចុះពិនិត្យតាមដាន និងវាយតម្លៃច្បាស់លាស់

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា. ( ២០១៩ ). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ២០១៩-២០២៣ [ ផែនការយុទ្ធសាស្ត្រ]. រាជធានីភ្នំពេញ ប្រទេសកម្ពុជាៈ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា. ( ២០២០ ). សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៩-២០២០ និងទិសដៅឆ្នាំសិក្សា ២០២០-២០២១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី ( ២០១៩ ). ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី [ ផែនការសកម្មភាព] ។ ក្រុងបានលុង ខេត្តរតនគិរី ប្រទេសកម្ពុជា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី ( ២០២០ ). ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី [ ផែនការសកម្មភាព] ។ ក្រុងបានលុង ខេត្តរតនគិរី ប្រទេសកម្ពុជា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី ( ២០២០ ). របាយការណ៍សមិទ្ធកម្មឆ្នាំ២០២០ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី [សកម្មភាព និងថវិកា] ។ ក្រុងបានលុង ខេត្តរតនគិរី ប្រទេសកម្ពុជា

ប្រទេសកម្ពុជារាជរដ្ឋាភិបាលកម្ពុជា. ( ២០១៩ ). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ [ផែនការយុទ្ធសាស្ត្រ] ។ រាជធានីភ្នំពេញ ប្រទេសកម្ពុជាៈ រាជរដ្ឋាភិបាលកម្ពុជា

ហង់ ជួន ណារ៉ុន. ( ២០១៨ ). យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ [ផែនការយុទ្ធសាស្ត្រ] ។ រាជធានីភ្នំពេញ ប្រទេសកម្ពុជាៈ ក្រសួងអប់រំ យុវជន និងកីឡា

Incheon Declaration. (2015). Education 2030: *Incheon declaration and framework for action towards inclusive and equitable quality education and lifelong learning for all* [Strategic Plan]. Incheon City: South Korea.

